ចំណេះដឹងគ្រប់វិនាទី

# ខ្មែរលើគម្ពីរ

# ស្វែងរកព្រះបាទជ័យវរ្ម័នទី៧



និពន្ធដោយ ជៀប គឹមហ៊ាង

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ខ្មែរឈើគម្ពីរ
# ស្វែងរកព្រះបាទជ័យវរ្ម័នទី៧

និពន្ធដោយ ជៀប គឹមហ៊ាង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សូមឧទ្ទិសកុសល

ដែលកើតមានពីការរៀបរៀងសៀវភៅនេះ

ជូនដល់លោកអ្នកមានគុណទាំងអស់

ជាពិសេស ចំពោះលោកឪពុក និងលោកអ្នកម្ដាយ

ជាទីគោរព ជាទីស្រឡាញ់ និងជាទីរឭករបស់ខ្ញុំ

ដោយអាឡោះអាល័យពន់ប្រមាណ ៗ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# វាចាអ្នកនិពន្ធ

៦៦៦

ម្ដេចឡើយ ទឹកដីនៃខ្ញុំ ត្រូវទំនាយអាក្រក់ ឈាមដាបពោះដីរ? តើខ្មែរមានកំហុសអ្វីខ្លះ?

ចិនអ្នកកាប់ជ្រូក ចាមកាប់គោ យួនចាប់ត្រី ។ ម្ដេចឡើយ កម្មធ្លាក់មក លើខ្មែរ? ។

ឈាមដាបពោះដីរ កន្លងផុតមកហើយ ។ អំណើះតទៅ ខ្មែរលែងមាន សង្គ្រាមទៀតហើយ?

មិនប្រាកដឡើយ ។ សង្គ្រាមនឹងកើតមាននៅស្រុកតូចតាច ដែលខ្វះការគ្រប់គ្រង ត្រឹមត្រូវ រវាង២៥ ឆ្នាំម្ដង ។ គឺ មួយជំនាន់មនុស្ស នេះតាមអ្នកឯកទេស ។

ដូចនេះ ទំនាយថាឈាមដាបពោះដីរ មិនមែនជា ពុទ្ធទំនាយ ឬទំនាយរបស់ព្រះពុទ្ធនោះទេ ហើយក៏មិនមែនជាកម្មពៀររបស់ខ្មែរទូទាំងប្រទេសនោះទេ ។ ជាការ ប្រមាណមើល នៃអ្នកដែល ស្គាល់ បុព្វហេតុនៃសង្គ្រាម ។ ប្រទេសនីមួយៗ ដើម្បីរស់មកដល់សព្វថ្ងៃ ឆ្លងកាត់សង្គ្រាមច្រើនផងណាស់ ។ ចាប់ពីសម័យអង្គរមក ខ្មែរ ស្គាល់ នូវ សង្គ្រាមច្រើនលើក ។ អំណើះ តទៅ យើងត្រូវរកវិធី ណា ចៀសវាង សង្គ្រាម ។ សង្គ្រាម មានច្រើនយ៉ាង ។ តែសង្គ្រាមក្នុងស្រុក សង្គ្រាមរវាងខ្មែរនិងខ្មែរ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នឹងអាចគេចបាន លុះត្រាតែយើងប្រកាន់យកមាគ៌ា មតិភាគច្រើនជាធំ ដូចយ៉ាងប្រទេសស្វីស។

ប្រទេសស្វីស ជាប្រទេសមួយដែលពុំស្គាល់នូវសង្គ្រាម ជាយូរមក ហើយជិតមួយពាន់ឆ្នាំហើយ ។ គឺថា តាំងពីជំនាន់អង្គរ រហូតដល់សព្វថ្ងៃ ស្វីសពុំដែលស្គាល់សង្គ្រាមម្តងណាឡើយ ។ កិច្ចការដែលគេត្រូវ សំរេច គេរមែងធ្វើការបោះឆ្នោត ជានិរន្តរ៍។

ជាមួយអ្នកជិតខាង ដែលរមែងចិញ្ចឹមចិត្ត ចង់បានទឹកដីយើង យើងត្រូវប្រុងប្រយ័ត្ន កុំឆេវឆាវពេក រិះរកប្រើផ្លូវបញ្ញាជាធំ។

ប្រទេសគេធំ មនុស្សគេច្រើន កម្លាំងបាយក៏គេមាន ។ យើង ប្រើកម្លាំងបាយលើគេ គឺយើងធ្លាក់ចូលក្នុងឧបាយកលរបស់គេ។

ត្រូវធ្វើខ្លួនខ្មែរឱ្យខ្លាំង ទើបខ្លាំងខ្លាច ។ ពីដើមកម្លាំងអ្វីក៏ដោយ ខ្មែរយើងជឿថា បានមកពីវត្ថុស័ក្តិសិទ្ធិ កន្សែងយន្ត កថា ខ្នាយតាន់ ។ល។ តែឥឡូវកម្លាំងអ្វីក៏ដោយ មកពីការខំប្រឹងហាត់ ប្រឹងរៀន ដូចជាកីឡា ធ្វើយ៉ាងណាឱ្យកាន់តែខ្លាំង កាន់តែលឿន កាន់តែខ្ពស់។

ពីដើមយើងជឿលើដីរស ជាអ្នកសំរេចជំនួសយើង ឥឡូវយើង ប្រើសន្លឹកឆ្នោត ជាអ្នកសំរេចជំនួសយើង។

ពីដើមយើងរស់នៅ បង្គើយនិងឋានសួគ៌ និងអារក្ខ អ្នកតា ទេវតា ព្រះឥន្ទ ព្រះព្រហ្ម...។

យើងដឹងថា នៅឋានសួគ៌មានរទេះសេះ (ភជរថ) មានជណ្តើរ (មាស ប្រាក់) មានអាមាត្យ មានឆ្នាំ មានអ្នកបររទេះសេះ។ ដូច្នេះ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅឋានសួគ៌ មានស្នេហា ដូចឋានកណ្ដាលដែរ ហើយប្រហែលជាគេចូលចិត្តស្នេហាជាងអ្វីទាំងអស់ ។

ពាក្យស្លោកយុវជនសម័យថ្មី មិនខុសពីគំនិតឋានសួគ៌ទេ

" Faire l'amour et pas la guerre "

" យើងកុំច្បាំងគ្នា យើងស្នេហាគ្នាវិញ " ។

តែឥឡូវឋានសួគ៌ ដូចជានៅឆ្ងាយ ។ យើងបាត់ដំណឹងសូន្យឈឹងពីព្រះជាម្ចាស់ ។ បន្ទាប់ពីពុទ្ធទំនាយទៅ តើនៅមានទំនាយអ្វីទៀត?

ជៀប គឹមហ៊ាង

អគ្គលេខាធិការ

សមាគមអ្នកនិពន្ធខ្មែរនៅបរទេស



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# លំនាំដើម

ថ្ងៃ ១៨ មិនា ឆ្នាំ១៩៧០ ឧត្តមសេនីយ **លន់ នល់** និង បក្សពួក បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេច។

នៅផ្នែកខាងកើតទន្លេមេគង្គ អ្នកស្រុកបះបោរ ធ្វើបាតុកម្ម ទាមទារ សម្ដេចមកវិញ ។

នៅទន្លេបិទ បាតុករចាប់ដំណាងរាស្ត្រ ពុះទ្រូង រុងយកថ្លើម និង ចាប់ប្អូនប្រុស **លន់ នល់** មួយ ដែលធ្វើជា កុម្ម៉ង់ស៊ែរ តិញ នៅជុប សម្លាប់ចោល ។

នៅភ្នំពេញ ចាប់ពីម៉ោង៨ ភ្លឺទៅ ផ្កាយដុះកន្ទុយវែងអន្ទាយ ធ្លាក់ លើទន្លេបួនមុខ នៅចំពីមុខព្រះបរមរាជវាំង ។

អ្នកស្រុកជឿថា សង្គ្រាមច្បាស់ជាកើតមានមិនខាន ។ កម្ពុជា កោះសន្តិភាព រអិលបន្តិច ម្តងៗ ទៅក្នុងភ្លើងសង្គ្រាម ។

ឧត្តមសេនីយ **លន់ នល់** ប្រកាសឡើងជាសេនាប្រមុខ ផ្កាយ ប្រាំពីរ ប្រែប្តូរនយោបាយស្រុកមួយរំពេច ប្រែប្តូរវាសនាប្រទេស រុញ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រាននាវាកម្ពុជាចូលក្នុងភ្លើងសង្គ្រាមវៀតណាម ដែលរៀបនឹងរលត់ទៅហើយ ។

" វាសនាខ្មែរ គឺមកពី នយោបាយ **លន់ នល់** " ជិត២៥ ឆ្នាំ សង្គ្រាមបន្តបន្ទាប់ រាលដាលដុតឆេះ កំទេចកម្ពុជា ឱ្យទៅជាផេះ ។ រាស្ត្រមានទុក្ខ បាត់សេចក្ដីសុខ វេទនារកទីបំផុតគ្មាន ។

បក្សពួក **លន់ នល់** អ្នកមានថ្មី ឃ្លាតខ្ទីវាស់ដី វាតអំណាចចែកដុល្លារគ្នា ។

ខ្មែរអើយ! ឈាមជាបពោះដីរ ទទួលយកទៅ បាបកម្មអ្នកហើយ ។ បាបសំរាប់រាស្ត្រខ្មែរ សំរាប់អ្នក រីឯមាស ប្រាក់សំរាប់អញ និងបក្សពួក វេចខ្ចប់រត់ឡើងឧទ្ធម្ភាគចក្រ មុននឹងនាវាកម្ពុជាលិច ។

<< Le destin c'est la politique >>

Napoléon






www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ពុក!

## តើនេះជាបាបកម្មខ្មែរឬ?

តើមានតែខ្មែរទេឬ ដែលស្គាល់នូវឈាមជាបពោះជំរឺ? ពេលដែលខ្មែរក្នុងស្រុកមានទុក្ខ ខ្មែរនៅបរទេសក៏មានទុក្ខដែរ? តើពុទ្ធទំនាយសំដៅតែខ្មែរក្នុងស្រុកតែប៉ុណ្ណោះ ខ្មែរដែលឈានជើងផុតពីព្រំដែន ខ្មែរលែងបាបហើយឬ?

សាសន៍ដទៃឯទៀតគេធ្វើបុណ្យអ្វី បានជាគេស្គាល់តែសេចក្តីសុខ? គេឥតបែកគ្រួសារ បែកប្រពន្ធ បែកកូន បែកម៉ែ បែកឪ បែកសង្សារ បែកស្នេហា ៗ គេមិនសម្លាប់គ្នា?

ពុក ទ្រុឌទ្រោមណាស់ហើយ បង់កក្រមា អង្គុយនៅមុខទូរទស្សន៍ មើលជនភៀសខ្លួន ជម្រូវទាំងបង្ខំចិត្ត រត់ចោលភូមិកំណើត បោះចោលអស់ហើយនូវអនុស្សាវរីយ៍



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នានា ជីធ្វី ជំណាំបន្ទៃ របស់ដែលខ្លួន ខិតខំសំចៃ ខំសន្សំជាយូរពេលមកហើយ ។

មនុស្សទាំងហ្វូង ក្មេងចាស់ស្រីប្រុស ទឹកមុខក្រៀមក្រំមហាស្រងូត មហាទុក្ខ ទូលលី របស់បន្តិចបន្តួច ដែលអាចយករួច ពោះជំហាន ឈានទៅរកកន្លែងថ្មី កន្លែងដែលខ្លួនសង្ឃឹមថា ផ្តល់សេចក្តីសុខ ។ ប្រគល់ជីវិតទៅលើវាសនាទាំងស្រុង ។ ជីវិតអណ្តែត ដូចបក ឥតបកក្រោយឡើយ ។

ភូមិឋាន ធ្លាប់សុខ ធ្លាប់ស្រណុករស់នៅ ក្លាយទៅជារណ្តៅភ្លើង ដុតឆេះអស់ហើយ ។

ឈាមខ្មែរ ហូរខ្ជុលខ្ជាញ់ លាយនិងទឹកភ្លៀងហូរចាក់ទៅក្នុងបឹង ។ ភ្លៀងខ្លាំងៗ ខ្យល់បក់រំកំរើ ដើមឈើរបេះរេឡើង បង្កើនទុក្ខទ្វេ ។ ខ្មែរអស់ជំរក ឈររងា ញ័រ ។

ព្រះអើយ! គ្មានអ្នកណាអាចជួយអ្នកបានឡើយ ។ នេះហើយកម្មពៀរ ពីអតីត?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

លាហើយដែនដី គោកធ្លក ជំរកក្រៀមក្សាន្ត ។ លាហើយ សុវណ្ណភូមិ ដែនដីសម្បូណ៌មាសពេជ្រ ។

ជនជាជកជន្ទើមធំ ដូតទឹកភ្នែកទឹងក្រមា ស្រែកហៅទេពី ពិបស្ត្រានបាយ ឲ្យមកមើល ទូរទស្សន៍ជាមួយគាត់ ។

ទេពី ញ័ររន្ធត់ ឃើញសោកវិនាសកម្មខ្មែរ ដែលគេបញ្ចាំង តាមទូរទស្សន៍បារាំង ។

កូនតូចទំលើស្មាឪពុក ខ្ទប់មុខយំ ។ មាណព ដៃម្ខាងកាន់កូនបង ដៃម្ខាងទៀតកាន់បង្អិចតូចមួយ សំណល់បានមកពី ការកសាងចំនួន៣០ ឆ្នាំ ។ ផ្ទះ ដែលខ្លួនធ្លាប់នៅត្រូវភ្លើងឆេះ សន្ធោសន្ធៅ ។

ទេពី លុតជង្គង់ លើកដៃប្រណម្យ បន្ទឹកវាចាថា៖

ឱ! ព្រះជាម្ចាស់អើយ! នេះហើយ ឬ ដែលខ្មែរហៅថា ឈាមជាបពោះដីរ ។ ខ្មែរ ដែលទន្ទឹងមើលផ្លូវយូរហើយ ខ្មែរដែលនិយាយ តៗគ្នាថា ឈាមជាបពោះដីរ ឥឡូវនេះមកដល់ហើយ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តើនៅខ្ទះឈាមប៉ុន្មានទៀត ទើបដល់កម្រិត ដែលព្រះលោកម្ចាស់តម្រូវ កំណត់ដល់រាស្ត្រខ្មែរ រហូតដល់ពោះជំរឺ !

ទឹកភ្នែកឆេទី ហូរស្រក់ ដោយមិនដឹងខ្លួន ។ នាងខិតខំរាវរកក្នុងចំណោមអ្នកភៀសខ្លួន ក្រែងឃើញខេមរា ឃើញបងប្អូន ឃើញមនុស្សម្នា ដែលនាងធ្លាប់ស្គាល់ ។

ពុកអើយ! ឆេទី ស្រដីទៅជនពិការ ដែលមានអាយុប្រមាណ៦០ឆ្នាំ ប្រមុះស្រួច មាឌខ្ពស់ ជាបារាំងចេះខ្មែរច្បាស់លាស់ ចេះមើលអក្សរ សំស្ក្រឹត មើលសិលាចារឹកលើអង្គរវត្តទៀត ។

ម្តេចឡើយ បានជាស្រុកខ្មែររងទុក្ខធំឥតល្ហែ ខ្មែរមានកំហុសអ្វីខ្លះ?

ជនបារាំង! ឈ្មោះប្រូន់ស៊ឺរ ឆ្លើយថា៖ អ្វីដែលអ្នកឃើញជាខ្មែរមានទុក្ខ មិនមែនខ្មែរទាំងអស់នោះទេ មានខ្មែរមួយចំនួន រស់ដោយសប្បាយ រស់លើគំនរទុក្ខគេ ។ ខ្លះធ្វើសង្គ្រាម ព្រោះសង្គ្រាមផ្តល់ប្រយោជន៍ដល់គេ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តើអ្នកណាទៅ មានប្រយោជន៍ ក្នុងរឿងនេះ? ឆេទី នាងសួរ!

ក្រូចស៊ះ មិនចាំបាច់និយាយទេ នាំប៉ះពាល់ដល់គេឯង ៗ អ្នកដែលមានប្រយោជន៍ ក្នុងរឿងនេះ គឺអ្នកដែលកំពុងតែសង់វិឡា អ្នកដែលបុណ្យស័ក្តិ ឡើងក្រឹតៗ ។

ឆេទី បន្ត! ចាប់ពីសម័យអង្គរ រហូតដល់ឥឡូវ ច្រើនជំនាន់មនុស្សហើយ ហាក់ដូចជាគ្មានយុគណាមួយ ដែលខ្មែររីករាយ ខ្មែរសម្បូណ៌សប្បាយ ខ្មែររុងរឿង ខ្មែរខ្លាំងពូកែ ល្បីរន្ទឺ ដូចកាលជំនាន់ព្រះបាទជ័យវរ្ម័នទី៧ ឡើយ ។

ម្តេចឡើយខ្មែរ មិនខិតខំ ស្រាវជ្រាវរាវរក បន្តបង្កើតឲ្យបានច្រើន មនុស្សដូចព្រះបាទជ័យវរ្ម័នទី៧? ។ យើងបង្កើតបានមួយហើយ ម្តេចមិនបង្កើតពីររូបបីបួនទៀត ។ ពេលនេះខ្មែរត្រូវការ ព្រះបាទជ័យវរ្ម័នទី៧ ជាងពេលណាទាំងអស់ៗ ព្រះអង្គចាប់ជាតិនៅឋានណា? យើងពុំបានលើកដំកើង ស្នាដៃ ជ័យហិមា នៃព្រះអង្គឡើយ ។ អ្នកស្គាល់ផ្លូវដែលមានឈ្មោះព្រះបាទជ័យវរ្ម័នទី៧ នៅក្រុងភ្នំពេញ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឬទេ? តើមានរបស់អ្វីខ្លះដែលមានឈ្មោះព្រះបាទជ័យវរ្ម័នទី៧ សាលារៀន មន្ទីរពេទ្យ...។ល។

ការដែលយើង ពុំដឹងគុណ ដល់មហាវីរបុរស ដូចនេះហើយ ដែលនាំឲ្យព្រះអង្គ លែងកើតមកជាខ្មែរទៀត?

ឆេទី ស្រដីទៅកាន់ប្រូង់ស័រ ថា៖

ពុក! ពេលដែលខ្ញុំ ដឹងក្តី គេរមែងស្រដីថា ទុក្ខសោកខ្មែរ បណ្តាលមកពីអាណានិគមបារាំង តើរឿងនេះយ៉ាងណាដែរ?

ប្រូង់ស័រ ដកដង្ហើមធំ បិទភ្នែកសន្សឹមៗ រំពឹងរិះគិត ចាប់ផ្តើមបរិយាយរឿងរ៉ាវ ដូចតទៅ៖



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# បុប្ផាប្រាំទង

បារាំងបានយកប្រទេសខ្មែរ ដាក់ជាចំណុះ នៅឆ្នាំ ១៨៦៣ ។ កាលណោះ មិនមែនមានតែប្រទេសខ្មែរមួយទេ ដែលនៅក្រោមអាណានិគមបារាំង ។ ឥណ្ឌូចិន ទាំងមូល (វៀតណាម លាវ និង ខ្មែរ) ត្រូវបារាំងត្រួតត្រា អាណានិគម បំរាញ់យកផល។ សូម្បីតែប្រទេសចិនឥណ្ឌៀ ឥណ្ឌូណេស៊ី ដែលមានប្រជាជន ច្រើនមហិមា ក៏ពុំអាច តតាំងនឹងកម្លាំង សាសន៍ស បានដែរ ។ ត្រួតសង្កត់ ប្របាច់ កាប់ក ដៃលូក រាវរកក្នុងហោប៉ៅ រាវរកត្បូង មាស ពេជ្រនានា ។ បារាំង ប្រើវិធី មិនឲ្យខ្មែររើខ្លួនរួច ។ ក្តិបត្រួយ គាស់ឫស មិនឲ្យលូតលាស់កើត ។ របនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង រៀប យ៉ាងណា សំរាប់បំរាញ់យកផល ។ គគូរ បំពុលសតិ អារម្មណ៍ កាប់ផ្តាច់ព្រលឹងជាតិ ឲ្យខ្មែរស្អប់ខ្មែរ ខ្មែរធ្វើបាបខ្មែរ ខ្មែរជៀលខ្មែរ ខ្មែរបាក់ស្បាត ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

របៀបនេះ គេប្រើ នៅពេលណា ដែលគេមានគ្នាតិច សំរាប់គ្រួតមនុស្សច្រើន ។



L'EXPÉDITION FRANÇAISE DU TONKIN : LA COUR MARTIALE À HANOÏ
D'après un croquis de M. [illegible], correspondant [illegible] de *l'Illustration*.

របៀបកាត់ទោស កាលជំនាន់អាណានិគម របៀបមនុស្សភាគតិចគ្រួតមនុស្សភាគច្រើន ដែលបារាំងហៅថា (Oligarchie) ។ នៅឆ្នាំ១៩២១ ប្រជាជនខ្មែរមាន២.៤០២.៥៨៥ នាក់ បារាំងប្រុសមាន ៤៨៧ នាក់ ស្រីមាន២៨៦ នាក់។ បារាំងប្រុសជិត៥០០នាក់ គ្រួតស្រុកខ្មែរ២,៥ លាននាក់។ ពួកប៉ុលពតក៏មានគ្នាតិចដែរ គ្រួតត្រាស្រុកខ្មែរ។ នៅស្រុកចិន គ្នា៤នាក់(Bande des quatres ) ផុតភ្លើងសង្គ្រាមអុកឡុក ឆាំកលីបរុក ទូទាំងប្រទេស។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅឆ្នាំ១៨៧៣ បារាំងមានចំនួន ១៨០ នាក់ នៅក្រុងហាណូយ ត្រួតត្រាវៀតណាម ។

ពេលដែលបារាំង ឃើញអង្គរ ដំបូង មហាបុរី ដ៏ប្រិមប្រិយ ឋិតក្នុងព្រៃរហោឋាន ហើយមានខ្លាដំរី រួចត្រូវគេបោះបង់ចោលក្នុងព្រៃ ដូចរឿងព្រេងនិទាន ។ បារាំងឃើញអង្គរ ពេលដែលខ្មែរ ធ្លាក់ដល់បាតដាល ។ បារាំងពុំឃើញអង្គរ ពេលដែលទើបកសាងឡើងហើយនោះទេ ។

បារាំងបានវាយទូរលេខ ទៅប៉ារីស ថាខ្លួនរកឃើញអង្គរ ៖ << Découverte d'un k or >>

អ្នកនៅក្រុងប៉ារីស ឃើញទូរលេខភ្លាម មើលយល់ច្រឡំ ស្មានតែ គេរកឃើញមាសមួយគីឡូ នៅលើដីខ្មែរ ។ ព្រោះអក្ខរាវិរុទ្ធ អង្គរ សរសេរ UN K OR ( ស្រដៀងនឹង UN Kg OR ដែលមានន័យថាមាសមួយគីឡូក្រាម) ។

ពាក្យចចាមអារាម ពីមាត់មួយទៅមួយ ថាស្រុកខ្មែរសម្បូណ៌ទៅដោយមាស ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ភ្ញាក់ផ្អើលឆោឡោ ប៉ារ៉ាំងខ្លះធាក់វ៉ាលិស ធ្វើការផ្សងព្រេង មកកាន់ឥណ្ឌូចិន ។ ពាក្យឥណ្ឌូចិន បង្កើតឡើងនៅឆ្នាំ១៩០៧ ។ ខ្លះទៀតឲ្យឈ្មោះថា បុប្ផា៥ទង ព្រោះទឹកដីឥណ្ឌូចិនល្អដូចបុប្ផា រួមផ្ដុំដោយដំបន់៥៖

កូសាំងស៊ីន អណ្ណាម តុងកឹង កម្ពុជា និង លាវ ។

ប៉ារ៉ាំងចាប់ផ្ដើម ដើមឡើយ យកប្រទេសយួន រួចមកបានយកស្រុកខ្មែរទៀត ។

ពុក! ហេតុដូចម្ដេច បានជាប៉ារ៉ាំងពូកែម្ល៉េះ កាលជំនាន់នោះ?

មិនមែនតែប៉ារ៉ាំងទេដែលពូកែ សាសន៍សដទៃទៀត ក៏ពូកែដូចគ្នា ដូចជា អង់គ្លេស ហុល្លង់ បែលហ្ស៊ិក អាល្លឺម៉ង់ ។ល។ ពូកែ ដោយគេរកឃើញម៉ាស៊ីន រកឃើញគ្រឿងផ្ទុះ (គ្រាប់បែក កាណុង ។ល។) និងម្ហូបអាហារកំប៉ុង ទុកបានយូរ ។

ពេលនោះ យើងជឿតែព្រះជិនវង្ស ស័ង្ខសិល្ប៍ជ័យ ថ្វីងសរសម្លាប់យក្ស រាប់លាន តែពុំអាចសម្លាប់ប៉ារ៉ាំងបានទេ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិទ្យាសាស្ត្រ អាចឲ្យគេធ្វើកប៉ាល់ទឹកធំៗ បើកបរតាមសមុទ្រ ឥតភ័យខ្លាច ហើយអាចរស់យូរអង្វែងលើកប៉ាល់ ដោយពុំបាច់ចុះលើដីគោក ទៅរកស្បៀង ។

ប្រទេស ដែលនៅប្រើព្រួញ ដាវលំពែង ពុំអាចបាញ់ទម្លុះកប៉ាល់ទឹកបានឡើយ ។

ក្អកឃុងៗ រន្ទើនជួនគ្នា ខ្សួចសំរុះជកដង្ហើមដោយពិបាក ។

ពុក! កុំប្រឹងនិយាយពេក ។

ឆេទី រត់ទៅយកទឹកមួយកែវ រួចលុតជង្គង់ ជូនពុក ។

ពុកអរគុណ ដល់ឯងច្រើន ដែលបានជួយយកអាសារពុក ថ្វីត្បិតតែឯង ជាអ្នកក្រៅ តែការស្មោះត្រង់របស់ឯងធ្វើឲ្យពុក រំភើបជាខ្លាំង ។ នេះជាលក្ខណៈដ៏ល្អមួយនៃខ្មែរទូទៅ ។ ក្នុងពេលទុក្ខព្រួយ ខ្មែរកម្រ បោះបង់ចោល មិត្តភក្តិណាស់ ។

ពុកសង្កេតឃើញ ពេលដែលពុករស់នៅស្រុកខ្មែរ ។ សាសន៍ដទៃទៀត ដូចចិនយួន គិតកំរៃ គិតប្រយោជន៍ចំណេញជាធំ ។ មនុស្សរបៀបនេះ ពិបាកយកគ្នាជាមិត្ត



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ណាស់ៗ មកដល់ពេលនេះ មកដល់អាយុ ប៉ុណ្ណេះ ពុក ស្តាយជាងគេ គឺឯង ពុំទាន់បានជួបខេមរា ៗ ឯងសុខចិត្តលះបង់ស្នេហា មករស់នៅជាមួយពុក ៗ មកដល់ថ្ងៃនេះ គ្មានដំណឹងអ្វីសូន្យឈឹង ៗ

ខេមរា បញ្ចេញវាចា! ទោះជាយ៉ាងណា ខ្ញុំសង្ឃឹមថា ព្រះដ៏មានព្រះភាគ មានបុណ្យខ្ពស់ហួសនិស្ស័យ ប្រណីដល់បងខេមរាផង ៗ

សុំតែរស់ ៗ សូមព្រះអង្គ កុំធ្មេចភ្នែក កុំបណ្តោយឲ្យខ្មែរក្រហមសម្លាប់មនុស្ស ដែលមានគុណបំណាច់ដល់អង្គរឡើយ ៗ

ហាលភ្លៀង ហាលថ្ងៃ ឈររៀបឥដ្ឋ រៀបថ្ម បន្តុបបន្តរៀបឲ្យល្អ ឡើងវិញ ៗ

ពុកអើយ! ពេលដែលខ្ញុំឈានជើងចាកចេញ កម្ពុជា ចិត្តសែនរងាពេកក្រៃ ៗ មកដល់ស្រុកបារាំង ខ្ញុំរឹតតែរន្ធត់ថែមទៀត តែខ្ញុំតាំងចិត្ត ថា "បើគេរស់កើត ខ្ញុំក៏រស់កើតដែរ" ។ ខ្ញុំអាចអត់មិនស៊ី ផឹកទឹកដេក ក៏បាន ព្រោះខ្ញុំគ្មានលុយ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

កាក់អ៊ី ទៀយ ៗ អ៊ីដែលខ្ញុំធ្វើ គឺបំពេញបំណងបង ខេមរា ដែលស្រឡាញ់ពុក ពន់ពេកក្រៃ ៗ ស្នេហាអាចឲ្យខ្ញុំពុះពារ គ្រប់បែបយ៉ាង ដើម្បីបំរើស្នេហា ៗ រស់នៅឆ្ងាយពីស្នេហា តែនៅតែស្នេហា ៗ នេះជាកម្មខ្ញុំទេ !

ពេលយប់ខ្ញុំគេង ៗ ខ្ញុំគេងសម្រក់ទឹកភ្នែក ណាមួយពុកឈឺ ពុំដឹងជាយ៉ាងណា? ណាមួយគ្មានបងប្អូន មាមីង ដូចនៅស្រុកយើង ៗ អ៊ីៗក៏ត្រូវរៀនទាំងអស់ រៀនជិះរថភ្លើង រៀនមើលផ្លូវ រៀនដើរកុំឲ្យឡានបុក រៀនទិញអីវ៉ាន់ ...ៗលៗ

តែស្រុកគេមានការគ្រប់គ្រង ចាត់តាំងល្អ ជួយដល់អ្នកឈឺថ្កាត់ ៗ

ម្រួចសំរ និយាយ! ដូចពុក កុំតែបាន Sécurité sociale (សង្គមនីរភ័យ សំរាប់លើកតម្លៃសន្តិសុខដល់សង្គម ) កុំអីពុក នឹងធ្លាក់ខ្លួនក្រហើយ ព្រោះជេកពេទ្យ ថ្លៃណាស់ ៗ

ពុក! ឆេទី សួរ ៖

Sécurité sociale កើតពីពេលណាមក?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

-ពេលដែលសង្គ្រាមលោកលើកទីពីរ ជិតដល់ទីបញ្ចប់ហើយ អ្នកដឹកនាំបារាំង ជឺផ្សិត កំពុងតែធ្វើសង្គ្រាម នាំគ្នារិះគិតរកវិធីណានឹងរករបៀបណាមួយជួយដល់បារាំងទាំងអស់ ឆ្វេងក្តី ស្តាំក្តី ដែលបានត្រួតពួតដៃគ្នា ដេញអាល្លឺម៉ង់ចេញពីទឹកដីខ្លួន ។

គេមានគំនិត មិនដូចគ្នាមែន តែគេនៅជាបារាំង ។ អ្វីដែលជាប្រយោជន៍ បារាំង គេរួមសាមគ្គីគ្នា ការពារប្រយោជន៍រួម ។

គិតចុះ គិតឡើង ទើបបានរកឃើញ Sécurité sociale នេះឡើង ព្រោះគេយល់ថា ក្នុងជីវិតមនុស្សម្នាក់ៗ បើឈឺហើយ មានពេទ្យមើល ដោយឥតគិតថ្លៃ នោះមួយផ្នែកនៃជីវិត មានការធានាអះអាង ។ ហើយភាពស្មើគ្នា ក៏បានមួយផ្នែកធំដែរ ។ ហេតុដូចនេះហើយ បានជាពុកឥតបង់លុយអ្វីឡើយ ។

និយាយដល់ត្រឹមនេះ ម្រួចសំរ ឃើញទឹកភ្នែក ឆេទឺ ហូរធ្លាក់ពីរឆ្នង់ជំផូរផង់ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឆេទី ! ហេតុអ្វីបានជានាងយំ ទឹកភ្នែកអ្នក ហូរច្រើនម៉្លេះ? អ្នកមានបញ្ហាអ្វីឬ? ប្រាប់ពុកមកបានទេ ព្រោះពុកគ្មានបងប្អូនណាផ្សេងទៀត ក្រៅពីឯងនិងខេមរាទេ ។

ពុកអើយ! គ្រាន់តែឮពុកនិយាយពី Sécurité sociale ពុកនិយាយពីអ្នកដឹកនាំគេ ដែលខិតខំរិះរកវិធីជួយប្រជារាស្ត្រគេ ឲ្យរស់នៅបានស្រួល ខ្ញុំរំភើបជាខ្លាំង ។ ខ្ញុំនឹកដល់ម្ដាយខ្ញុំ ដែលមានកូន៨នាក់ ។ ពេលឥតពីឪពុកខ្ញុំទៅ គាត់ឈឺទៀត គ្មានប្រាក់ខែ គ្រួសារធ្លាក់ខ្លួនក្រ ។ គ្រួសារដែលរស់នៅជុំគ្នា ពេលបាយ ពេលបុណ្យ យើងប្រឡែងលេងសើចសប្បាយ ទៅតាមយុវវ័យ បែរជាព្រាត់ប្រាសគ្នាអស់ ។ ខ្ញុំត្រូវមករស់នៅជាមួយ ម្ដាយមីង ឯខេត្តសៀមរាប ។ ប្អូនខ្លះទៀតទៅនៅជាមួយ មាមីង ផ្សេងទៀត ។ យើងព្រាត់គ្នា បន្តិចម្ដងៗ យូរៗជួបមុខគ្នាម្ដង ។

ម៉ែទៅបួសជាដូនជី ព្រោះម៉ែមិនសប្បាយចិត្ត នឹងជីវិតជាតិនេះ ។ ម៉ែប្រាថ្នា សុំឲ្យជាតិក្រោយបានប្រសើរជាងជាតិនេះ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ម៉ែធ្វើយ៉ាងណា ឲ្យជីវិតម៉ែធាប់ចប់ ដើម្បីទៅកាន់ភពថ្មី ដែលម៉ែសង្ឃឹមថាច្បាស់ជាប្រសើរជាងជាតិនេះ ។

ពេលដែល ខ្ញុំជួបម៉ែ យើងពុំសូវនិយាយគ្នាប៉ុន្មានទេ ម្នាក់ៗយំរៀងខ្លួន ។ ភ្នែកយើងជាតិនេះ សំរាប់យំតែប៉ុណ្ណោះ ។

ម៉ែសួរ ដំណឹងពីកូនផ្សេងទៀត តែម្នាក់ៗ រស់ដោយពិបាករៀងខ្លួន ។

ខ្ញុំបាននាំចំណីបន្តិចបន្តួច ផ្ញើម៉ែ តែម៉ែទទួលទានលែងកើតហើយ ។ លុយដែលយើងមានសល់បន្តិចបន្តួច ម៉ែគិតទៅដល់ពុក ម៉ែទិញរបស់ល្អៗធ្វើបុណ្យបញ្ជូនទៅពុក ។ តើពុកបានទទួលឬទេ?

តើមានតែម៉ែខ្ញុំទេ ឬមានតែគ្រួសារខ្ញុំទេ ដែលមានទុក្ខដូចនេះ?

បើម៉ែ រស់នៅស្រុកបារាំង ម៉ែមិនធ្លាក់ខ្លួនដូចនេះទេ ព្រោះសង្គមគេ បាត់បែងឡើងដើម្បីការពារមនុស្ស កុំឲ្យធ្លាក់ក្នុងអវបីដូចនេះ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ម៉ែមិនបាច់ប្រាថ្នាជាតិក្រោយឡើយ ព្រោះមានវិធីដោះស្រាយ សំរាប់ជាតិនេះហើយ ៗ ស្រុកគេ គេដោះស្រាយ បាន ហេតុអ្វីបានជា យើងធ្វើមិនបាន?

ម្រួចសំសួរទៅនាង **ទេវី**!

ពុកពុំដែលមានឱកាសសួរឯង តើឯងនិង **ខេមរា** ជួបគ្នានៅពេលណា?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ស្នេហ៍ដំបូង

យកដៃជូតទឹកភ្នែក រួច ទើបចាប់និទានរឿងខ្លួន ។ ខ្ញុំជាអ្នកកំពង់ចាមៗ ឪពុកធ្វើជាទាហាន ។

ពុកបាត់ខ្លួននៅភ្នំ សំឡូត ។ កាលណោះ មានការបះបោរ រវាងទាហាននិងអ្នកស្រុក ស្តីពីរឿងដីធ្លី ។

ប្រួចសំរ- យើងត្រូវប្រយ័ត្ន នឹងរឿងដីធ្លី ស្រុកណាក៏ដូចស្រុកណាៗ ប្រជាជន តែងជាប់ចិត្តនឹងទឹកដីរបស់ខ្លួន ។ ទឹកដីជាកេរ្តិ៍ មរតក ទឹកដី ជាជម្រកគ្រួសារ ជាកន្លែងដែលខ្លួនខិតខំជីកតាស់ ដាំដុះដំណាំផ្សេងៗ ដោយកម្លាំងញើសខ្លួនឯង ។ កម្លាំងគ្រួសារ ទាំងប៉ុន្មាន ប្រមូលផ្តុំ របនាដីឱ្យមានទ្រង់ទ្រាយ ឱ្យផ្តល់ផលទៅតាមកម្លាំងញើស កម្លាំងប្រាជ្ញាខ្លួន ។ ជាសរុប ជាអនុស្សាវរីយ៍ សំរាប់គ្រួសារនិមួយៗ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឆេទីបន្ត! បន្ទាប់ពីឪពុកខ្ញុំបាត់ខ្លួនទៅ គ្រួសាររស់នៅដោយខ្វះមុខ ខ្វះក្រោយ ដូចខ្សែដាច់ខ្សែ វិលក្លួចត្របាញ់តាមខ្យល់បក់ សំយុងក្បាលចុះក្រោម គ្មានអ្វីទប់ឡើយ ។ ម្តាយខ្ញុំ ដើរសុំបសួរគេ ក្រែងឮដំណឹងពីឪពុកខ្ញុំ សូកគេសូកឯង ក្រែងបានពត៌មាន ។

គ្រួសារក្រៀមក្រំ លែងសប្បាយ ដូចពេលមុនៗ ទៀតហើយ ។ ទឹកបឹងកាន់តែរីង លុយកាន់តែអស់ បន្តិចម្តងៗ រេចរឹលទៅៗ ។ ម៉ែម្នាក់ឯង ប្រឹងប្រែងទប់ពុំឈ្នះ ។ ស្រុកសង្គ្រាម ទំនិញឡើងថ្លៃ ជាលំដាប់ ។ ម៉ែក្តាប់គ្រួសារ លែងបាន វាសនារុញច្រាន បំបែកយើងឲ្យរស់នៅដាច់គ្នា ។ សុំបងប្អូនជ្រក ជម្រកវាសនា ។ បំណងយើងទាំងប៉ុន្មានពីមុនមករលាយខ្យុល ។ ស្រវារកបង្គោលតោង រកបង្គងទំបណ្តោះអាសន្ន ។ បន់អស់ព្រះនានា ព្រះចន្ទ ព្រះឥន្ទាព្រះធរណី ... តែគ្មានព្រះមួយណា ជួយយើងឡើយ ។ កាន់តែក្រ កាន់តែបន់ កាន់តែជឿ ។ តែព្រះហាក់ដូចជាជួយតែអ្នកមាន អ្នកដែលមិនស្មោះនឹងព្រះទេវិញ ។ អ្នកមាន កាន់តែមានទៅ អ្នកក្រ កាន់តែក្រទៅ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តើនេះមកពីជាតិមុន យើងពុំបានធ្វើបុណ្យ? អ្នកណាទៅដឹងជាតិមុន យ៉ាងណា? ធេវី នាងនឹកដល់បងប្រុសផល្លាជាកូនក្មេះ ព្រោះយើងបានផ្សងជួបគ្នាជាតិនេះ ៗ ប្រហែលជាជាតិមុនយើងធ្វើបុណ្យច្រើន ទើបបានបំណងយើងបានសំរេច ៗ តែហេតុដូចម្តេច បានជាយើងត្រូវបែកគ្នា? ៗ

ខ្ញុំមករស់នៅជាមួយម្តាយមីង មីង ភេត ឯខេត្តសៀមរាប ៗ កាលណោះមីងមានភោជនីយដ្ឋាន លក់ម្ហូបអាហារនៅជិតទីផ្សារ ៗ ខ្ញុំខិតខំផ្តាប់មីង ខិតខំរៀនធ្វើម្ហូបអាហារលុះត្រាបានស្គាត់ជំនាញ ៗ

បង ខេមរា ឧស្សាហ៍ នាំមិត្តភក្តិមកទទួលទានម្ហូបអាហារនៅភោជនីយដ្ឋានម្តាយមីងខ្ញុំ ៗ រាល់ផងគាត់រមែងសរសើរពីគុណភាពនៃម្ហូប ហើយសួររកមុខអ្នកដែលធ្វើម្ហូប ៗ

ខ្ញុំរៀនជាខ្លាំង ៗ ម្តាយមីងខ្ញុំ ពីដើមគាត់ធ្វើដោយដៃគាត់ តែក្រោយមក ដោយឃើញខ្ញុំមានថ្វីដៃ និងសមត្ថភាពគ្រប់គ្រាន់ គាត់ប្រគល់កិច្ចការនេះទុកដាក់មកលើខ្លួនខ្ញុំ ៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

មុខរបររបស់មីង រីកដុះល្បីឮរន្ទឺពេញខេត្តសៀមរាប សូម្បីតែ ជនបរទេស ក៏ស្គាល់ដែរ ។ ខ្ញុំក៏ត្រូវហាត់រៀនភាសាបរទេសទៀត ដើម្បីនិយាយទាក់ទងជាមួយភ្ញៀវ ។

នៅឱកាស ពេលសំរាកម្តងៗ ខ្ញុំអ្នកស្រុកស្រែ ដែលពុំស្គាល់អង្គរ ឧស្សាហ៍ទៅលេងអង្គរ ឈរគន់គយ គន់ហើយគន់ទៀត "អង្គរស្អីមស្អែ អ្នកល្អម៉្លេះទេ" ។ ខ្មែរមុននឹងស្លាប់ គួរតែស្គាល់អង្គរម្តង ស្នាដៃនៃបុព្វបុរសយើង។

ថ្ងៃមួយ នៅកន្លែងមួយ ដែលមានថ្មរាយប៉ាយ រាត់រាយ ខ្ញុំភ្ញាក់ព្រើត ដោយឃើញប្រាសាទមួយ ដុះជារូបរាងស្អាតប្លែក អណ្តែតផុសចេញពីដី។ ខ្ញុំឈរភ្លេចខ្លួន លួចសរសើរ ស្នាដៃស្ថាបត្យករ ដ៏ចំណាន។

ឱ! អស្ចារ្យមែន ៗ ជាស្នាដៃក្សត្រណា? ព្រះពិស្ណុការមកសង់ឬអ្វី?

រំពេចនោះ ខ្ញុំឮសម្លេង ពីក្រោយខ្នងខ្ញុំ ។ ព្រះពិស្ណុការ គឺខ្ញុំនេះឯង ។ កាលពី ១០០០ឆ្នាំមុន ខ្ញុំបានមកសង់ម្តង ហើយប្រគល់ដល់ក្សត្រខ្មែរ រួចខ្ញុំវិលហោះទៅ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

បានលើវិញ ។ តែខ្មែរបែរជាបោះបង់អង្គរ ព្រោះខ្មែរថែរក្សាការពារពុំបាន ។ ឥឡូវខ្ញុំវិលមកវិញ មកជួសជុលកែច្នៃឲ្យប្រសើរឡើង ។

ឆេទី នាងផាកវេរ រកម្ចាស់សម្ដេង!

អូហ៍ លោកទេតើ! ជំរាបសួរលោក!

ខ្ញុំសូមសរសើរ! សរសើរ ដោយខ្ពង់ខ្ពស់ ! នេះបានហៅថាអ្នកពូកែ! អ្នកមានថ្វីដៃ! អ្នកមានទេពកោសល្យ! មហាទេពកោសល្យ ។ វិះជ្រុះធ្លាក់បានស្រាក់ពីដៃ ព្រោះប្រាសាទ ស្អាតពេកក្រៃ ។

ខេមរា សួរ! នៅខ្វះពាក្យអ្វីទៀត បញ្ជោរខ្ញុំ? ប្រាសាទខ្ញុំ កសាងល្អមែន តែពុំមានឱជារស ដូចរបស់ក្នុងបានស្រាក់ នោះទេ ។ ក្លិនចេញពីបានស្រាក់ បញ្ជាក់នូវទេពកោសល្យ អ្នកធ្វើមែន ។

ទេពកោសល្យអ្វី! ទេពកោសល្យខាងស្លម្ហូប ។

ព្រះអើយ! ខ្ញុំពុំដែលឮទេ ធ្វើម្ហូបអាហារ ជាទេពកោសល្យ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅស្រុកខ្មែរ ធ្វើម្ហូបអាហារ ជាការធម្មតា នៃស្ត្រីឋានៈទាប ៗ លោកស្រី គេឥតកាន់វែក កាន់ឆ្នាំងនោះទេ ៗ

ខេមរា - អ្នកណាក៏ថាចេះធ្វើអ្វីដែរ តែធ្វើឲ្យបានឆ្ងាញ់ ពុំងាយរកបានឡើយ ៗ

តើនៅសៀមរាប មានផ្ទះលក់បាយឆ្ងាញ់ ប៉ុន្មានកន្លែង?

សូមលោក មេត្តាឈប់សរសើរ ខ្ញុំទៅ ៗ ខ្ញុំអៀនខ្លួនណាស់ៗ នៅស្រុកខ្មែរ ការស្លម្ហូបអាហារ គ្មានគុណសម្បត្តិវិសេសវិសាល ជាទេពកោសល្យឡើយ ជាកិច្ចការ ជើងឈ្នួល បាវព្រាវ តែប៉ុណ្ណោះ ៗ

ឥឡូវ សូមលោកនិទានប្រាប់ខ្ញុំម្តង ខ្ញុំចង់ដឹង ហេតុអ្វីបានជាលោកចេះសង់ប្រាសាទ កើត ៗ

មួយពាន់ឆ្នាំហើយ ដែលប្រាសាទសង់ហើយ តើលោកទៅស្រាវរក របៀបសង់ ពីណាមក? លោកសង់កើត ល្អដូចពីដើម ដូចគេជប់ ៗ តើលោក អាចជប់ព្រះបាទ ជ័យវរ្ម័នទី៧ ឲ្យព្រះអង្គរស់រានមានជីវិតបានឬទេ?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ខេមរា – ជប់ពុំបានទេ ។ អ្នកខ្លាំងពូកែនិមួយៗ កម្រនឹងកើតណាស់ ។ ព្រះពុទ្ធ សមណគោត្តម ជិត៣០០០ឆ្នាំហើយ ពុំទាន់មានកើតមួយអង្គទៀតឡើយ ។ ឯតាឥសី ក៏ដូចគ្នាដែរ យើងពុំឃើញមានកើតទៀតឡើយ ឯអាតាំងដូចរូបខ្ញុំមិនខ្វះទេ រស់សំរាប់ជាំតែជូនលោកតា តែប៉ុណ្ណោះ ។

ឯអាតាំងពៅតា លួងដូចស្វាបព្រា ពុំស្គាល់រសជាតិសម្អីឡើយ ថ្វីជ្បិតតែរស់នៅជិតអណ្តាត ។ នៅជិតលោកតា ឥតចេះជប់ ចេះបាញ់ធ្នូ ឬចេះបំបាំងកាយ ឡើយ ។

ខេមរាបន្ត! ខ្ញុំនឹងនិយាយជំរាបពីរឿងសង់ប្រាសាទបាន តែដោយរឿងវែងពេក ខ្ញុំថាសូមឆៀត ទទួលទានបាយ ជាមួយអ្នកនាងផងបានទេ ព្រោះធុំក្លិនឈ្ងុយពីកន្ទ្រក ។ ហើយទីពីរ នាងនឹងនិទានរឿងអ្នកនាងដល់ខ្ញុំវិញផង ។

ទេពីនឹកក្នុងចិត្តថា៖

បង់ជីង រឿងខ្ញុំមានប្រយោជន៍អ្វី? ខ្ញុំទេ ដែលបង់ជីង រឿងអង្គរ រូបចម្លាក់នានា ។ រឿងខ្ញុំនិងរឿងអង្គរ ឈរទន្ទឹមគ្នា ដូចមេឃនិងដី ដូចតារានិងជន្លេន ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឆទី លបសួរម្ដាយមីង តើព្រមទទួលលោក ខេមរា ឲ្យទទួលទានបាយ ជាមួយបានទេ។

មីង អេះអុញ! តែចិត្តរីករាយ និយាយថា៖

ស្រេចតែលោកទេ ។ ខ្ញុំខ្មាសអៀនណាស់ ព្រោះគ្មានអ្វីជាល្អឆ្ងាញ់ពិសាឡើយ។ ខ្ញុំពុំយល់ទាស់ទេ តែសូមលោកកុំប្រកាន់ ។

ម្ដាយ មីងនាង ឆទី មីងគេត សួរទៅលោក ខេមរា ថា៖

លោក! ប៉ុន្មានខែនេះ ខ្ញុំឃើញលោកអញ្ជើញ មកភោជនិយដ្ឋានខ្ញុំ មានមិត្តភ័ក្តិតិចជាងមុន ។

ពីដើមមានប្រុស មានស្រីបរទេសច្រើន ឯទឹកមុខលោកដូចជា ស្រងូតជាងមុន ។

ខេមរា ឆ្លើយ ! នេះជាការសំងាត់តែខ្ញុំជំរាប ជូនមីងចុះ ។ យើងខ្ញុំបានទទួល ការគម្រាមកំហែង ពីខ្មែរក្រហម គេមានចេតនា សម្លាប់យើងខ្ញុំចោល ។

បារាំង ដែលជាអ្នកបច្ចេកទេស ជួយសង់អគ្គារ និងត្រឡប់ទៅស្រុកគេវិញ អស់ហើយ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តើឲ្យខ្ញុំសំរេចចិត្ត យ៉ាងណា?

ខ្ញុំជាតិខ្មែរ ឈាមខ្មែរ អក្សរជារបស់ខ្មែរ ។ ដូនតាយើងកសាង ។ ខ្មែរបោះបង់អក្សរចោលទៀត ។ កូនជាងខ្លះបោះបង់ការងារចោល ព្រោះខ្លាចខ្មែរក្រហម ។ តើអ្នកជួសជុលអក្សរ មានកំហុសអ៊ីដែរ ជាជនក្បត់ជាតិដែរ!

អក្សរល្អឆើតឆាយ ល្អពណ្ណរាយ លើភពផែនដី ។ សាកលលោក ទាំងមូល ទទួលស្គាល់ថាជាស្នាដៃ មួយដ៏ល្អក្នុងចំណោមវត្ថុដ៏ល្អនានា ។

អក្សរឥតមានច្រើនយោបាយ អក្សរឥតចូលបក្សពួកណាម្តងឡើយ ក៏មានមនុស្ស ខ្លះយកបាយមក លាបមាត់ពពែទៀត? យកពណ៌មកលាបអក្សរឲ្យក្រហម ។

ឪពុកបិញ្ចឹមខ្ញុំ ប្រូច់សំរ ជាជាតិបារាំង ត្រូវរដ្ឋាភិបាលបារាំងបង្ខំឲ្យវិលត្រឡប់ទៅស្រុកវិញ ព្រោះស្រុកខ្មែរកើតអាសន្ន កើតចម្បាំង ខ្លាចមានគ្រោះថ្នាក់ទៅថ្ងៃក្រោយ ។ ខ្ញុំជាខ្មែរ ខ្ញុំនឹងនៅក្រាញ ការពារផលប្រយោជន៍ខ្មែរ ។ ដរាបណា ខ្ញុំមានឱកាស ខ្ញុំធ្វើតែអំពើល្អដល់ជាតិខ្ញុំ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ស្តាប់សម្តីទាំងនោះ ឆេទី នាងនឹកក្នុងចិត្តថា៖ បុរសនេះ មានចរិតខ្ពស់ សម្តីពីរោះ គួរស្រឡាញ់រាប់អាន ។ មិនថាឡើយ តែបាយកញ្ចប់ បើលោកចង់ទទួលទានបានស្រាក់ក៏ខ្ញុំមិនថាអ្វីដែរ។

មីងគេតនិយាយ! លោកខេមរា លោកជួសជុលប្រាសាទស្អាតល្អ តម្រូវចិត្តព្រះជាម្ចាស់ តែលោកពុំអាចតម្រូវចិត្តមនុស្សលោកបានឡើយ។

ទោះជាធ្វើល្អ យ៉ាងណា ក៏នៅតែមានមនុស្ស មិនសប្បាយចិត្ត ។

ក្នុងជីវិត ចៀសមិនផុតទេ ធាតុជូរចត់ល្វីង ។ សូម្បីតែព្រះវេស្សន្តរ ជួបតាជូជក់ ធ្វើបាបកូន អ្នកស្រុកត្មះតិះដៀល... ជេញចំបរបង់ ។ល។

ដល់ពេលបានត្រាស់ហើយ ព្រះពុទ្ធជួបនឹងទេវទត្ត ជួបមារសត្រូវទៀត ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែក្នុងជីវិត ការសំខាន់ គឺមធ្យោបាយដោះស្រាយ រកច្រកចេញ ។ ការដែលយើងស្គាល់ នូវមធ្យោបាយច្រើន អាចជួយដល់ការរស់នៅ របស់យើង ។

មីងគេត សង្កេតឃើញថា ខេមរា ប្រហែលជាចាប់ចិត្តស្នេហាលើ ឆេទី មិនយកលេស ប្រញាប់ប្រញាល់ វិលមកសៀមរាបវិញ ទុកឲ្យអ្នកទាំងពីរ នៅសាសង ផ្ដោះផ្ដងសំណេះសំណាលគ្នា ។

ពន្លកស្នេហ៍ ចាប់ដុះត្រួយ ដូចទឹកសន្សើម និងរបះព្រៃក្នុងបុរីអង្គរ ។

ចាប់ពីថ្ងៃនោះមក អ្នកទាំងពីរ កាន់តែស្និទ្ធស្នាល និងគ្នាទ្វេឡើង ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ឫសរុក្ខាឱបរឹតផ្ទាំងសិលា

# ស្នេហាមហារឹងមាំ

៚៚៚

(សូមអានកំណាព្យប្រាសាទតាព្រហ្ម នៅទំព័រឧបសម្ពន្ធ)

អ្នកទាំងពីរ រមែងណាត់ជួបគ្នា ក្នុងបុរីមហានគរ ប្រាសាទព្រះខ័ន បាយ័ន ភ្នំក្រោម បារាយណ៍ទឹកថ្លា ប្រាសាទតាព្រហ្ម ។ល។ និង ។ល។

គូទាំងពីរ ដើរត្រសង ផ្ដោះផ្ដង ពាក្យស្នេហា ក្រោមព្រឹក្សាធំៗ រងំដោយសម្លេងរៃយំ ។

បង! ហេតុអ្វី បានជាស្នាដៃដ៏ល្អ ត្រូវខ្មែរបោះបង់ចោល ដោយគ្មានស្រណោះ? សូម្បីតែរៃ ក៏នៅតែយំស្រណោះ អន្ទរ ពេលមុនថ្ងៃលិច ។

ខេមរា-ព្រះរាជាជំនាន់នោះ ខិតខំកសាងប្រទេស កសាងស្រុក ឲ្យល្អលើសគេ ឲ្យល្អប្រណីតជាឋាន តុះសិត ឋានសួគ៌ សំរាប់មនុស្សផង និងសំរាប់អាទិទេពផងដែរ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

"យើងធ្វើយ៉ាងណា ឱ្យអង្គរ ក្លាយជាកន្លែង ដ៏ល្អ លើសគេ នាលោកា ។ ព្រះ អាទិទេពទាំងឡាយ ទោះជានៅទីជិតក្តី ទីឆ្ងាយក្តី សូមព្រះអង្គយាងមកស្ថិតនៅក្នុងបុរីអង្គរ" ។

កាលយប់ថ្ងៃ សម្លេងតន្ត្រី លេងប្រគំ រណ្តំ បំពេអារម្មណ៍ ជល់ព្រះជាម្ចាស់ ។ កិន្នរ វេរាំក្បាច់ បាចផ្កាគោរពព្រះចេស្តា ។

ឆេទី! អូនក្រឡេក មើលខាងស្តាំ មើល! អូនមានឃើញអ្វីទេ?

អូនឃើញ ដើមឈើ ដ៏ធំដុះលើផ្ទាំងសិលាឬទេ?

ចាស៎! បង ឃើញហើយ ។

របស់ពីរ ដែលយើងស្មានថាគ្មានព្រលឹង តែគេចេះស្នេហាគ្នា ។ ឫសរុក្ខា ឱបត្រកងស្នេហា និងផ្ទាំងសិលារឹតរឹងមាំ រស់រួមរ៉ាសនាជាមួយគ្នា ទោះភ្លៀង ទោះផ្គររុក្ខាឈរគ្របសិលា មិនឲ្យទទឹកបាន ។ ពេលព្យុះព្យាមាសិលាខំពុះពារ មិនឲ្យរុក្ខារលំបាន ។ ម្នាក់ៗមានករណីយកិច្ចរៀងខ្លួន តែគេសាមគ្គី កសាងជីវិតរួម ។

សំណាបយោងដី ស្រីយោងប្រុស ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ដើរ កាន់ដៃគ្នា នៅក្នុងព្រៃមណីក្សេមក្សាន្ត ខេមរា សូត្ររហឹម កំណាព្យ ដែលខ្លួនបានចងចាំ ស្តីពី ប្រាសាទ តាព្រហ្ម មានដូចតទៅ៖

តាព្រហ្មយំយែកស្រែក ផ្ដែផ្ដាំចៅ

ផ្ដែផ្ដាំចាមឈប់ទៅវើឆានខ្មែរ!

វើឆានខ្លាំងប្រឆាំងនឹងជាតិគេ

នឹងជាតិគាត់ស្បថស្បែថៃសង្គ្រាម!

...

នៅខាងឆ្វេងដៃ មានរូបព្រះពុទ្ធបដិមាករ មួយអង្គ អង្គុយពែនភ្នែន លើពស់ឆ្វាយរង្វេល ។ ទឹកមុខញញឹម សំឡឹងមើលយើងទាំងពីរ ។

ខេមរា កេះឆេរី បង្អុលទៅព្រះពុទ្ធរូប ។

ព្រះអង្គ លោកទត់មើលយើង ទាំងពីរនាក់ ។ ឆេរី មើលទៅព្រះបដិមាករ ឃើញដូចជាព្រះអង្គ សំឡឹងមើលមែន ។ ព្រះអង្គញញឹមៗ ដូចជាសប្បាយព្រះហឫទ័យ ។

ឆេរី លុតជង្គង់ ថ្វាយបង្គំព្រះជ័មានឫទ្ធិ ។ នាងនិយាយខ្សឹបខ្សៀវ បន់បួងសួង ។ ឯ ខេមរា ក៏ធ្វើដូចគ្នា ។

www.facebook.com/7khmer

Fb page : Entertainment And Knowledge

ខេមរា សួរទៅឆេទី។ អូនចង់ដឹងបងបន់រឿងអ្វីទេ?

-ចា៎ះ! ចង់ដឹង។

-ចង់ដឹងមែន! ខ្ញុំបន់ថា...បន់ថា...

-បន់ថាយ៉ាងម៉េច? ឆេទីនាងសួរ!

-ថាឲ្យជួបតែទេវី ពីជាតិនេះតទៅ។

នាងអៀនមុខក្រហមព្រឿងៗ។

ខេមរា បន្ត! ព្រះពុទ្ធអង្គនេះបានមកពន្យល់សប្តិខ្ញុំ ថាព្រះអង្គត្រូវព្រះរាជាជំនាន់មុនលាក់ទុកក្នុងរូងឈើ កុំឲ្យសៀមលួចយកទៅបាន។

ខ្ញុំទៅរកឃើញ រួចកសាងបល្ល័ង្កថ្វាយ។ ព្រះអង្គបានប្រាប់ខ្ញុំថា បើត្រូវចិត្តលើនាងណា សុំបោះទូលមកចុះព្រះអង្គនឹងជួយ ឲ្យបានសំរេច។ ព្រះអង្គអើយ ខ្ញុំព្រះករុណា បានរកឃើញហើយ។

ឆេទី និយាយសើចលេង។

ខ្ញុំពុំសុខចិត្តទេ ព្រះអង្គឥតសួរចិត្តខ្ញុំសោះ។ ព្រះអង្គទទួលសំណូកបងខេមរា។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ខេមរា បើព្រះអង្គ ពុំព្រមជួយខ្ញុំទេ ខ្ញុំពុំព្រមសង់ប្រាសាទថ្វាយទេ ។

ធេវី នាងក្រឡេកមើលមុខខេមរា ដោយស្រឡាញ់នឹងសម្តី ស្រឡាញ់នឹងពាក្យពិត ដែលចេញពីបេះដូងបុរស។

អ៊ីៗ ដែលចេញពីក្នុងខ្លួនខេមរា មានសញ្ញាច្បាស់ៗ មិនស្រពិចស្រពិល ឬបន្ទំបោកនោះឡើយ ។

នៅចំពោះមុខ មនុស្សត្រង់ ធេវីនាងត្រូវតែនិយាយត្រង់ទៅវិញដែរ ថ្វីត្បិតតែជាស្ត្រីភេទ ថ្វីត្បិតតែការអប់រំនារីខ្មែរកុំឲ្យសំរេចចិត្តដោយខ្លួនឯង "ត្រូវសួរចិត្តម្តាយ" ។

ពេលនេះ ធេវី ហាក់ដូចជាមានសេចក្តីក្លាហាន ហ៊ានសំរេចវាសនាដោយខ្លួនឯង។

បង ខេមរា ! បារមីព្រះជាម្ចាស់ធ្វើឲ្យបេះដូង អូនញ័រខុសពីធម្មតា។ បងអើយ! អូនទន់ជើងទន់ដៃអស់រលីង។

ឱព្រះជាម្ចាស់អើយ! នាងខ្ញុំចុះចាញ់បារមី ព្រះអង្គហើយ ។ នាងខ្ញុំនឹងគោរពទទួលស្នេហ៍ដ៏ឧត្តុង្គឧត្តម ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

**ខេមរា** យកនាសា ក្រេបក្លិន សក់**ឆៃទី** ។ ក្លិនឆោមនារី មានរសជាតិ ជាងក្លិនអ្វីទាំងអស់ ។ រូបអ្នកទាំងពីរ កាន់ដៃគ្នា នាំឡើងទៅលើ កំពូលប្រាសាទ កំពូលដ៏ខ្ពស់ជាងគេបង្អស់ ។

ខាងលើយើង ស្ទើរយកដៃចាប់ពពកលេង ។

**ឆៃទី** មាសបង! ពេលនេះយើងនៅខ្ពស់ ហួសពីគេ ខ្ពស់ហួសនិស្ស័យ នៅចន្លោះមេឃនិងដី ។ ពេលណាមួយត្រូវតែចុះមិនខាន ត្រូវប្រុងប្រៀបរៀបរកផ្លូវចុះឲ្យស្រួល កុំឲ្យជួលបែកមុខ ។

ខាងក្រោមអ្វីក៏តូចទាប ។ ទោះជាដីទួល មើលឃើញដូចរាបស្មើ ទាំងអស់ ។

អូនមើលដុំពពក ដុំធំៗ រូបបែកខ្ញែក ជាដុំតូចៗ ដោយខ្យល់ផ្លុំបំបែក ។

ខ្យល់ ជាបច្ចាមិត្តផ្តុំ ព្រោះឲ្យបែកជាដុំតូចៗ ។ ខ្យល់ចេញពីមាត់មនុស្សក៏មានអានុភាពខ្លាំងក្លាណាស់ដែរ អាចបំបែកសាមគ្គីភាពយើងបាន ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាប់មកមេឃខ្មៅមីរ រក់ភ្លៀង ៗ សម្លេងក្តុងៗពីបម្ងាយ ៗ

-បង! សម្លេងផ្គរឬ?

-មិនមែនទេ! មាសបង

-នេះជាសម្រែកសង្គ្រាម! សម្លេងកាណុងបាញ់ផ្ទោង បំផ្លាញក្រុង បំផ្លាញជីវិតមនុស្សនានា ៗ ទិសដៅរបស់គេ គឺសំដៅទៅយកអំណាច នៅក្រុងភ្នំពេញ ៗ តែមុននឹងទៅដល់ភ្នំពេញ គេត្រូវកំទេចឲ្យអស់ជននានា រួចភូមិស្រុក រួចខេត្តនានា ៗ កំទេចឲ្យអស់ផ្ទះអ្នកក្រ ដុតភូមិឋាន ភូមិគ្រឹះ ព្រោះតែចង់បានអំណាច ៗ នៅស្រុកគេ ក៏ដូច្នោះដែរ កាលពីជំនាន់ដើម ៗ តែដល់ឥឡូវ ដើម្បីចៀសវាងកុំឲ្យមានសង្គ្រាម បំផ្លាញទ្រព្យសម្បត្តិ អ្នកស្រុកដែលគ្មានទាក់ទាមរឿងនេះ គេបង្កើតឲ្យមានការបោះឆ្នោតឡើង ៗ

អូនសម្លាញ់បងអើយ! សង្គ្រាមនៅមិនឆ្ងាយពីអង្គរទេ ៗ សង្គ្រាមនឹងរាលដាល មកដល់អង្គរ ថ្ងៃណាមួយមិនខាន ៗ ដីខ្មែរនឹងប្រឡាក់ ដោយឈាមខ្មែរ ៗ ដីខ្មែរនឹង



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្រោចស្រព ដោយទឹកភ្នែករាស្ត្រប្រជា វេទនារកទីបំផុតគ្មាន ។

កិនរំសេវ កិនឈាម ទាមទារ ទាញវាសនាខ្មែរ ឲ្យរអិល បន្តិចម្ដង ៗ ធ្លាក់ក្នុងរណ្ដៅអវិចី ផុតសាសន៍ឯង បំផ្លាញផ្ទះសម្បែងឲ្យខ្ទេចជាផេះ ។

គ្មានអ្វីឃាត់ឃាំងបានឡើយ ព្រោះយើង គ្មានផ្លូវណាឲ្យប្រសើរជាជាងសម្លាប់គ្នា ដើម្បីអំណាច ។ នេះជាកម្មយើងទាំងអស់គ្នា?

នៅស្រុកគេ ដើម្បីចៀសវាង កាប់សម្លាប់គ្នា គេធ្វើការបោះឆ្នោត រើសយកអ្នកខ្លាំងពូកែ អ្នកដែលមានសមត្ថភាពជាងគេ ដោះដូរផ្លាស់គ្នា ទៅតាមកាលៈទេសៈ ។

ការដែល ដណ្ដើមអំណាច ដោយ កម្លាំង បាយ កម្លាំងអាវុធ ពុំអាចឲ្យគេកាន់អំណាច យូរបានឡើយ ។ ហើយដល់ពេលធ្លាក់ ត្រូវក្សិណក្ស័យ របស់ទ្រព្យត្រូវគេរឹបយក ប្រពន្ធកូនត្រូវគេធ្វើបាប... ឈាមសងឈាម គំនុំសងគំនុំ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

បងអើយ! អូនភ័យព្រួយ ភ័យខ្លាច និងរងា កំព្រាចិត្តពន់ពេក ។

ទឹកភ្នែកនេះ ហូរធ្លាក់ លើថ្ពាល់ជំជូរជន់ ។

តើអូនមានរឿងអ្វី ធ្ងន់ក្នុងចិត្ត បានជាទឹកភ្នែក ស្រក់ហូរច្រើនម៉្លេះ?

បងអើយ! អតីតកាល ណែនណាន់ តាន់តាប់ នៅក្នុងបេះដូងអូន ៗ អូនចង់និទានរឿងអូន ឲ្យបងស្តាប់ មិនចាំបាច់បងជណ្តឹងសួរ ទាន់ឡើយ ។ តែរាល់ដង យើងខ្វះឱកាសល្អ ។ ណាមួយ អូនអៀនខ្មាស ហាក់ដូចជាហែកទ្រូងឯង ។ តែអូនចង់ឲ្យ បង ស្គាល់ច្បាស់ នូវរឿងរ៉ាវ របស់អូន ចង់ឲ្យ បងស្គាល់ច្បាស់ពីអូន មុននឹងសំរេចចិត្ត កុំឲ្យស្តាយក្រោយ ។ ការខ្វះខាតរមែងតែមាន តែយើងជួយបង្រួបគ្នា កាន់ដៃគ្នាទៅរកអនាគតភ្លឺស្វាង ។ អូនមិនមែនជាកូនគហបតី របស់អ្វី មានប្រើ មិនខ្វះនោះទេ ។ អូនមិនមែនជាអ្នកធេតធាយសប្បាយ រាល់រាត្រី សប្បាយនឹងពន្លឺពេជ្រនឹងពន្លឺអគ្គិសនី ។ អូនធ្វើការ ហត់នឿយណាស់បងអើយ!



www.facebook.com/7khmer
Fb page : Entertainment And Knowledge

អូនស្គាល់ថ្លៃប្រាក់រៀល ទំរាំបានមួយរៀលៗ ត្រូវប្រឹងប្រែង ប្រឹងញញឹមទទួលភ្ញៀវ ពីព្រលឹមទល់ព្រលប់ ។ ញញឹមរហូត ដល់អ្នកខ្លះថា អូនប្រហែលជា មិនដែលកើតទុក្ខទេឬ?

ខេមរា ផ្ទេកក្បាលលើស្មាខេធី រួចបិទភ្នែក គ្មានគិតអ្វីទាំងអស់ ។ នាយបីតជកស្រូបក្លិនសក់ស្រស់ស្រី ក្រអូបឈ្ងួលហឫទ័យ សាច់សល្អខ្ចី គួរឲ្យបេតី ហួសប្រមាណ ។ ខ្យល់ត្រសៀកបក់សក់ស្រស់ស្រី ក្រោមលើភក្ត្រា ខេមរា ។

នេះហើយ ដែលគេហៅថា សុភមង្គល។ គ្មានឋានសួគ៌ឯណាទៀតទេ ។

សង្គ្រាម ហាក់ដូចជានៅឆ្ងាយ ។ យើងភ្លេចនូវទុក្ខសោកទាំងពួង។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ជន្ទល់រលំ ជីវិតរលាយ

៙៙៙៙

ទឹកភ្នែករហាម លើថ្ពាល់ស្រស់បំព្រង ឆេទី ខំប្រមូលកម្លាំងស្មារតី និទានរឿងរបស់ខ្លួន ។

ពុកខ្ញុំ ធ្វើជាទាហាន ក្នុងកងទ័ពខេមរភូមិន្ទ មានពាក់សញ្ញា រូបហនុមាន បានសេចក្ដីថា ក្លាហាន ចិត្តស្មោះបំពោះជាតិ សាសនា ព្រះមហាក្សត្រ ។

នៅផ្ទះខ្ញុំ មានព្រះពុទ្ធរូប កន្សែងយន្ត ខ្សែបង្កេះ បន្ទុមខ្លា ខ្នាយតាន់ ប្រទាលផ្សេងៗ ជួយថែរក្សា ការពារជីវិត ការពារសត្រូវ គ្រប់ប្រភេទ កុំឲ្យមកបៀតបៀនបានឡើយ ។

រាល់ថ្ងៃសីល ពុកតែងស្លៀកស ពាក់ស អង្គុយបត់ជើង សូត្រធម្ម ៗ ជាកិរិយា ផ្ទុកពីទាហានជំនាន់នោះ ដែលខ្វះឱបជបស្រា និងស្រីបារ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពុកបានរួមធ្វើចំបាំងជាច្រើន តាំងពីទាមទារឯករាជ្យ រហូតបានជោគជ័យ ពីបារាំង ។ រួចមក ពេលដែលបាន ឯករាជ្យហើយ យួនពុំព្រមដកទ័ពចេញពីក្របេះ ស្ទឹងត្រែង ស្រែជេស ។ល។

ពុកដង្ហែ ព្រះមហាក្សត្រធ្វើបូជនីយកិច្ចដេញយួន អស់ពីទឹកដីយើង ។ អស់ពីយួន សៀមចូលមកយកព្រះវិហារទៀត ។ ពុកត្រៀមបាំ តទល់ទ័ពសៀមទៀត ការពារទឹកដីខ្មែរ ។ រាល់ថ្ងៃពុក អង់អាចក្លាហាន ទាញកន្សែងយន្តរុំក លោតលើឡានហ្ស៊ីប សំដៅសមរភូមិ ។ ភ័ក្ត្រញញឹមសង្ឃឹមលើជ័យជំនះ គ្រវីដៃលា ម៉ែ និងកូនទៅការពារមាតុភូមិ ។

លើខ្លួនពុកមានស្នាកស្នាមរបួស ។ ស្នាក និមួយៗ ជារឿងសង្គ្រាម រវាងខ្មែរនិងប្រទេសជិតខាង ។

រាល់ថ្ងៃ ដែលពុក ទៅច្បាំង ខ្ញុំ និង ម៉ែ និង ប្អូន រស់នៅដោយក្រៀមក្រំ ។ លែងសើច លែងក្អាកក្អាយ ដូចពេលមុនទៀតហើយ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

រង់ចាំ ! រង់ចាំពុកមកវិញ !

បាត់ដំណឹងយូរ ! ខ្ញុំយករូបថត ពុកមកដេកឱប ៗ ពុកស្រឡាញ់លុយ? ស្រឡាញ់គ្រួសារ ឬស្រឡាញ់ជាតិ?

ថ្ងៃមួយ មុនរដ្ឋប្រហារបន្តិច ពុកបាននិយាយទៅកាន់ម៉ែថា៖

ខ្ញុំអាច ច្បាំងនឹងខ្មាំងបរទេស ការពារ ទឹកដីខ្មែរបាន តែឲ្យខ្ញុំសម្លាប់ខ្មែរ ខ្ញុំធ្វើមិនរួចឡើយ ។ ណាមួយ ខ្ញុំបានផឹកទឹកសម្បថទៀតផង ។ ប្រហែលជាពុកមានលេចឮថា ទាហានប្រុងក្បត់យកអំណាចក៏មិនដឹង ។

តែពុកឥតមាននិយាយអ្វីឲ្យហួសពីនេះទៀតឡើយ ។

ខេមរា បន្ថែម! អ្នកដែលផឹកទឹកសម្បថហើយក្បត់ អ្នកនោះប្រព្រឹត្តនូវកំហុសត្រួតគ្នា ។

ថ្ងៃមួយ ពុកទឹកមុខស្រងូត ខុសពីធម្មតា ។ ពុកទាញកាំភ្លើងខ្លីមកសៀតបង្កេះ រួចឱបលាម៉ែជាចុងក្រោយ ។ ប្អូនខ្ញុំផ្សេងទៀត ឱបជើងឪពុក ដោយគ្នានៅក្មេងពេក ខ្លះផ្តាំឲ្យខ្ញុំទិញនំផ្ញើវាផង ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ក្រោយពីពុកបាត់ខ្លួនមក ម្ដាយខ្ញុំបាប់ឈឺ ខិន ធ្វើការពុំរួច ។

ឆេទី នាងយំ! ខ្ញុំធំជាងគេ ខំប្រឹងជ្រោលទូលគ្រួសារ ។

បងអើយ! ខ្លួនទៅក្មេងពេក ពុំសូវយល់ការរស់នៅ ពុំដឹងបញ្ហាគ្រួសារ ពុំដឹងភារៈឪពុកម្ដាយ ។ គ្រួសារខ្ញុំរលំ ។ បងប្អូន បែកខ្ញែកគ្នា ទៅរស់នៅផ្ទះមីងមា ។ គេជួយយករក្សាចិញ្ចឹម ។

ឆេទី បន្ត! បងអើយ! អូនអភ័ព្វណាស់ ។ សង្គ្រាមទាមទារ ឈាមគ្រួសារអូន បន្ទាប់ពីឪពុក ឥឡូវ ឪពុកមាទៀតហើយ ។ ប្ដី មីងខ្ញុំ បាត់ខ្លួនទៅ សមរភូមិ ឧត្តរមានជ័យ ក្នុងពេលថ្មីៗនេះ ។

មីងតែលគោល ឥតមានកម្លាំងកំហែង នឹងប្រឹងរកស៊ីតទៅទៀតទេ ។ គាត់បាន លក់ភោជនីយដ្ឋានទៅ ឲ្យគេហើយ ។

ជីវិតខ្ញុំ មិនដឹងជាយ៉ាងណាទេ?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឱសង្គ្រាម! អ្នកបឺតស្រូបឈាមខ្មែរ ៗ អ្នកផ្ដាច់ព្រលឹងជីវិតមនុស្ស ដែលខ្ញុំស្រឡាញ់ៗ អ្នកសាហាវណាស់! អ្នកគ្មានធម៌មេត្តា! មិនគ្រាន់តែផ្ដាច់ជីវិតមនុស្ស ដូចយមបាល អ្នកបំផ្លាញ ផ្ទះសម្បែង បំផ្លាញ ភូមិដ្ឋាន របស់របរ ឲ្យមនុស្សធ្លាក់ខ្លួន ចុះក្រ ឲ្យប្រទេស ហិនហោច ខ្លោចផ្សា វេទនា ៗ

តើត្រូវតែធ្វើសង្គ្រាម ចៀសមិនរួច? គ្មានមធ្យោបាយណា ក្រៅពីសម្លាប់ ស៊ីសាច់ហុតឈាមគ្នា? សង្គ្រាមមិនផ្អែតផ្អន់ តើអ្នកណាបានចំណេញច្រើនជាងគេ ពេលមានសង្គ្រាមម្ដងៗ? ខ្មែរជឿព្រះពុទ្ធសាសនា ពុំហ៊ានសម្លាប់សត្វទេ តែខ្មែរសម្លាប់គ្នាឯង ស្លាប់ច្រើនជាងបរទេសសម្លាប់ទៅទៀត ៗ

នៅឯនាយជើងមេឃឆ្ងាយ ស្នូរកាំភ្លើង ឮសន្ធាប់ ៗ ខ្មែរថ្វែងសរសម្លាប់ខ្មែរ ៗ ក្នុងមួយជំនាន់ៗ ខ្មែរស្គាល់តែទឹកភ្នែក ព្រាត់ប្រាសគ្នា ៗ ម្ដងនេះ មិនដូចពេលមុនខ្មែរនិងសៀមនោះទេ តែខ្មែរនិងខ្មែរ ៗ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# សង្គ្រាម
# រវាងខ្មែរនិងសៀម

ឆេទី សួរ ! ហេតុដូចម្ដេចបានជាខ្មែរចុះថយ បន្ទាប់ពីអង្គរមក?

ខេមរា- មិនមែនមកពីអង្គរទេ ។ ខ្លះថាខ្មែរបាក់កម្លាំងមកពីសង់អង្គរ? តើប្រទេសចាម មានសង់អង្គរទេ បានជាបាត់រូបពីលើផែនទី?

នាជំនាន់ដើម ប្រទេសដែលអាចយកជ័យជំនះ លើសត្រូវបាន ត្រូវប្រកបនូវកត្តាបីយ៉ាង៖

-ព្រះអាទិទេពឱ្យឈ្នះទើបឈ្នះបាន

-គុណសម្បត្តិនិងគុណធម៌នៃមេទ័ព

-ប្រជាជនគាំទ្រ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ព្រះបាទត្រសក់ផ្អែម និងក្សត្រតៗមក ខ្វះនូវវិជ្ជា មេទ័ព មិនមែន ជាមេទ័ព និងមិនមែន ជាអាទិទេព មកចាប់បដិសន្ធិ ធ្វើឲ្យខ្មែរ ខ្វះនូវជំនឿ លើមេរបស់ខ្លួន ។

ខេមរា បន្ត!

ស្តេចសៀមនីមួយៗ សុទ្ធតែជាព្រះអាទិទេព មកចាប់បដិសន្ធិ ។

-ស្តេចត្រៃលោកៈ អាទិទេព ១១ អង្គ មកចាប់បដិសន្ធិ កើតជា ត្រៃលោក មួយអង្គឯងៈ ព្រះព្រហ្ម ព្រះនរាយ ព្រះវិស្ណុ ព្រះឥន្ទ្រ ព្រះពិរុណ ព្រះវាយោ ព្រះអគ្គិ ព្រះអាទិត្យ និងព្រះចន្ទ្រ ។

ព្រះឥន្ទ្រធិរាជា (១៣៧០-១៣៨៧) ព្រះឥន្ទ្រ មកចាប់បដិសន្ធិ ។

ព្រះរាមាសាន់ (១៣៨៨-១៣៩៥) ព្រះរាម មកចាប់បដិសន្ធិ ។

ប្រទេសសៀមពីដើម ឈ្មោះថាណងចៅ ។ នៅឆ្នាំ ១៦៥៣ ទ័ពម៉ុងហ្គោល វាតត្បាតប្រទេសចិន និងរាជា



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ណាបក្រណាន់ទៅ ដេញជំរុញសៀម ឲ្យរត់ចុះមកខាងត្បូង (ខាងប្រទេសខ្មែរ) ។ កាលណោះយុទ្ធសាស្ត្រ ម៉ុងហ្គោលមានប្រសិទ្ធិភាពណាស់ ច្បាំងឈ្នះប្រទេសនានា រាយផ្សាយរហូតដល់អឺរ៉ុប ដោយប្រើទ័ពសេះយ៉ាងលឿនរហ័ស ។

ទ័ពសៀម ដែលធ្លាប់ប៉ះទង្គិចនឹងទ័ពម៉ុងហ្គោល មានការពិសោធន៍ និងស្គាល់នូវយុទ្ធសាស្ត្រថ្មីៗ របៀបប្រើសេះក្នុងសង្គ្រាម ។

ខ្មែរនៅប្រើយុទ្ធសាស្ត្រ តាមរបៀបឥណ្ឌៀ ប្រើកងថ្មើរជើងច្រើន និងដំរីជាជំនួយ ។

របៀបរៀបទ័ព រៀបក្បួនព្យុហយាត្រា ប្រើពេលច្រើន ។ ឯដំរីទៀត មានគុណវិបត្តិខ្លាំង ដោយដំរីខ្លាចភ្លើង។ ពេលឃើញភ្លើង ដំរីបត់ក្បាលរត់ជាន់ទ័ពខ្លួនឯង ។ ហេតុដូចនេះហើយ បានជាយើងឃើញនៅអឺរ៉ុប ពុំមានប្រើដំរី ក្នុងសង្គ្រាមឡើយ ។ គេបានដឹកនាំដំរី យកមកពិសោធ តែពុំមានប្រសិទ្ធិភាព ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទ័ពសេះលឿនជាងដំរី បាញ់ព្រាវៗ រួចជិះផាយយ៉ាងលឿន គេចបាត់ ។

មិនតែប៉ុណ្ណោះ សៀមមានគំរោងយូរអង្វែង ផែនការវាយយកស្រុកខ្មែរ ។ គេកសាងក្រុងនីមួយៗ សមស្របទៅតាមផែនការសង្គ្រាម ។ ពីទីក្រុងមួយ ទៅក្រុងមួយទៀត មិនត្រូវមាន ចម្ងាយលើពី ២ ថ្ងៃ បើគេធ្វើដំណើរតាមជើង ។ នេះសំរាប់ឲ្យកងទ័ពបានសំរាក មុននឹងធ្វើដំណើរតទៅមុខទៀត ។

មិនតែប៉ុណ្ណោះ សៀមប្រើល្បិច បំបាក់ស្មារតីខ្មែរឲ្យជឿថា អង្គរជាក្រោលគោព្រះឥន្ទ្រ ។ ដោយស្តេចសៀមព្រះឥន្ទ្រាធិរាជា ជាព្រះឥន្ទ្រមកចាប់កំណើត ឯខ្មែរជាអ្នកបាំបំការត្រសក់ ខុសគ្នាមេឃនិងដី ។ ធ្វើម្តេចឡើយនឹងលើកកាំបិត តតាំងប្រឆាំងនិងព្រះឥន្ទ្រឈ្នះ ។ បាញ់នោះហៅមិនឮ !

ព្រះបាទត្រសក់ផ្អែម អ្នកបាំបំការត្រសក់ និងយាមក្រោលគោឲ្យស្តេចសៀម នេះបើបង្រួមសេចក្តីមក ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅឆ្នាំ១២៨២ ស្តេចសៀមឈ្មោះ ភាមាកំហែង បានទៅចងមិត្តភាពជាមួយស្តេចចិន ។

រួចមក ភាមា កំហែង បានជួបជាមួយ ព្រះមហា ខាន់គូប៊ីឡៃ (ស្តេចម៉ុងហ្គោល) នាឆ្នាំ១២៩៤ ហើយឆ្នាំ១៣០០ ភាមាកំហែង បានវិលទៅម្តងទៀត ទៅជួបអធិរាជប្រទេសចិន ។

នៅឆ្នាំ១២៣៨ មេទ័ពសៀម២នាក់ (ប្រាបួន និងបងឃ្លាំងតៅ) ចុះសន្ធិសញ្ញា ជាបក្សសម្ព័ន្ធនឹងគ្នា ដេញខ្មែរចេញពីសុខោទ័យ ។

ក្រោយមក បងឃ្លាំងតៅ ឡើងសោយរាជ ដោយយកឈ្មោះថា ព្រះបាទស្រីឥន្ទ្រឌិត ហើយចាប់ដេញខ្មែរ និងមនចេញពីដីសៀម ។

នៅឆ្នាំ១២៨៧ ស្តេចសៀម បីអង្គ ចុះសន្ធិសញ្ញា ជាបក្សសម្ព័ន្ធនឹងគ្នា ៖

-ភាមាកំហែង ស្តេចសុខោទ័យ ជាកូនឃ្លាំងតៅ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

-ម៉ានវ៉ៃ ស្តេចនៅឈៀនវ៉ៃ

-ង៉ុំបួន ស្តេចនៅផាយ៉ៅ

ព្រះបាទរាមាកំហែង បានរើខ្លួនពីក្រោមការត្រួតត្រានៃប្រទេសខ្មែរ ។

យើងឃើញហើយ រាមាកំហែង បានធ្វើដំណើរ ទៅប្រទេសចិន ទៅជួបព្រះខាន់គូប៊ីឡៃ ទៅរៀន ទៅមើលរបៀបរបបស្រុកគេ ។

ការបេះជីងទាំងនេះ ជាកត្តាមួយធ្វើឲ្យប្រទេសសៀមមានប្រៀបមកលើប្រទេសខ្មែរ ។

ម្រួច់សំរ ! អង្គុយស្តាប់ ការបរិយាយរបស់ឆេទី រួចបន្ថែមថា៖

ពេលដែលលោកជាវតាក្វាន់បេសកទូតចិនធ្វើទស្សនកិច្ចនៅប្រទេសខ្មែរ នាឆ្នាំ១២៩៦ លោកបានឃើញ ប្រទេសខ្មែរ ខ្ទេចខ្ទាំ ដោយមានសង្គ្រាម ជាមួយថៃ រួចមកម្តងហើយ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ចាប់ពីឆ្នាំ១៣៥២ រាមាធិបតី បានឲ្យកងទ័ពសៀម លុកលុយប្រទេសខ្មែរ ឡោមព័ទ្ធ រាជធានីអង្គរ ហើយដណ្ដើមយកបាន នៅឆ្នាំ១៣៥៣ ។ សៀមប្លន់យកអស់របស់មានដំឡៃផ្សេងៗ តាំងពីរបាំព្រះរាជទ្រព្យ ឡើងទៅ ។

សៀមដាក់ព្រះអង្គម្ចាស់សៀម មួយអង្គ ឲ្យត្រួតត្រាខ្មែរ រហូតដល់ឆ្នាំ១៣៥៧ ទើបខ្មែររើខ្លួនរួច ។

រាល់ជង ដែលសៀមដកទ័ពថយទៅ សៀមដុតបំផ្លាញអង្គរអស់ ។

ដល់ឆ្នាំ១៤៣១ សៀមវាយលុកលុយ ចូលស្រុក ខ្មែរម្ដងទៀត ដុតកំទេចអង្គរ កាត់មែក កាត់ធាង កាត់ឫសគាស់រំលើងឫស រុញផ្ដួល មហារុក្ខាខ្មែរ ឲ្យដួលផ្ងារ ហារមាត់លែងរួច ។

ខ្មែរសំរេចបោះបង់អង្គរចោល ។ ខ្មែរចុះខ្សោយជាលំដាប់ តរៀង រហូតមក ។

ប្រូច់ស៊ះបន្ត!



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្តេចសៀម ដែលវាយយកអង្គរ ជំនាន់នោះមាន ឈ្មោះ ជូបតទៅ ៖

ឆ្នាំ១៣៦៩-ស្តេច អ៊ូ ថុង -ព្រះវិស្ណុ មកចាប់កំណើត ;
ឆ្នាំ១៣៨៨-៨៩ - ស្តេចរាមា សាន់ -ព្រះរាម ចាប់ កំណើត
ឆ្នាំ១៤៣១-ស្តេចបរមរាជាទី២

មកដល់ត្រឹមនេះឮសម្លេងកណ្តឹងរោទិ៍ឡើងៗ ធេវីនាង ស្ទុះទៅបើកទ្វារ ឃើញឡុងនិងមិត្តភក្តិជាច្រើន មកលេងៗ

ឡុង ជាបងជីដូនមួយធេវី ។ ឡុង ធ្វើការនៅប្រទេសខ្មែរ មួយរយៈ ទើបបាន អាហារូបករណ៍ មករៀន នៅស្រុក បារាំង រហូតដល់បានសញ្ញាប័ត្រ ជាបណ្ឌិតខាងច្បាប់ ។ នៅ ស្រុកបារាំង មានវិជ្ជាខ្វះ ពិបាករកការងារ ធ្វើណាស់ ព្រោះ បារាំង គេឥតត្រូវការ យើងទេ ។

ជំរាបសួរ ម្ទេស៍! ជំរាបសួរ ធេវី! ឡុងនិយាយ ។

-ម្ទេស៍ បានជាស្រួលបួលហើយឬនៅ?

- អរគុណច្រើន ខ្ញុំបានស្រួលខ្លះហើយ តែដោយជរា ជង សុខភាព ក៏កាន់តែជាបទៅ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រហ្វង់សំរ! កុំតែរបួសពុំងាយចាកចោលអង្គរឡើយ ឆេទីនិយាយ!

ឡុងសួរ! ចុះ ហ្វង់សំរមក អ្នកណាទៅនៅជំនួស ទទួលថែរក្សាអង្គរ ។

ប្រហ្វង់សំរៈ ជកដង្ហើមធំ រួចពោលថា ពិបាកណាស់ មនុស្សល្ងង់ខ្លៅ ចង់ដឹកនាំស្រុក ។ ថែតែរបស់ដែលមានរួចហើយ ថែមិនកើតផង រួចអួតខ្លួនថា "មហាលោតផ្លោះ" មហាអស្ចារ្យ ។

អ្នកដែលចង់ជួយ មិនដឹងជាជួយដូចម្តេច បើខ្លួនចេះអស់ហើយ ខ្លួនគ្រាន់បើហើយ ។

ឆេទី និយាយ! ពេលដែលប្រហ្វង់សំរ មានគ្រោះថ្នាក់ ចង់ខេមរា ទទួលមើលកិច្ចការជំនួស ។

ខេមរា ជាកូនចិញ្ចឹម ប្រហ្វង់សំរ គាត់ស្រឡាញ់ដូចកូនបង្កើតអញ្ចឹង ។ ចងខេមរាជាអ្នកស្រឡាញ់អង្គរមួយដែរ គាត់អង្គុយធ្វាក់ថ្ម ដែលបាក់បែកឲ្យល្អដូចដើម ។ សម្តី ក៏ពិរោះ ចិត្តទូលាយ អត់ធ្មត់ និងកំដៅថ្ងៃ ឬភ្លៀងផ្គរ ឈររំពឹងគិត



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ធ្វើយ៉ាងណា ឲ្យអក្សរ រស់ឡើងវិញ ។ តែអក្សរ ត្រូវខ្មែរសម្លាប់ បោះបង់ចោល ម្តងទៀត ។ អក្សរជាកន្លែងប្រមូលផ្តុំនៃអ្នកចំណានៗ ក្នុងរាជាណាចក្រ ពួតដៃគ្នា កសាងសមិទ្ធិ ដ៏ស្កឹមស្កៃ ។ នេះហើយ ដែលគេហៅថាមហាលោតផ្លោះ មហាអស្ចារ្យ ។

ប្រួចសំរះ ! ខ្ញុំពុំដែលមានឱកាសនិទាន រឿងខេមរាឲ្យអ្នកស្តាប់ទេ តែពេលនេះឱកាសល្អ ខ្ញុំនឹងនិទានរឿងខ្ញុំ និងរឿង ខេមរា ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ប្រវត្តិ
# ហ្វ្រង់ស័រ



ឪពុកខ្ញុំ ជាអ្នកបច្ចេកទេស ខាងដាំកៅស៊ូ ។ ហ្វ្រង់ស័រ និទាន! គ្រួសារខ្ញុំ បងប្អូនជាច្រើន និងបារាំង ផ្សេងទៀត



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ចាកចេញ ពីកំពង់ផែ " ម៉ារសី " ឆ្ពោះមកព្រៃនគរ នាឆ្នាំ ១៩៣៩ ។ ៣០ថ្ងៃ ទើបមកដល់ បើតាមយន្តហោះ ៨ថ្ងៃ តែប៉ុណ្ណោះ ។

ដើម្បីដាំត្រូវកាប់គាស់ព្រៃ ឆាយដី ។ ពីដើមស្រុកខ្មែរ ដើមឈើធំៗ ហើយ សម្ភារៈពុំ សម្បូណ៌ទៀត ។ ណាមួយ ជម្ងឺគ្រុនចាញ់ និងជម្ងឺផ្សេងៗទៀត ពស់ប៉ឹក ខ្លាស៊ី...បារាំង ត្រូវការកម្លាំងមកជួយធ្វើការ ។

បារាំងទៅចាប់យួន ពីស្រុកយួន យកមកធ្វើការ នៅស្រុកខ្មែរ ។ ហេតុនេះហើយ បានជា មានយួន ជាច្រើន នៅស្រុកខ្មែរ ជាពិសេសយួនហ្វ ។ គេសំគាល់ពួកនេះ ដោយមានធ្មេញខ្មៅ ។

ឡុង សួរទៅ ម្រួចំស៊ំ ! គេចាប់មនុស្ស ដូចម្ដេចទៅ ចាប់ដូចប្រមាត់ប្រមង់ ម្ដងមួយៗ?

-មិនដូចនេះទេ ម្រួចំស៊ំឆ្លើយ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

គេជ្រើសរើសថ្ងៃ យកថ្ងៃបុណ្យ ។ យករដូវណា ពេលដែលមនុស្សទំនេរច្រើន ជាពិសេស ក្រោយពីពេលច្រូតកាត់ហើយ ។

បារាំងយកកុប៉ាល់ធំ ទៅបត នៅជិតច្រាំងមួយ រួចបើក ឲ្យមនុស្សម្នា ឡើងលេងលើ កុប៉ាល់ ។ ពេលយប់ មានភ្លើងភ្លាត់ មានទឹកផឹក និងអំណោយផ្សេងទៀត ។

ដំណឹងនេះ ឮពីមាត់មួយទៅមួយ ពីដើមភូមិដល់ចុងភូមិ ។ យួនកាន់តែច្រើនឡើងៗ នាំគ្នាមកមើល ល្ងាចស្អាប់ភ្លើងលើកុប៉ាល់ ។

នៅថ្ងៃទីបី មនុស្សកាន់តែច្រើនឡើងទេ្វ ។ យួនភ្ញឹកភ្លូចខ្លួន ជក់នឹងល្បែងកំសាន្តផ្សេងៗ ។ ពេលនោះបារាំងបាច់ស្រាយពួរ បណ្តែតកុប៉ាល់ ឲ្យទៅដល់កណ្តាលទន្លេ រួចបារាំងបាច់ជាក់ខ្នោះ មនុស្សណាមានកម្លាំង កំហែងអាចធ្វើការ កាប់គាស់ព្រៃបាន ។ មនុស្សចាស់ដែលពុំអាចធ្វើការបាន ត្រូវលើកបោះទម្លាក់ ក្នុងទឹក យួនណាហ៊ានតដៃត្រូវគេសម្លាប់ចោល ។ យួនទាំងនេះត្រូវដឹក


www.facebook.com/7khmer
Fb page : Entertainment And Knowledge

យកមកស្រុកខ្មែរ ធ្វើការឲ្យបារាំង ។ នៅកន្លែងណា ត្រូវនៅកន្លែង នោះ យួនទាំងនេះ គ្មាន សិទ្ធិ អំណាច នឹងដូរទីលំនៅ ឡើយ << ធ្វើការស៊ីដេក រួចស៊ីដេកធ្វើការ >> នេះជាជីវិតនៃគូលីចំការកៅស៊ូ ។

ដើមកៅស៊ូ ខ្លះឲ្យឈ្មោះថា <<រុក្ខា ស្រក់ទឹកភ្នែក>> ព្រោះជ័រ ចេញពីដើមឈើ ស្រក់តក់ៗ ដូចទឹកភ្នែក ហូរ ព្រោះអាណិតដល់គូលី ។ ឯម្ចាស់ចំការ ប្រមូលលុយ រស់នៅ ដោយក្តីរីករាយ ។ ដល់វ័យសិក្សា ឪពុកយកទៅឲ្យរៀនសាលានៅឯព្រៃនគរ ។ ភ្នំពេញពុំទាន់មានសាលានៅឡើយ។

ឱ! កម្ពុជាដ៏ល្អ សំរាប់គ្រួសារខ្ញុំ និងសំរាប់ខ្លួនខ្ញុំ ខ្ញុំពុំភ្លេចគុណអ្នកឡើយ ។ ខ្ញុំនឹងតបស្នងសងគុណអ្នក រាល់ឱកាសដែលខ្ញុំមាន ។

បារាំងផ្សេងទៀត ធ្លៀតប្រើអំណាច កៀបសង្កត់ បង្អត់ម្ចាស់ស្រុក ធ្វើទុក្ខបុកម្នេញ ទាត់ធាក់វាយដំខ្មែរ ជាការកំសាន្ត ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប៉ាកាំងរស់នៅដោយសាន្តត្រាណ រហូតដល់ឆ្នាំ១៩៣៩ ទើបមានការរំដើបបះបោរ ។

មតិប៉ាកាំង ជំនាន់នោះ ជឿជាក់ថា៖ គ្មានកំឡាំងណាអាចវាយប្រហារប៉ាកាំងបានឡើយ ។

ប៉ាកាំងតែងបទ និងនាំគ្នាច្រៀង៖

" Ma•ton ki ki...

តុងកឹង ក្រុងដ៏ល្អនៃខ្ញុំអើយ!

តែព្យុះសង្គ្រាម នៅមិនឆ្ងាយឡើយ ។ ផ្គរបន្ទោរសញ្ញាពិទិស ខាងកើត ប្រាប់ថា ចលនាតស៊ូ ទាមទារឯករាជ្យ ចាប់បដិសន្ធិហើយ ។ ម្ចាស់ស្រុក ម្ចាស់ដី គេទាមទាររបស់របរគេវិញហើយ ។ ឫកក្រអឺតក្រទមរបស់យើង ត្រូវគេកាប់បំបាក់វិញម្តងហើយ ។

ឆេទី នាងនិយាយម្តងពេលដែលស្រូវសំរះឈប់ ។ ខ្ញុំបានជួបគ្រួសារយួនម្នាក់និយាយថា គាត់ជាទាហានប៉ាកាំងពីដើមធ្លាប់ធ្វើសង្គ្រាមនៅខៀនបៀនភូ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ហ្វ្រង់ស័ះ និទាន ! ឌៀនបៀនភូ ជាតន្លុកវាលមួយដ៏ធំ ហ៊ុមព័ទ្ធជុំវិញដោយភ្នំ ។

បារាំងយល់ថា ទីនេះជាបន្ទាយដ៏ល្អ សំរាប់បារាំង ហ៊ុមជុំវិញ ដោយភ្នំជាកំពែងការពារ ដ៏រឹងមាំ ។ តែការយល់នេះបែរជាខុសស្រឡះទៅវិញ ព្រោះយួនធ្វើពលិកម្មដ៏មហិមា ដឹកទាញអូសឡើងលើកំពូលភ្នំ កាណុងធំៗ រួចបាញ់ផ្ដក់ ចុះក្រោម ទៅលើបន្ទាយបារាំង ។ ឯកុប៉ាល់ហោះដែល បំរុងជួយ ក៏ត្រូវយួនបាញ់ពីលើភ្នំ ធ្វើឲ្យអាក់យាំងដំណើរ ។

ឌៀនបៀនភូ ទម្លាក់អាវុធ បារាំងចុះចាញ់យួន ។ នៅឆ្នាំ១៩៥៤ ថ្ងៃ២០ ខែ៧ សន្និសីទ ទីក្រុងហ្សឺណែវ បែកទឹកដីវៀតណាម ជាពីរ ។

ឡុង ឲ្យយោបល់ ! មិនមែនតែបារាំងទេ ដែលចង់គ្រប់គ្រងឥណ្ឌូចិន មានជប៉ុនទៀត ។ ហ្វ្រង់ស័ះ មានដឹងខ្លះទេ ពេលដែលជប៉ុន ចាប់បារាំងនៅឥណ្ឌូចិន គេថា ក្នុងតែ៣ ថ្ងៃ តែប៉ុណ្ណោះ បារាំងចុះចាញ់ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រួចសំរ! ងក់ក្បាល ។

ខ្ញុំនឹងនិទានឲ្យអ្នកស្តាប់ ។ គឺចាប់ពីពេលនោះហើយ ដែលខ្ញុំបង មិត្តភាព ជាមួយ គ្រួសារ ខ្មែរម្នាក់ រហូតដល់ពេលឥឡូវ គឺគ្រួសារខេមរា នេះឯង ។

ជប៉ុនតាំងទ័ពជាដំបូងនៅហៃហ្វុង ឡេវកាយ និងឡាំងសុង ក្រោមបញ្ជាការ ឧត្តមសេនីយម្នាក់ឈ្មោះនិស៊ីហារ៉ា( Ni shi hara ) នៅថ្ងៃ៩/២/២៨ ពេល ល្ងាច ជប៉ុន ចាប់បារាំង ដកអាវុធ អស់ ក្នុងរយៈ តែ ២ ឬ ៣ ម៉ោង ប៉ុណ្ណោះ មិនមែនបីថ្ងៃនោះទេ ។

ឡុងទឹក ក្នុងចិត្ត! នេះបានសមមុខបារាំង ក្រអឺតក្រទម គងអន្ទាក់ខ្លា ប៉ះចំគេ ខ្លាំងដែរ បាក់ធ្មុង ក្នុងរយៈបីម៉ោង ។ ខ្ញុំនៅចាំកាលណោះចាស់ៗនិទានថា ឃើញបារាំងដែលរត់រួចខ្លួន ពីជប៉ុនចាប់ ស៊ីបាយជ្រូក ព្រោះឃ្លានពេក ។

ប្រួចសំរ បន្ត! ពេលនោះ គ្រួសារខ្ញុំ គេបផុតពី ជប៉ុនរត់ពួន នៅក្នុងព្រៃជិតខុមមួយ មានដំណាំ បន្លែព័ទ្ធ ជុំវិញ ។ ម្ចាស់ផ្ទះគួរសមពន់ពេកក្រៃ ទទួលខ្លួនលាក់បំពួនគ្រួសារ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ខ្ញុំ នៅក្នុងគុម្ពបេក ។ អ្នកដឹងហើយ ច្បាប់ជំនាន់នោះ បើយើងលាក់បំពួនសត្រូវជប៉ុនមុខជាសម្លាប់ចោលមិនខាន ។

ម្ចាស់ផ្ទះជរាបន្តិច ហើយមានជម្ងឺទៀត រស់នៅជាមួយចៅប្រុសម្នាក់អាយុប្រមាណ៩ឆ្នាំ ។ ចៅនោះហើយជាអ្នកនាំចំណី អាហារ ផ្សេងៗ ចិញ្ចឹម គ្រួសារខ្ញុំ ។ កុមារនោះ គឺ ខេមរា នោះឯង ។

ឆេទីនាងសួរ! ចុះឪពុក បងខេមរា នៅឯណា?

ជន ចាស់ជរា ជាជីដូន មិនមែនម្ដាយខេមរា នោះទេ ។ ម្ដាយខេមរា ស្លាប់ តាំងពី ខេមរា ទើបនឹងកើត ម៉្លេះ ។ ឪពុក ខេមរា ត្រូវបារាំង ចាប់ខ្លួន បំរុងនឹងបញ្ជូនទៅកោះត្រឡាច ព្រោះពូគង់ជាមេខ្មែរឥស្សរៈ នៅម្ដុំខាងមេមត់ ។

ឡុង សួរ! ម្រេង់ស៊ំ អ្នករស់នៅ លាក់បំពួនខ្លួន ប៉ុន្មានថ្ងៃ ដែរ ។

ម្រេង់ស៊ំ ឆ្លើយ! ច្រើនខែ ដែរ ។ យើងខ្ញុំរង់ចាំ រហូតដល់ ជប៉ុនចុះចាញ់ ដោយ អាមេរិកទម្លាក់ គ្រាប់បែកបរមាណូ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅលើក្រុង ហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី ថ្ងៃ៦ និងថ្ងៃ៩ ខែ៨ ឆ្នាំ១៩៤៥ ។

ជប៉ុនចុះចាញ់ នៅថ្ងៃ២/៩/៤៥។ ពេលនោះនៅស្រុកខ្មែរ មាននាយករដ្ឋមន្ត្រី សឺនង៉ុកថាញ់ ចូលដៃជាមួយជប៉ុន ។ ដល់ជប៉ុនចុះចាញ់ បារាំងចាប់សឺនង៉ុកថាញ់ ដាក់ពន្ធនាគារ ។

ឡុងបន្ត! រឿងនេះ វែងណាស់ ឪពុក ខេមរា ត្រូវបារាំងចាប់ធ្វើបាប បំរុងនឹងបញ្ជូនទៅកោះត្រឡាច ឯជីដូនខេមរា យកខ្លួន ជួយយកអាសារបារាំង មិនខ្លាចស្លាប់។

ប្រុងសំបន្ត! ឲ្យតែបារាំងមិនមែនសុទ្ធតែអាក្រក់ទាំងអស់នោះទេ។ ឲ្យតែបារាំងមិនមែនជាអ្នកជិះជាន់ រឹបអូសយកសម្បត្តិទ្រព្យ ពីប្រទេសបំណុះនោះឡើយ។

ពូគង់ ឪពុក ខេមរា ជាអ្នកស្នេហាជាតិ ។ បំណងរបស់គាត់ គឺទាមទារឯករាជ្យ ។ ចំពោះខ្ញុំ ជាការទាមទារដ៏ត្រឹមត្រូវ តែចំពោះប្រយោជន៍ប្រទេសបារាំងវិញ បារាំងត្រូវចាត់ពូគង់ ជាសត្រូវនឹងប្រយោជន៍គេ គេត្រូវតែយកចេញឲ្យឆ្ងាយ ។ យ៉ាងណាមិញ ខ្មែរនិងខ្មែរ ក៏ពុំយល់ពុំ


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដូចគ្នាដែរ ខ្លះចូលដៃចូលជើង ជាមួយបារាំង ខ្លះច្បាំងប្រឆាំងនឹងបារាំង ។ ពួកគេប្រហែលជា មានពេលខ្លះច្បាំងនឹងឪពុកខ្លួនផង ក៏មិនដឹង? ឪពុកនិងឪពុកច្បាំងប្រហារគ្នា ឯកូនកំព្រាស្នេហាគ្នា សាងជីវិតថ្មី លើគំនរបាក់បែកនៃកម្ពុជាអភ័ព្វ ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ចលនាខ្មែរ
# ទាមទារឯករាជ្យ

ពេលនោះ មិនមែន មានតែ ប្រទេសខ្មែរ មួយទេ ដែលមានចលនា បះបោរ ទាមទារ ឯករាជ្យ ។ ប្រទេសនានា ផ្សេងទៀត ដែលនៅក្រោមអាណានិគម បារាំង អាហ្វ្រិក អារ៉ាប់ អាស៊ី ផុសផុល ទាមទារឯករាជ្យ ។

នៅស្រុកខ្មែរមាន ចលនាខ្មែរឥស្សរៈ កើតឡើងនៅ ឆ្នាំ១៩៤៧ ដោយលោក ស៊ីវ ហេង ។ ឆ្នាំ១៩៥០ ចលនានេះ ដឹកនាំដោយ សឺនង៉ុកមិញ ។ ក្រោយមកចលនានេះ បែកជាពីរ មួយចូលជាមួយសៀម ដឹកនាំដោយ សឺនង៉ុកថាញ់ មានឈ្មោះថាខ្មែរសេរី ។ មួយទៀតចូលជាមួយ យួន ដឹកនាំដោយ សឺនង៉ុកមិញ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅក្នុងខេត្តកំពង់ចាម ផ្នែកខាងកើត ទន្លេមេគុង ខ្មែរឥស្សរៈ ដឹកនាំដោយពូ គង់ ឪពុកខេមរា ។

ពូគង់ មានជំនួយម្នាក់ឈ្មោះ គន បែកគំនិត យកបលនា ខ្មែរឥស្សរៈ ប្លន់យករបស់របរ ដែលខ្លួនរឹបបាន យកទៅ លក់ យកលុយចែកចាយគ្នីគ្នា ។

ពូ គង់ និយាយថា៖ យើងមិនត្រូវធ្វើដូចនេះទ្បើយ ។ យើងមិនត្រូវលក់របស់ទាំងនេះយកលុយទេ ត្រូវតែចែក របស់នេះដល់អ្នកស្រុក អ្នកស្រែ ឱ្យសប្បាយចិត្ត ។ អ្នក ស្រុកនឹងនាំគ្នាគាំទ្រ យើងទៅថ្ងៃក្រោយទៀត ។ បលនា យើង ខ្មែរឥស្សរៈ ជាបលនា ស្នេហាជាតិ មិនមែនជា ចោរប្លន់ ឥតមានមនសិការ នោះទ្បើយ ។ អ្វីដែលយើង ចង់បាន គឺឱ្យបារាំង ចាកចេញ ពីទឹកដី យើងក្នុងពេល ឆាប់ៗនេះ ។ ខ្ញុំគ្មានចេតនា នឹងសម្លាប់បារាំងសោះទ្បើយ ខ្ញុំពុំចង់មានកម្មពៀរ វេរានឹងគ្នា ប្រពាក់វាក់វិន ដល់ជាតិ ក្រោយៗទៀត ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែគនពុំព្រមស្តាប់ យករបស់ដែលរឹបបាន ពីក្បួនរថយន្តបារាំង ដឹកស្បៀង ទៅលក់ ស៊ីចាយផឹកស្រា ។ អ្នកទាំងពីរ ចាប់មានការរកាំរកូស រវាងគ្នាបន្តិចម្តងៗ ។

ថ្ងៃមួយ គនទឹកក្បត់ លួចឲ្យពត៌មានដល់ទាហានបារាំង ថា ពូ គង់ ប្រុងវាយ ស្ទាក់ឡាន ដឹកស្បៀងទាហាន នៅមុំប្រធាតុ ជិតកណ្តាលជ្រុំ ។

ពេលនោះ នាងស៊ីនួន ប្រពន្ធ ពូគង់ មានផ្ទៃពោះ ជិតគ្រប់ខែ ។ នាងទៅដងទឹក នៅក្នុងបឹង ។ ពេលព្រលឹមស្រាងៗ កាំរស្មីនៃព្រះអាទិត្យ ក្រហមឆ្អៅ ជះរស្មីចូលទៅក្នុងបឹង ដូចឈាម ។

ស៊ីនួនយកដៃអង្អែលផ្ទៃរួចស្រដីថា៖

កូនមាសម្តាយ! ឪពុកនិងម្តាយកូនឯងតស៊ូ យូរអង្វែងគ្មានថ្ងៃណាសប្បាយរីករាយ បន្តិចឡើយ ។ រស់ដោយភិតភ័យ ដូចម្រឹគត្រូវព្រានទន្ទ្រានរានរក ឥតជំរក រងាគោកយ៉ាក ដេកមិនឆ្អែត ស៊ីពុំឆ្ងាញ់ ព្រោះបងប្អូន នេះព្រោះចង់បានសេរីភាព ចង់បានឯករាជ្យ ពីបារាំង នេះគឺសំរាប់



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ដល់ឯង ដល់ខ្មែរទូទៅ គេទៅថ្ងៃមុខ រស់នៅឲ្យបានរុងរឿង សម្បូណ៌សប្បាយ ។ ព្រោះយើងជាម្ចាស់នៃស្រុកយើង យើងនាំគ្នាកសាងស្រុក ទៅតាមលំនាំគំនិត ដែលយើងចង់បានទាំងអស់គ្នា ។

ម្ដាយសង្ឃឹមថា អ្នកដឹកនាំប្រទេសទៅថ្ងៃក្រោយ មិនភ្លេចឡើយនូវញើសឈាមនៃអ្នកតស៊ូ ពេលនេះ ។

និយាយមិនទាន់ចប់ផង គ្រាប់កាំភ្លើងមួយគ្រាប់ រត់បាញ់ទម្លុះដើមទ្រូង ស៊ីនួនរមៀល ធ្លាក់ក្នុងបឹង ។ ឈាមហូរចូលបឹងក្រហមឆ្អិនឆ្អៅ ។

ពូគង់រត់មកលើកបីត្រកងប្រពន្ធ ដៃស្ដាំកាន់កាំភ្លើង ដៃឆ្វេងវែកសក់ មើលមុខប្រពន្ធ ដែលឈឺចាប់នឹងរបួសហួសពីការទ្រាំបាន ។ ទឹកភ្នែក ស៊ីនួន ហូរលាយជាមួយឈាម ។

ប្ដីសម្លាញ់អូនអើយ ! ថ្ងៃនេះជាអវសាន្តនៃជីវិតអូនហើយ ។ បង! មើលព្រះអាទិត្យចាប់រះ ព្រលឹងអូននឹងលា



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ជាតិទឹកដីខ្មែរ ទឹកដីជាទីស្រឡាញ់ ។ អ្នកមិនទាន់ស្គាល់នូវឯករាជ្យនៅឡើយទេ ។ ផ្លូវនៅឆ្ងាយទៀត ។

ប្តីសម្លាញ់! ទុកអូនម្នាក់ឯងចុះ! បងរត់យកអាយុសិនទៅ! បន្តការតស៊ូទៀត សំរាប់អនាគតប្រទេសយើង!

ពេលនោះសម្លេងកូនង៉ា ចាប់ស្រែកឡើង ។ គឺសម្លេងខេមរា ដែលបានឃើញពន្លឺថ្ងៃ ។ ខេមរា ពុំបានឃើញឈាមម្តាយហូរចូលក្នុងបឹងទេ ហើយក៏ពុំបានឮសូរសម្លេងចុកចាប់ម្តាយដែរ ។

ពូគន់ លើកកូនដាក់ជិតដៃស៊ុនួន ។ នាងខំប្រឹងអង្អែលកូន រួចខំញញឹម ។

ឱកូនប្រុស ម្តាយជ្រើសរើសផ្លូវស្នេហាជាតិ ផ្លូវនៃអ្នកក្លាហាន ។ តែជីវិតជួបគ្រោះអាសន្ន មិនមែនជាផ្លូវ សម្បុំសុខនោះឡើយ ។

ពេលនោះនាយគនមកដល់ល្មម មានទាំងទាហានបារាំងនៅពីក្រោយ ។

ពូគន់យល់ថា គនក្បត់គ្នាឯងហើយ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ពូគង់ យកដៃបិទភ្នែក ស៊ុនួនកុំឲ្យនាងឃើញ "មនុស្ស អាក្រក់" តែ ស៊ុនួនបានចូលមរណភាពមុននេះបន្តិច ។

- "ក្រោកឡើង! ទម្លាក់អាវុធចុះ" គន ស្រែក គំរាម ពូគង់ ។

ពូគង់ដាក់កាំភ្លើងចុះ ដៃបីកូនខ្ចី ។

- អញសម្លាប់ឯងឲ្យអស់មួយពូជ គននិយាយ ! អញនឹងក្លាយទៅជាអ្នកមានមួយ អញលក់របស់ដែលប្លន់ពីបារាំងបាន ។ នេះហើយជាផ្លូវជ័ល្អ សំរាប់គ្រួសារអញ ។

គនបាញ់ពូគង់មួយគ្រាប់ដួលដេកជិតប្រពន្ធ ។

ទាហានបារាំងមកដល់ល្មម ពេលដែលគនភ្ជង់កាំភ្លើងបំរុងនឹងសម្លាប់កូនខ្ចីទៀត។ តែបារាំងរុញកាំភ្លើងឆាកចេញ ហើយរុញគនទៅមុខទៀត ដេញរាវរកពួកឥស្សរៈ។ ទារកនេះគឺខេមរា នោះឯង ។ នេះជាប្រវត្តិរបស់ ខេមរា ។

ឆេទីសួរ! បងខេមរា កំព្រាឥតមានឪពុកម្ដាយ ពីត្រឹមពេលនោះមក? ម្ដេចបានជួបជីដូន?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហ្វ្រង់ស័រ៖ បន្ត! ពូ គង់ របួស ត្រូវទាហានបារាំងចាប់បាន ។ ឯខេមរាត្រូវ គេ បោះ បោល នៅ ក្នុងព្រៃ ម្នាក់ឯង នៅ ជិត សពម្ដាយ ។

ក្រោយ មក ក្រោយពី ដឹង ថា ទាហាន បារាំង ដក ថយ វិញអស់ ពួកឥស្សរៈលបៗ ទៅរើសរកសព យកទៅកប់ ធ្វើបុណ្យ ។ ខេមរាត្រូវ គេរើសយក ទៅ ប្រគល់ ឱ្យ ជីដូន ខាង ឪពុក ឈ្មោះយាយ ផាន់ ចិញ្ចឹមបីបាច់ថែរក្សា ។

<< កូនអើយឥតម៉ែ ឥតមានគេថៃ ដូចម៉ែផងខ្លួន >>

ខេមរា ខ្វះ នូវការថ្នាក់ថ្នម ពីឪពុកម្ដាយ ខ្វះក្លិនម្ដាយ ដែលធ្វើ ឱ្យគេ ដល់ធំ ឡើងជាមនុស្ស ស្ងាត់ស្ងៀម រិះគិត ច្រើនពីរឿងជីវិត ។

ឆេទី នាង សួរ បន្ត ទៀត ! ចុះឪពុក បងខេមរា ទៅ ជា យ៉ាងណាទៅ?

ហ្វ្រង់ស័រ - ឆេទី ស្គាល់ពូគង់ទេ ពូម្នាក់ បាក់ដៃ យាមសារមន្ទីរ និងឃ្លាំងឥវ៉ាន់ផ្សេងៗ ពូនេះហើយជាឪពុក ខេមរា ។

ចាំះ! ខ្ញុំស្គាល់ គាត់គួរសមណាស់ ហើយឆ្លាតវៃទៀត ។ ខ្ញុំស្ដាយ ណាស់ ដោយពុំដឹងរឿងរ៉ាវ ទាំងនោះសោះ ម៉េះ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្ញុំសាកសួរ ឲ្យបានច្បាស់ពីបំណង របស់គាត់ និងពីជីវិតតើគាត់យល់យ៉ាងណាដែរ បន្ទាប់ពីរឿងបែក បាក់គ្រួសាររឿងមិត្តក្បត់មិត្ត ។ល។ រឿងស្រុកទេស ។ល។

ប្រុងស៊ំ! ជាធម្មតាមនុស្សក្បត់ គេឥតយកជាគ្នាទេដូចពូគន ។

ឯរឿងពូគន់ ឪពុកខេមរា មានលំនាំដូចតទៅ ។

ខ្ញុំនិងគ្រួសារខ្ញុំ(ប្រុងស៊ំនិយាយ) បន្ទាប់ពីបានរស់រានមានជីវិត ដោយសារជូនផាន់ ជួយលាក់បំបាំងមក ក៏កើតមានចិត្តស្រឡាញ់រាប់អាន ជូនផាន់ និងខេមរា ហើយសន្យាថា នឹងជួយគ្រួសារនេះ ឲ្យបាកផុតពីភាពក្រីក្រលំបាកវេទនា ។ ពួកយើងខ្ញុំ បានសួរទៅជូនផាន់ ថាជូនចង់បានអ្វីក្នុងជាតិនេះ តើជូនមានបំណងប្រាថ្នាយ៉ាងណា ប្រាប់យើងខ្ញុំមក ខ្ញុំនឹងរៃលក ធ្វើយ៉ាងណា ជួយជូនឲ្យបានដូចប្រាថ្នា បើយើងខ្ញុំអាចជួយបាន។

ជូនផាន់ពេលនោះចាប់មានជម្ងឺផង បានរ៉ាយរ៉ាប់រឿងពូគន់ឲ្យយើងខ្ញុំស្តាប់ ដោយក្រៀមក្រំ ក្នុងចិត្តបំផុត។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលដែលយើងខ្ញុំបានស្ដាប់ហើយ យើងខ្ញុំដឹងថា បំណងជូនផាន់ ទី១ គឺចង់រកអ្នកណា ជួយពិញ្ញឹម បិបាច់ ថៃរក្សា ខេមរា ឲ្យបានរៀនសូត្រ ទៅជាអ្នកចេះដឹងនឹងគេ ព្រោះគាត់ចាស់ហើយ ហើយមានជម្ងឺទៀត មិនអាច បិបាច់ថៃរក្សាបៅ ឲ្យបានយូរអង្វែងឡើយៗ ហើយចាប់ តាំងពីបារាំងចាប់ពូគង់មក គ្មានអ្នកណាហ៊ានរាប់អាន គ្រួសារគាត់ឡើយៗ គាត់មើលទៅឃើញខ្មៅងងឹត ចំពោះ វាសនា ខេមរាៗ

ទី២ គឺចង់ឲ្យគេជួយ កុំឲ្យបារាំងសម្លាប់ពូគង់ ឬបញ្ជូន ទៅកោះត្រឡាច ៗ

បំណងជូនផាន់ មិនមែនជាបញ្ហាដល់គ្រួសារខ្ញុំឡើយៗ គឺជាបំណងធម្មតានៃជនជាតិខ្មែរ ដែលចង់រស់នៅដូចគេ ដូចឯង មិនលោភលុយ លោភអំណាចៗលៗ នៅប្រទេស បារាំង បំណងទាំងនេះជាសិទ្ធិនៃពលរដ្ឋ ដែលរដ្ឋត្រូវ តែផ្ដល់ឲ្យចេះមើល ចេះអាន ចេះសរសេរអក្សរ ៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជូន ផាន់និង ខេមរា ត្រូវគ្រួសារខ្ញុំយកមកឲ្យរស់នៅ ឯក្រុងភ្នំពេញ ឲ្យរៀនសូត្រ ដូចគេឯង ។ ឯជូនផាន់ មានពេទ្យមកជួយមើលជម្ងឺ គាត់បានធូរស្បើយ ។ គាត់រមែងទៅមើលកូនគាត់ ពូគង់ នៅក្នុងពន្ធនាគារ " គុកធំ " នាក្រុងភ្នំពេញ ។

កុំតែបានជូនផាន់ជួយ ខ្ញុំម្ល៉េះស្លាប់បាត់ទៅហើយ ទាំងមា មីង បងប្អូន ផ្សេងៗទៀត ។

បារាំងឯទៀត នៅជិតៗទីនោះត្រូវជប៉ុន ចាប់យកទៅទាំងអស់ ។

យាយ ផាន់ ពេលនោះនៅមានអំណាច ព្រោះជាម្ដាយពូគង់មេឥស្សរៈ។ គេហៅយាយផាន់ថា ជា"មាតាស្នេហាជាតិ" ។ គ្មានអ្នកណាហ៊ានមកបៀតបៀនគាត់ឡើយ ។ មេឥស្សរៈជំនាន់នោះ មិនមែនមិនដឹង ពីវត្តមាន នៃយើងខ្ញុំ នោះឡើយ តែគេទាំងនោះស្ដាប់បង្គាប់ យាយ ផាន់ ព្រោះ គាត់បានប្រាប់ទៅមេឥស្សរៈថា" កូនប្រុសខ្ញុំតែមួយ ត្រូវបារាំងចាប់យកទៅ ចាប់ដោយសារ បារាំង ជាសត្រូវនឹងយើង ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែបារាំងនេះ ជាបារាំង ដែលមានទុក្ខទោស យើងត្រូវតែយកអាសារគេ យើងឥតមានបំណងនឹងសម្លាប់គេសោះឡើយ ។ បំណងរបស់យើង សូមឱ្យគេចាកចេញពីទឹកដីយើង។ ឱ្យគេទុកឱ្យយើងមានឯករាជ្យភាព មានសេរីភាព ។ ទោះជាអ្នកមិនព្រមក៏ដោយ ខ្ញុំសូមការពារគ្រួសារនេះ ដែលមកសុំឱ្យខ្ញុំជួយការពារ ។ បើអ្នកមិនព្រម ខ្ញុំសូមឱ្យអ្នកសម្លាប់ខ្ញុំ ជាមុនសិន មុននឹងបាប់គ្រួសារបារាំងទាំងនេះ ។ នេះជាសំណូមពរជាចុងក្រោយបង្អស់របស់ខ្ញុំ ខ្ញុំពុំអាចរស់នៅ ឱ្យបានយូរ តទៅទៀតឡើយ ។ ខ្ញុំពុំចង់ឃើញអ្នកតស៊ូយើង និងបារាំងកាប់សម្លាប់ហុតឈាមគ្នាតទៅទៀត យើងរិះរកមធ្យោបាយការពារប្រយោជន៍រៀងខ្លួន ។ ខ្ញុំព្រាត់ប្រាសកូនសម្លាញ់ចៅឥតឪ ឥតម្តាយ តើអ្នកយល់ថា នេះជាផ្លូវល្អ ដែលត្រូវតែបន្ត តទៅទៀតឬ? ខ្ញុំពុំចង់ឱ្យអ្នកទាំងអស់គ្នា ជួបប្រទះនូវរឿង ដូចខ្ញុំនេះទៀត ។ ខ្ញុំសូមឱ្យអ្នកទាំងអស់ពិចារណា រកផ្លូវណា ឱ្យប្រសើរជាងនេះ។


www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មេឥស្សរៈទាំងនោះ ស្ដាប់ហើយ ក៏លាជូនផាន់ ទៅកាន់ទីកន្លែងរៀងខ្លួន ។ គេបានជួយលួចលាក់បំពួនយើងខ្ញុំ ហើយជូនកាលគេជួយផ្គត់ផ្គង់ ជាចំណីអាហារ ទៀតផង បើតាមខ្ញុំស្មាន ព្រោះមានសាច់ បន្លែប្លែកៗ ។

ហេតុដូចនេះហើយ បានជាខ្ញុំប្ដេជ្ញា ចិត្តថា នឹងជួយរាស្ត្រខ្មែរ ដោយប្រការណាមួយមិនខាន ព្រោះខ្ញុំបារាំង ជាមិត្តនឹងខ្មែរ ។

ពេលដែលខេមរាជាប់បាក់ឌុប យើងខ្ញុំចង់ឲ្យខេមរា រៀនមុខវិជ្ជា សំរាប់ដឹកនាំស្រុក ព្រោះឪពុកម្ដាយជាអ្នក ស្នេហាជាតិ តែយើងខ្ញុំមិនចង់ឃើញទុក្ខសោកខេមរា ព្រោះសង្គមខ្មែរ មិនអនុញ្ញាតខ្មែរគ្នាឯង បានសុខឡើយ ប្រសិនណាយើងប៉ះពាល់ ដល់ប្រយោជន៍គេ ។ យើងក៏សំរេច ដោយមានការ យល់ព្រម ពីខេមរា និងពូគង់ ឲ្យខេមរា រៀនវិជ្ជាវិស្វករសំណង់ ។ ដល់រៀនចប់ ហើយ ខ្ញុំយកមកធ្វើការជាមួយខ្ញុំ កសាងជួសជុលប្រាសាទ ដែលបាក់បែក ។

ចុះជូនផាន់ទៅឯណាសព្វថ្ងៃ? ឆេរី សួរ!



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

-ជូន ផាន់ ទទួលអនិច្ចកម្ម ក្រោយពីខេមរា ចូលរៀននៅសាលា មហាវិទ្យាល័យ ។

ឯពូគង់ត្រូវបារាំង លែងឲ្យ មានសេរីភាព មុនពេលដែលប្រទេសកម្ពុជា បានឯករាជ្យបន្តិច ។ គាត់បានជួបម្តាយនិងកូន ហើយរស់នៅជួបជុំគ្នា ពីរឬបីឆ្នាំដែរ ទើបជូន ផាន់ ទទួលមរណភាពទៅ ។

ឡុង និយាយ ! ពេលដែលខ្មែរបានឯករាជ្យ ហើយ ខ្មែរក៏នៅតែ ខ្វះសមត្ថភាព នឹងកសាងស្រុក ឲ្យបាន ដូចជាបៅហ្វាយដែរ ។

ឆេទី ជូនយោបល់ ! តាមខ្ញុំសង្កេត តាំងពីដើមមក ដល់ស្រុកបារាំង ខ្ញុំឃើញបារាំងនៅស្រុកគេ មិនដូចបារាំងនៅស្រុកយើងទេ ។ គេត្រឹមត្រូវ គេគោរព រាក់ទាក់ គេមិនសំឡុត ដូចបារាំង នៅស្រុកយើងទេ ។ ខ្មែរដែលនៅក្រោមបារាំង ជិតមួយសតវត្ស ជាពិសេស ពួករដ្ឋការ បម្លងយកលក្ខណៈមិនល្អទាំងនោះ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រឃួង់សំរះ ចាប់អារម្មណ៍ទៅលើឯករាជ្យខ្មែរ ៗ ខ្លះថា អាណានិគមអង់គ្លេស គ្រាន់បើជាង អាណានិគមបារាំង ៗ គំនិតទាំងនេះ មិនត្រូវខ្លាំងពេកនោះទេ ព្រោះប្រទេសដែល នៅ ក្រោមអាណានិគម លូតលាស់ បាន បន្ទាប់ពីឯករាជ្យ អាស្រ័យទៅដោយអ្នកដឹកនាំ ៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ដំណែល

# កម្អែល អាណានិគម

បារាំងប្រគល់សំបកផ្ទះមកឲ្យខ្មែរវិញ តែបារាំងពុំបានបោសលាងជូតឲ្យស្អាតឡើយ ។

ច្បាប់ទាំងដុលប្រគល់ឲ្យខ្មែរ ច្បាប់ជិះជាន់មនុស្ស ។ ច្បាប់បារាំងបង្កើត ដើម្បីការពារប្រយោជន៍ខ្លួន ការពារប្រយោជន៍ជនមួយក្តាប់ ។

នៅស្រុកខ្លួន ខ្លួនធ្វើច្បាប់ តម្រូវមនុស្សភាគច្រើន ដែលខ្លួនហៅថា ប្រជាធិបតេយ្យ ។ ដល់មកស្រុកគេ ខ្លួនធ្វើច្បាប់សំរាប់គ្នាខ្លួនមួយក្តាប់តូច ។

ខ្មែរនៅក្រោមបារាំង ឡើងបាងដូចបារាំង ។ ឫកពាដូចលោកបាឡាត់ស្រុក ក្នុងរឿងកុលាបប៉ៃលិន អញ្ចឹង ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

អ្នកដឹកនាំ មានសញ្ញាប័ត្រ ធំ ឫកគួរឲ្យខ្ពើម ឫកសំឡៀត យកលុយ គ្មានអ្វីជាថ្លៃថ្នូរ ។ មនុស្សយ៉ាងនេះហើយ ដែលធ្វើឲ្យសង្គម គៀងស្ទះ ពុំព្រមទៅមុខ ព្រោះគ្មានអ្នកណាចូលជិតបាន ។ ក្រៅពីជំរិតយកលុយ គិតប្រយោជន៍ផ្ទាល់ខ្លួន គ្មានគិតអ្វីជាប្រយោជន៍សាធារណៈ ទាល់តែសោះ ។

ហ្វ្រង់ស័ះ-បារាំង បង្កើតរចនាសម្ព័ន្ធ អប់រំ ឃោសនា ធ្វើយ៉ាងណា កុំឲ្យខ្មែរ លូតលាស់កើត បង្កើតច្បាប់សេដ្ឋកិច្ចសំរាប់តែប្រមូលយកលុយ ចែកគ្នាតែប៉ុណ្ណោះ ។




ពីដើមនៅឥណ្ឌូចិនគេចាយលុយ ពីយ៉ាស្ត្រ (Piastre)។ មួយពីយ៉ាស្ត្រ (Piastre) មានថ្លៃ ១៦,៥០ ហ្វ្រង់ (Franc) នៅឆ្នាំ១៩២០ ។ ឆ្នាំ១៩២៦ មួយពីយ៉ាស្ត្រ (Piastre) មានថ្លៃ២៥ ហ្វ្រង់(Franc)។ ក្នុងកំឡុងឆ្នាំ១៩៥០ ១រៀលថ្លៃស្មើ១០ហ្វ្រង់(Franc)។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឆេរី និយាយ ! កាលខ្ញុំនៅតូច ខ្ញុំតែងឮថា បារាំង សម្លាប់អ្នកបះបោល ៗ ប្រទេសឥតសាលា គ្មានការ អប់រំ ។ កាលណោះមានសាលាវត្ត ដែលអាចជួយបណ្តុះ បណ្តាលខ្មែរឲ្យក្រោកតស៊ូឡើង ។

ប្រូង់ស័រ ! គេអប់រំមនុស្ស កុំឲ្យមានលក្ខណៈបីយ៉ាង ជាប់នឹងខ្លួន ៗ របស់ទាំងបីនោះគឺ ៖

-ការស្អប់ឈ្នានីសគ្នា

-ការកេងប្រវ័ញ្ចគេ

-ការមើលងាយមើលថោកគេ

តែលក្ខណៈទាំងនោះ គេឃើញមាននៅលើខ្មែរភាគ ច្រើន ដូចយ៉ាងលោកបាឡាត់ស្រុកជាដើម ។

ផ្លូវដែលជ្រើសរើស សំរាប់ជីវិត គឺផ្លូវគោរពកោត ខ្លាច ៗ លើកដៃសំពះ ទទួលទ្រនូវអ្វីទាំងពួងដែលធ្លាក់ពី លើមេឃ ដែលខ្លួនហៅព្រេងវាសនា ។ ទទួលព្រមយក ទាំងអស់ ដោយពុំបាច់គិតរកផ្លូវដោះស្រាយ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រូចំសំ៖ ! ខ្មែរមានលក្ខណៈល្អ អាចរស់នៅជាមួយគ្នាបាន ។ ជាមនុស្ស ស្ងាត់ស្ងៀម រំពឹងគិត ដើរបិទភ្នែកត្រឹមៗ ដូចលោកទ្រង់បាត្រ ។ គិតទៅឋានសួគ៌ ច្រើនជាង គិតពីជីវិតសព្វថ្ងៃ ។ ឯបារាំង គេគិតជីវិតសព្វថ្ងៃជាមុនសិន មុននឹងគិតដល់បរលោក សមដូចពាក្យថា៖

Aides – toi, le ciel t'aidera ប្រែថា៖ ត្រូវជួយខ្លួនអ្នកជាមុនសិន ទើបព្រះឥន្ទ្រនឹងជួយអ្នកជាខាងក្រោយ ។

ឡុង ស៊ួរ ! ក្នុងចំណោមប្រជាជនឥណ្ឌូចិន អ្នកណាគ្រាន់បើជាងគេ!

ក្នុងចំណោមសាសន៍បី ខ្មែរ យួន លាវ គេច្រើននិយាយដូចតទៅ៖

គេថា យួនជាអ្នកដាំស្រូវ ខ្មែរក្រឡេកមើលស្រូវដុះ ឯលាវដេកលេងផ្លុំខ្លុយ ចាំដល់ស្រូវទុំ ។

ប្រូចំសំ៖ បន្ត! មានរឿងមួយដែលគេច្រើននិទានលេងៗ ថ្ងៃមួយមាន ខ្មែរ ម្នាក់ មាឌធំបងស្រអែមខ្មៅសក់រួញ ភ្នែកខ្មៅមូល ចូលទៅប្តឹងបារាំងថាមានយួនម្នាក់ចង់វាយគាត់ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

បារាំងនឹកក្នុងចិត្ត ចង់ឃើញមនុស្ស ដែលហ៊ានវាយ តូនេះៗ គេទៅ ហៅយួនយកមក ។ គ្រាន់តែឃើញយួនភ្លាម បារាំងលាន់មាត់ៈ

ឱ!ម្ចាស់ថ្លៃអើយ! យួនស្គមតៃវ៉ៃ ស្គមដូចប្រចៀវចងគ្រៀង គ្រាន់តែវាវាសមួយដៃ ដួលផ្កាប់មុខបាត់ហើយ ។

នេះចង់បង្ហាញ លក្ខណខ្មែរ ដែលចង់បាន យុត្តិធម៌ ពីសំណាក់រដ្ឋការ ។ រឿងធំ គឺរឿងយុត្តិធម៌ក្នុងសង្គម ។ ការដែលខ្វះយុត្តិធម៌ ធ្វើឲ្យយើងពុំអាចរកស៊ីខ្ចីធនាគារ ទិញផ្ទះ ទិញឡាន ឬទិញរបស់ប្រើផ្សេងៗ ដូចស្រុកគេបានឡើយ ។

ខ្វះយុត្តិធម៌ ប្រទេសនឹងស្គាល់នូវអនាធិបតេយ្យ ព្រោះគ្មានច្បាប់ការពារ ។ មនុស្សត្រូវការច្បាប់ ។ សត្វរស់នៅ ដោយគ្មានច្បាប់ ខ្លាចាប់សត្វណា ស៊ីក៏បាន ស្រេចអំពើចិត្ត ។

ឡុង បន្តសំនួរ ! **ហ្វ្រង់ស៎ះ** ធ្វើដូចម្តេចបានជាចេះខ្មែរច្បាស់ម៉្លេះ?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រូចស៊ំ៖ -ចេះពីរៀន មានពីរក ។ កាលខ្ញុំនៅតូច ខ្ញុំមានខ្ញុំកំដរ ខ្មែរយួន ។ ខ្ញុំនិយាយជាមួយអ្នកទាំងនោះ ។ យួនក៏ខ្ញុំចេះ ខ្មែរក៏ខ្ញុំចេះ ។ កាលនៅតូច រៀនភាសាឆាប់ចេះណាស់ ដល់ធំពុំងាយរៀនទេ ។

ឡុង-នៅអឺរ៉ុប ពីដើមច្បាំងគ្នា មិនឈប់ឈរដែរ ទំរាំគេរករបៀបរស់នៅ ដោយសុខសាន្តនឹងគ្នា ។

ឆេទី ចៀតសួរទៅ ប្រូចស៊ំ

អ្វីទៅដែលធ្វើឲ្យមនុស្សខ្លាំងពូកែ? អ្វីទៅដែលធ្វើឲ្យមនុស្សចៀសវាង គ្រោះថ្នាក់ផ្សេងៗ?

ប្រូចស៊ំ៖ មនុស្សជំនាន់ដើម រស់នៅក្នុងព្រៃ ឬរូងភ្នំ ទាល់តែសាមគ្គីគ្នា ទើបអាចប្រយុទ្ធនឹងសត្វព្រៃ ខ្លាជំរឺបាន ។

មនុស្សកើតមក ពុំមានគ្រឿងការពារ ដូចសត្វឡើយ គ្មានក្រចក គ្មានចង្កូម គ្មានខ្នាយ ស្បែកមិនក្រាស់ទៀត ។ តែមនុស្ស មានបញ្ញា ប្រើកម្លាំង មនុស្សមិនអាចឈ្នះសត្វបានឡើយ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មនុស្សសាមគ្គីគ្នា ប្រើគំនិត បែងចែក ការងារ សង់របង សង់ផ្ទះ ធ្វើកាំបិត ដាវ លំពែង ។ មនុស្សទេ ដែលការពារ ភូមិដ្ឋាន មិនមែនរបងនោះឡើយ ។ ឥតមានមនុស្ស របងឥតបានការអ្វីទេ ។ មនុស្សធ្វើភ្លើង បង្កាត់ភ្លើង រកទឹក ជីកអណ្តូង ។ល។

តែឯកឯង មនុស្ស ពុំអាចជីកអណ្តូង សង់ផ្ទះ ធ្វើឡាន ...បានឡើយ ។

សត្វគោ កើតឡើងម្នាក់ឯង លើដីមានស្មៅ ។ នៅក្រោមជើងវា មានស្មៅ គោអាចរស់តែឯងបាន ។

ឆេទី នាងសួរទៅហ្វ្រូឌ់សំ៖ ថា៖

សត្វពាហណៈ គេមើលក្រយៅ?

មនុស្ស គេមើលអម្បូរ?

ឯប្រទេស គេមើលអ្វី ដើម្បីដឹងថាល្អឬអាក្រក់ទៅថ្ងៃក្រោយ?

ហ្វ្រូឌ់សំ៖ ឆ្លើយ!

គេមើលអ្នកដឹកនាំ ជាមនុស្សជំពូកណា?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

- កាប សាហាវយង់ឃ្នង ឬមនុស្សស្លូតបូត ជឿបាប បុណ្យ ។

-គេមើលសេដ្ឋកិច្ចប្រទេស ប្រជាជនមានប៉ុន្មាននាក់ ស្រូវ ត្រី សាច់ ផលិតបានប៉ុន្មាន ស៊ីអស់ប៉ុន្មាន នៅសល់ប៉ុន្មាន បើបេះតែខ្វះស៊ីរាល់ឆ្នាំ ច្បាស់ជាថ្ងៃណាមួយ មានការបះបោរហើយ ។

-គេមើលចិត្តគំនិតរាស្ត្រប្រជា ចរិតយុវជន ដែលថ្ងៃក្រោយ ទៅជាពលរដ្ឋ តើជាមនុស្សមានការអប់រំត្រឹមត្រូវ ចូលចិត្តយុត្តិធម៌ ស្អាតស្អំ? ឬក៏ជាមនុស្សខិលខូចស៊ីក្បាល ស៊ីកន្ទុយ គ្មានគិតគេឯង សប្បាយតែលើអបាយមុខ ប៉ោតែឡ្យ ក្អួងក្អាង ។ បើយុវជនអាក្រក់ មានចំនួនច្រើន ប្រទេសច្បាស់ជា ផ្សៀងទៅរកសង្គ្រាម ទៅរកជម្លោះគ្នាឯងក្នុងស្រុក ទៅអនាធិបតេយ្យ ។

ឆ្លុះជូនជាមតិ!

ខ្មែរយើងរមែងអធ្យាស្រ័យច្រើន ពុំមានចរិត ដូចបារាំងទេ ។ យើងឃើញចៅហ្វាយស្រុកជិះឡានថ្មី ក៏មិន



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ថាអ្វី? ថ្វីត្បិតតែដឹងថាប្រាក់ខែចៅហ្វាយស្រុក មិនអាចទិញឡានបានល្អ យ៉ាងនេះក៏ដោយ ព្រោះជាកុសលផលបុណ្យគេ ដែលគេកសាងពីជាតិមុន ។

ម្ចាស់ះ ! ខ្មែរភាគច្រើន ប្រឡំសាសនា និងជីវិតរស់នៅ ។ សាសនានិយាយថា កុំកុហក កុំសម្លាប់សត្វ កុំកេងប្រវ័ញ្ចគេ ។ល។ តែក្នុងជីវិតរស់នៅ អ្នករកស៊ីក្ដី ត្រូវកុហកខ្លះ ដើម្បីបានចំណេញ ។ មនុស្សដើម្បីរស់ត្រូវហ៊ានចាប់ត្រី ចិញ្ចឹមសត្វ ។ល។

ឆ្មុះ និទាន! មានកន្លែងមួយ ទឹកចេញពីក្នុងដី ក្ដៅពុះហុយផ្សែង ព្រោះជារន្ធភ្នំភ្លើងពីដើម ។ ខ្លះទៅមុជទឹកកន្លែងនោះ ព្រោះល្បីថាអាចជួយឲ្យជាជម្ងឺសើស្បែក ។

តែមីងម្នាក់ខ្មែរ គាត់ថាពុំទៅមុជទេ ព្រោះទឹកនោះចេញពីឋាននរក ។ យមបាលធ្វើកំពប់ទឹកខ្ទះគ្នោត ដែលគេដាំស្រុសមនុស្ស ដែលមានកម្ម ។

ម្ចាស់ះ ! នេះបង្ហាញឲ្យយើងឃើញនូវទំនាស់រវាងសាសនានិងវិទ្យាសាស្ត្រ ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

មិងនោះ ដែលជឿតាម របៀបសាសនា ពុំអាចឲ្យកម រមាស់ គាត់ជាបានឡើយ ។

អ្វី ដែលគេ បង្ហាត់បង្រៀន ពីក្មេងមក ជាប់នៅ នឹងខ្លួន គាត់រហូត ដល់ចាស់ស្លាប់ ។

ឡុង និយាយ រឿងមួយទៀត! កាលជំនាន់សង្គម មាន លោក មហាមន្ត្រី មួយ ទិញឡានល្អជាងគេ ។ មានតែមួយ គត់ ក្នុងរាជាណាចក្រ ។ គាត់ បង្ខំឲ្យឈ្នួញ ទិញគ្រឿងឡាន សំរាប់តែឡានគាត់មួយ ។ ស្រុកយើងក្រ ពុំអាច ប្រើឡាន គ្រប់ធុន គ្រប់ម៉ាក ហើយទិញខ្លៅខ្យង ស្តុកទុក ហូរហៀរ បានឡើយ ។

ឡុង បន្ត! កាលជំនាន់សម្តេច កាលណោះ ខ្ញុំនៅក្មេង អ្នកដែលមានអាយុប្រហែល នឹងឪពុកខ្ញុំ ដឹងរឿងលោក គះ ។ គះ ជាកុង្សី ខាងប៉ូលិស អាងយ៉ាងក្អេងក្អាង សំឡុតគេ ឯង ឥតក្រែងអ្វីឡើយ ។ សំឡុតជំណាងរាស្ត្រ បំណងនឹង សម្លាប់ ជំណាងរាស្ត្រណា ដែលមិនខ្ចប់ខ្ជាប់អំណាចខ្លួន ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

អ្នកណាដែលឆ្លើយទូរស័ព្ទមិនស្រួល មិនត្រូវចិត្តខ្លួន គេ: ទៅវាយតប់ទាត់ធាក់ដល់ប៉ុយរ៉ូ ។ ធ្វើឫកដូចបារាំង ទាត់ធាក់គេ តាមអំពើចិត្ត សមដូចឃ្លាជំណាលថា:

" អាបារាំងបារេ ចោរអប្បល័ក្ខ ហ៊ានយកជើងធាក់ អាលក្ខហ្លួងលេង" ។

កាលណោះ សង្គមដូចគៀងស្ទះ ទៅមុខមិនរួច ទំនាស់រវាងយុវជននិងរដ្ឋការ រវាងក្មេងនិងចាស់ជំនាន់មុន ។

សម្ដេច លោកធ្វើល្អ កសាងមហាវិទ្យាល័យ ជាច្រើន បង្ហាត់បង្រៀនដល់កម្រិតវិស្វករ ។

តែវិស្វករទាំងនោះ ដល់ពេលចេញពីសាលា ពុំមានក្របខ័ណ្ឌ នឹងគេទេ គេហៅថាកុងត្រាក់ទុយអែល ( Contractuel ) ។ គេពុំប្រគល់កិច្ចការឲ្យធ្វើ កិច្ចការដែលមានការទទួលខុសត្រូវ ។ យុវជនក្មេងៗ ពោរពេញទៅដោយថាមពល ត្រូវគេបញ្ឈរជើងចោល បាក់កម្លាំងនឿយណាយ ។

ខ្ញុំនៅចាំកាលណោះ យុវជនវិស្វករ ក្មេងៗស្រាក់លុយគ្នាយកទៅសូកបាស់ៗធ្វើការនៅ Fonction publique ដើម្បី


Fb page : Entertainment And Knowledge

ឲ្យចេញ Statut ។ តែមនុស្សចាស់នោះស៊ីលុយអស់ ហុចសំបកឲ្យយុវជនវិញ ។ ហេតុដូចនេះហើយ បានជាមានយុវជនខ្លះកាន់ជើងលោក លន់ នល់ ព្រោះសង្ឃឹមថាមានយុត្តិធម៌ជាមិនខាន ។ ចាស់ៗនាំគ្នាបិទផ្លូវមិនឲ្យក្មេងរុលទៅមុខរួច កន្លែងខ្វាញ់ គេដាក់គ្នាគេ ។ គេថាយើង Contractuel ។ មិនមែនថាយើងខ្មែរ ខ្មែរដែលមានជំរេះនោះទេ ។ ទោះជាអ្នកមកពីស្រុកណា មានសញ្ញាប័ត្រយ៉ាងណា ក៏ជា Contractuel ដែរ ។ និស្សិតមកពីអាមេរិក រុស្ស៊ី អល្លឺម៉ង់ ។ល។ សុទ្ធតែ Contractuel ។

ឯអ្នកដែលគ្រប់គ្រងតាមខេត្ត នាយកដ្ឋាន មានសញ្ញាប័ត្រជា " Controleur " ចាស់ៗ ។ ពួកនេះមានលុយច្រើន គេស្រាក់លុយគ្នា ទៅសូក Fonction publique ធ្វើយ៉ាងណាកុំឲ្យ Statut ចេញ ។ ការដែលពុំព្រមដោះស្រាយបញ្ហា ធ្វើឲ្យទៅជាទំនាស់សង្គម ទំនាស់ជំនាន់មួយទៅជំនាន់មួយ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទំនាស់មានច្រើនទៀត ម្នាក់ៗធ្វើតាមចិត្តខ្លួន តាមខ្លួនយល់ឃើញ គ្មានច្បាប់គ្មានទម្លាប់ ។

នៅជិតផ្ទះខ្ញុំ ពីដើម មានតាម្នាក់ ការ់ សិល ឡុង និយាយ គាត់មានស្រះមួយ មានត្រីជាច្រើន ។ ដើម្បីកុំឲ្យគេបាប់ត្រីក្នុងស្រះ គាត់ ព្រោះគាត់ខ្លាចបាបដល់គាត់ គាត់បោះអំបែងដប កញ្ចក់ ផ្សេងៗ ។ អំបែងទាំងនោះ អាចធ្វើឲ្យគ្រោះថ្នាក់ដល់មនុស្ស ទៅជាខ្វិន ពិការ ។

ថ្ងៃមួយ កូនចៅគាត់ មកពីភ្នំពេញ គ្នាមិនដឹង ក៏បុះមុជទឹកលេង មុតនឹងអំបែង ទៅជាពិការ ។

ម្ចាស់សំរ ! នៅស្រុកបារាំង អ្នកដែលបង្ក គ្រោះថ្នាក់ដល់គេ ជាអ្នកមានទោស ។

ពេលនោះ ម្ចាស់សំរ ក្រោកឡើងទៅបត់ជើង ។ ឡុងលួចសួរឆេទីថា៖ តើម្ចាស់សំរ មានគ្រួសារឬទេ?

- ចាំះ មាន ។ ប្រពន្ធគាត់ បុះទៅទិញថ្នាំ បាត់ហើយបន្តិចទៀតទើបត្រឡប់មកវិញ ។ ជាភរិយាទីពីរ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រពន្ធទីមួយ ជាជាតិបារាំង បានកូនមួយ ធ្វើជាអ្នកកាសែត និងថតរូប ភ្នាក់ងារ កាសែត ប្រចាំដំបន់អាស៊ី ។

ថ្ងៃមួយ កូនប្រុសទទួលគ្រោះថ្នាក់ បាត់បង់ជីវិត នៅមុំព្រំដែន ខ្មែរ-វៀតណាម ។

ប្រ៊ូង់ស័រ និងភរិយា ក្រៀមក្រំក្រៃលែង ។ ប្រពន្ធ ប្រ៊ូង់ស័រ ពុំអាចរស់នៅក្នុងស្រុកខ្មែរ តទៅ ទៀតបាន ព្រោះ ពោរពេញ ទៅដោយ អនុស្សាវរីយ៍ ដែលធ្វើឲ្យគាត់ បំភ្លេចកូនពុំបាន ។

ឯ ប្រ៊ូង់ស័រ វិញ ពុំអាច បោះបង់អង្គរបានឡើយ ព្រោះ អង្គរស្ទើរតែ ជាបេះដូងរបស់គាត់ទៅហើយ ។

អ្នកទាំងពីរ ក៏សំរេចនៅដាច់គ្នា ។

ក្រោយមក ប្រ៊ូង់ស័រ យកប្រពន្ធ ឈ្មោះ មាឈា ជាសាច់ញាតិ ខាងបងខេមរា ។ គាត់ស្រឡាញ់រាប់អានខ្ញុំណាស់ ។ ហេតុដូចនេះ ហើយបានជាគាត់យកខ្ញុំមកតាម ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ធេវី បន្ត! ពេលដែលម្តាយ មិនលក់ភោជនីយដ្ឋានទៅ ខ្ញុំឥតមានការអ្វីធ្វើឡើយ ។ ម្រេង្គសំរ និងខេមរា ហៅខ្ញុំទៅជួយ ធ្វើការជាអ្នកថែរក្សាឃ្លាំង រូបចម្លាក់ នានា ។

ឡុងសួរ! តើ ម្រេង្គសំរ មានគ្រោះថ្នាក់អ្វីទៅ?

ធេវី និទាន! ម្រេង្គសំរ ខិតខំកសាងទីលានជាំ ។ ការដ្ឋានធំជាងគេ មនុស្ស៣០នាក់ ធ្វើការ៥ឆ្នាំមកហើយ ។ ថ្ងៃនោះមិនដឹងជាថៃជន្យអ្វី ពេលយប់ខ្ញុំសុបិនឃើញថា អង្គររលំបាក់បែក អស់ ។ ខ្មែរបាត់អង្គរ ថ្មតរលើគ្នា ។ ខ្ញុំយំរហូតភ្ញាក់ដឹងខ្លួន ។

បងខេមរា ខំលួងលោមខ្ញុំ កុំឲ្យរន្ធត់ពេក ហើយយើងទាំងពីរនាក់ នាំគ្នាមកញ៉ាំគុយទាវ ឯក្រុងសៀមរាប ។ នៅតាមផ្លូវ មានមនុស្សដែកធេរ សំបុត្រស្នាម ហូរហែ ។ ក្រុងសៀមរាប ពីដើមជាក្រុងគេស្រមក្សាន្ត ឥឡូវក្លាយទៅជាក្រុង រង់ចាំការបំផ្លាញ ។ ពេលយប់ ខ្មាំងបាញ់ផ្គក់ គ្រាប់បែកធ្លាក់លើផ្ទះ សាលារៀន មន្ទីរពេទ្យ ។ល។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

យើងបើកលើស្ពានដែក ចូលកាត់ស្ទឹងសៀមរាប ។ ពីដើមគេមុជទឹកបាន ឥឡូវទឹកស្ទឹងក្លាយទៅជាភក់ជ្រាំស្អុយ ចំកណ្តាលក្រុង ។ ឲ្យតែមានទឹកកន្លែងណា គេទៅសង់បង្គន់ពីលើ ។ ម្នាក់អ្នកដុះដាក់ទឹក ម្នាក់ដងទឹកយកទៅប្រើ ។ គេគ្មានគិតថាទឹកស្ទឹងនេះជារបស់រួម ហើយនិងនាំគ្នា ជួយសំអាតសោះ ។

ក្រោយពីស្រូបស្រស់គុយទាវហើយ យើងទាំងពីរនាក់វិលទៅរកម្ទង់សំះ ឯលានជំរឺ ព្រោះថ្ងៃនេះជាថ្ងៃបង្ហើយ ។ កិច្ចការ ៥ឆ្នាំ ក្រោមភ្លៀង ក្រោមផ្គរ ទើបតែនឹងចប់ ។ ទៅដល់ឃើញមនុស្សច្រើនមិរ ប៉ូលិស ទាហាន ឡានពេទ្យ ។ គេប្រាប់ថាម្ទង់សំះ មានរបួសជាទម្ងន់ ខ្មែរក្រហមយកមីន មកកប់នៅទីលានជំរឺ ។

ខេមរា ឱបម្ទង់សំះ ដែលដេកក្នុងឡានពេទ្យ ឱបឪពុកយំស្រក់ទឹកភ្នែក ។

ឱព្រះជាម្ចាស់អើយ! ឈាមជាបពោះជំរឺ ទើបនឹងចាប់ផ្ដើមទេឬ? ឬក៏ឈាមជាបពោះជំរឺជិតដល់ទីបញ្ចប់



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ហើយ ព្រោះខ្ញុំឃើញរូបដំរីប្រឡាក់សុទ្ធតែឈាម ។ តែឈាមមិនគ្រប់គ្រាន់ទៅឡើយ ។ មិនដឹងជានៅខ្វះឈាមប៉ុន្មានទៀតទេ?

ផ្ទាំងសិលានានា ដួលដេកបាក់បែកធ្លាក់រាត់រាយ ពាសពេញធរណី ។

រដ្ឋាភិបាលបារាំង យកបិត្តុទុកដាក់ នឹងគ្រឿងសឹះ ណាស់ដឹកយកមកព្យាបាល ឯក្រុងភ្នំពេញ ។

ពេលដែលខ្ញុំមកដល់ភ្នំពេញ ជាមួយគ្រឿងសឹះ របប ឈន់ឈល់ ជិតរលំហើយ ។

ភ្នំពេញ ពីដើម ដែលមានប្រជាជនមិនដល់មួយលាននាក់ផង ឡើងកើនចំនួនជិត២លាននាក់ មួយជាពីរ ។ មនុស្សម៉ឺរ តាន់តាប់ ដេករកេតរកូត តាមចិញ្ចើមថ្នល់ តាមរានគ្រែដែលសេសសល់ ។ អ្នកទាំងនោះជាជនភៀសខ្លួន រត់ចោលភូមិឋាន ផ្ទះសម្បែង ដែលត្រូវភ្លើងសង្គ្រាម បំផ្លិចបំផ្លាញ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ភ្លើងសង្គ្រាម រាលដាល ហ៊ុមព័ទ្ធជុំវិញ ក្រុងភ្នំពេញ ។ ផ្លូវគមនាគមន៍ត្រូវកាត់ផ្ដាច់ ។ ទំនាក់ទំនងរវាងក្រុងភ្នំពេញ និងខេត្តនានា ធ្វើឡើងដោយកប៉ាល់ហោះ ។

រាល់ថ្ងៃកប៉ាល់ទឹក ដឹកស្បៀងពីស្រុកយួន ហែរហម ដោយ កប៉ាល់ចម្បាំង ។ ខ្មាំងពួនស្ទាក់បាញ់លិចកប៉ាល់ ។ ខ្លះក៏មកដល់រដ្ឋធានី ។

ទំនិញឡើងថ្លៃ ហួសកម្រិត ប្រាក់រៀលចុះថ្លៃ ជារាល់ថ្ងៃ ។ ពីដើមយើងទិញកូនជ្រូកមួយ ដល់ឥឡូវលក់ពងមាន់មួយសងរួចថ្លៃជ្រូក ។

មនុស្សសុំទានពាសពេញទីក្រុង ។ អ្នកមានកាន់តែមានឡើង ។ ភ្នំពេញបង្អៀតដោយឡាន ចេញទៅឆ្ងាយពុំបាន កំណត់ត្រឹមគីឡូលេខ៦ ពោធិចិនតុង តាខ្មៅ ច្បារអំពៅ ។

ពេលយប់ គ្រាប់កាណុង ធ្លាក់ចូលក្រុង ត្រូវសាលារៀន ផ្ទះសម្បែង មន្ទីរពេទ្យ ។ល។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មន្ទីរពេទ្យ ពោរពេញ ទៅដោយមនុស្សរបួស ដាច់ដៃ ដាច់ជើង ខ្វាក់ភ្នែក បែកក្បាល ស្រែកថ្ងូរ ឈាមហូរស្រក់ លើប្រថពី ។

ក្រៅពីនេះ ភ្នំពេញ ពោរពេញទៅដោយទាហាន ឯកសណ្ឋានគ្រប់គ្នា សិស្សសាលា រដ្ឋការ ។ នៅលើមេឃ ឧទ្ធម្ភាគចក្រ ទាហាន និងកុម៉ាល់ហោះ "បានស្រាក់" ហោះហើរ ខ្វាត់ខ្វែង ។ ទាហានឈរបាញ់សំញែង មើលពីលើមេឃ ។

គ្រាប់បែក ផ្ទុះម្ដងៗ នៅផ្សារអូរឫស្សី ម្ដងនៅផ្សារថ្មី ម្ដងនៅផ្សារអូរឡាំពិក...។ល។

ក្បួនហែរសព ហែរមិនចេះចប់ ។ កន្លែងដុតសព ភ្លើងឆេះឥតឈប់ ។ អ្នកគោរសក់កាន់ទុក្ខ កាន់តែច្រើនឡើងៗ ។

ប៉ូលិសដេញចាប់យុវជន នៅក្នុងរោងកុន ដើម្បីឲ្យទៅធ្វើទាហាន ។ ទាហានឥតប្រាក់ខែ រដ្ឋគ្មានលុយបើកឲ្យ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាហានឥតគ្រប់ចំនួនទៅច្បាំង ។ មួយកំប៉ាញី មានតែពីរ ឬ បីនាក់ ក្នុងចិត្តប្រុងតែទម្លាក់អាវុធ រត់ឲ្យតែរួចតែខ្លួន ។

ជាប់ភ្លើង ជាប់ទឹកជានិរន្តរ៍ ។ មួយថ្ងៃៗ ជាប់ពីរ ឬ បីដង ។

ទាហានទៅច្បាំងដឹកប្រពន្ធកូនទៅតាមមានទាំងឆ្នាំងបាយ ឆ្នាំងសម្ល ទៅជាមួយដែរ ។ កន្សែងយន្តក្រហមឬសវ៉ាន់ក ពាសពេញព្រាត ។ ដោយមនុស្សច្រើនពេក ចារនឹងដៃមិនទាន់ គេផ្ដិតកន្សែងយន្តដោយម៉ាស៊ីន លក់ ឬចែកទៅឲ្យអ្នកដែលចង់បាន ។

ឈន់ឈល់ ជិះកុប៉ាល់ហោះ ប្រោះព្រំ ក្រុងភ្នំពេញ ឲ្យរួចផុតពីកាណុងផ្ដក់ ។

វិទ្យុខ្មែរក្រហម ផ្សាយសំឡេង សុំឲ្យខ្មែរសាធារណរដ្ឋ ទម្លាក់អាវុធចុះ គេសម្លាប់តែមនុស្ស៧នាក់ អ្នកដឹកនាំគ្រាក់ៗ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឯ ប្រុងសំរ ត្រូវគេដឹកយកមកព្យាបាល ឯក្រុងប៉ារីស៍ទៀត ។

បងខេមរា ពុំបាន មកជាមួយយើងទេ ព្រោះនៅរៀបចំ ទុកដាក់សម្ភារៈ រូបចម្លាក់ផ្សេងៗ ។

ឱ បងខេមរា មាសស្នេហ៍អូនអើយ! អង្គរមួយ គេមិនស្តាយ បងស្តាយព្រះកេសព្រះពុទ្ធ និងព្រះកេសព្រះវិស្ណុ ព្រះនរាយ...ៗលៗ

គេប្រាំងធ្វើយ៉ាងណា ឲ្យតែបានអំណាច ទោះជាអង្គរ ឬប្រាសាទឯទៀត រលំផុល ក៏គេឥតឈឺក្បាលដែរ ។

យើងបែកគ្នា ហៅមិនឮ? ពុំដឹងជាបងស្លាប់ ឬរស់? បាត់ដំណឹងសូន្យឈឹងៗ សាធារណរដ្ឋធ្លាក់ ក្នុងកណ្តាប់ដៃខ្មែរក្រហម ។

ពេលវេលាចេះតែកន្លងទៅមុខៗ ប្រុងសំរ និងឆេទី រមែងស៊ើបសួរ ដំណឹងពីខេមរា ក្រែងលោមានអ្នកណាស្គាល់ ។

អូនជឿលើបារមីព្រះពុទ្ធនៅអង្គរ ថាព្រះអង្គមិនឈរនៅស្ងៀម ឲ្យខ្មែរក្រហម ធ្វើបាបបងឡើយ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

របប ប៉ុលពត រលំ បះជើងទៅ ហ្វ្រង់ស័រ និងធេវី បាន សំបុត្រអនុញ្ញាតិឲ្យចូលស្រុកខ្មែរ ។ អ្នកទាំងពីរ រៀបចំ វ៉ាលិស ចេញពីក្រុងប៉ារីស៍ ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

# បេះប្រឡេះអ្នកចេះចោល
# ខ្មែរក្រហម កម្រោល
# ដូចពួកអាណានិគម!

កប៉ាល់ហោះ ចុះចតនៅអាកាសយានដ្ឋាន ពោធិចិនតុង ប្រហ្វេសំ និងឆេទី រិះរកវិធីស៊ើបសួរដំណឹងពីខេមរា ។

ក្រោយពីសម្រាកបន្តិចនៅរាជធានី ភ្នំពេញ អ្នកទាំងពីរបន្តដំណើរទៅអង្គរ ។

ភ្នំពេញចាស់ទ្រុឌទ្រោម ក្រខ្វក់ គោកយ៉ាក មិនដូចភ្នំពេញពីដើមឡើយ ។ កាលពីមុនឆ្នាំ១៩៧០ ភ្នំពេញស្អាតល្អប្រណិត ជាទីក្រុងដ៏ល្អមួយនៅចុងបូព៌ាប្រទេស ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទៅដល់អន្តរ ភ្លាម ឆេទី នាងស៊ើបសួរមនុស្សម្នាដែលធ្លាប់ស្គាល់ៗ ភាគច្រើនស្លាប់អស់ក្នុងពេលសង្គ្រាម ។

ពេលព្រឹកព្រលឹម នាងធ្វើដំណើរម្នាក់ឯង ក្នុងព្រៃអន្តរ ។ នាងឈរនៅមុខព្រះអង្គខ្មៅ លើកដៃទាំងពីរប្រណម្យ បិទភ្នែក បណ្ដែតអារម្មណ៍ទៅឆ្ងាយ ទៅដល់អនុស្សាវរីយ៍ ជាដំបូងដែលនាងបានជួប ខេមរា ។

ឆេទី ឮសម្លេងមនុស្ស ដើរលើស្លឹកឈើក្រៀម និងលើមែកឈើ នាងក្រឡេកមើលឃើញមនុស្សម្នាក់ ពុកមាត់ស្រមាម ខោអាវរហែករយ៉ៃ ដូចមនុស្សសុំទាន ។

អ្នកនោះលូកដៃសុំទានឆេទី !

ឆេទី សំឡឹងមើលមុខជននោះ ឥតព្រិចភ្នែក! ពិស្ណុការមែនទេ?

ជននោះ ងក់ក្បាល ! ឆេទី នាងស្ទុះឱប ខេមរា ដោយត្រេកអរក្រៃពេក ។

ឱព្រះជាម្ចាស់! បងនៅរស់ទេ?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

បងអើយ! ម្ដេចឡើយ ជីវិតក៏វេទនាម៉េះ អូនគ្មានសង្ឃឹមបន្តិចសោះថាបានជួបបង!

អូនគ្មានសង្ឃឹមសោះថា បងនៅរស់រានមានជីវិត ។ រូបរាងបងដូរច្រើន តែអូនសង្ឃឹមថា ចិត្តបងនៅតែល្អដូចដើម ។ ជននោះងក់ក្បាល ។

ម្ដេចបានជាបង មិននិយាយស្ដីអ្វីសោះ? សង្គមជាក់ជាធ្វើឲ្យមនុស្សប្រែប្រួល មនុស្សចេះទៅជាល្ងង់ មនុស្សល្ងង់ធ្វើចេះ ។

ខេមរា ធ្វើសញ្ញាក្បាល ឲ្យធេវី នាងដើរតាមទៅឆ្ងាយពីមនុស្សម្នា ។

បងខេមរា ស្រុកស្រួលបួលឡើងវិញហើយ បងអាចនិយាយបាន ។ យើងមិនមែនរស់នៅក្នុងរបបខ្មែរក្រហមទៀតទេ?

ខេមរា ធ្វើភ្នែកឡឹងឡង់ ។ ព្រោះខេមរា រស់តែឯកឯងគ្មានដំណឹងអ្វីសោះ ពីការប្រែប្រួលនៃប្រទេសជាតិ ។

ទឹកភ្នែកហូរ! ស្រក់ពីកែវភ្នែក ខេមរា ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ធេវី នាងយកកន្សែងជូតទឹកភ្នែកឲ្យប្ដី ។

មួយសន្ទុះធំ ទើបខេមរា ចាប់ផ្ដើមនិយាយ!

ធេវី! នាងសុខសប្បាយជាទេ?

នាងមិនភ្លេចខ្ញុំទេ? ធេវីនាងស្រក់ទឹកភ្នែក ។

បង ខេមរា ! តើមានតែពាក្យនេះទេ ដែលបងភ័យព្រួយជាងគេ?

ពាក្យដែលអូនរង់ចាំជាងគេ គឺពាក្យថា បងនៅតែស្រឡាញ់អូនជានិច្ច។

ខេមរាចាប់ដើរស្រួលដូចមនុស្សធម្មតាបន្តិចម្ដងៗ ។ ពីមុន ខេមរា ធ្វើជាមនុស្សពិការ ឆ្កួតលីលា ។

ធេវី នាំខេមរា ជិះតាក់ស៊ី " taxi " ទៅសណ្ឋាគារ ដែលនាងស្នាក់នៅ ។

ដល់មុខទ្វារ អ្នកយាមទ្វារ មិនឲ្យ ខេមរា ចូលក្នុងសណ្ឋាគារ ។ មិនតែប៉ុណ្ណោះ គេនឹកស្មានថា ធេវីឆ្កួតទៀត ។

ធេវី! នឹកហួសចិត្ត នឹងចរិតអ្នកយាមទ្វារ ដែលស្ដាប់បញ្ជាពីលើ ធ្វើគ្មានគិតពិចារណា ។ នាងទូរស័ព្ទទៅប្រុង



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស៎ះ! នាងនិយាយជាភាសាបារាំង ជាមួយ ម្រ៉ូខ់ស៎ះ ដែលរង់ចាំនៅក្នុងបន្ទប់ ព្រោះនាងចង់បង្ហាញឲ្យឃើញថា នាងមិនមែនស្រីឆ្កួតទេ ។

រង់ចាំបន្តិច ម្រ៉ូខ់ស៎ះ ស្លៀកពាក់ស្អាត បាត អាវធំ បង ក្រវ៉ាត់ចេញមក ។

ឃើញខេមរា ភ្លាម ម្រ៉ូខ់ស៎ះ ស្ទុះទៅឱបដោយត្រេកអរពន់ពេក ។ រួច ម្រ៉ូខ់ស៎ះនិយាយបារាំង វាយឫក បញ្ចេញអំណាច ជាអ្នកធំ និយាយទៅកាន់អ្នកយាមថា៖ នេះជាភ្ញៀវកិត្តិយសរបស់ខ្ញុំ ។ ម្រ៉ូខ់ស៎ះបង្អួលទៅខេមរា ។

-ឯងមានក្រដាសកត់ទេ!

-អ្នកយាមងក់ក្បាល ទាញកូនសៀវភៅនិងខ្មៅដៃ ។

ម្រ៉ូខ់ស៎ះ និយាយយឺត ធ្វើយ៉ាងណា ឲ្យ អ្នក យាម ខ្ញារមានពេលគិតនិងនឹកភ័យខ្លាចអំណាចបារាំង ។

-ឯងត្រូវរកជាងកាត់ដេរ ដ៏ចំណាន ហើយឲ្យមកជួបយើងនៅបន្ទប់លេខ៦០៣ ។ ស្តាប់បានទេ?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

- ហើយឯងត្រូវទៅទិញស្បែកជើង ស្រោមជើង យកមកឲ្យយើងមុនម៉ោង១៦ថ្ងៃត្រង់ ។

- ហើយកុំភ្លេចរកជាងកាត់សក់មកផង ។

រួចប្រូទ្ធំសំហូតកាបូបទាញលុយ៥ដុល្លារហុចទៅឲ្យឆ្មាំទ្វារ ។ ក្នុងកាបូប ធ្វើឲ្យឃើញនូវក្រដាសប្រាក់ជាច្រើន ។

អ្នកយាមទ្វារអោនលំទោន ទទួលយកលុយ រួចចេញទៅបាត់ ។

ប្រូទ្ធំសំញាក់ភ្នែកដាក់ឆេទី និងខេមរា រួចនិយាយថា៖

ជាមួយខ្មែរ បានតែសំឡុត ៗ និយាយស្រួល និយាយពន្យល់ ស្តាប់មិនបានទេ ។ ឃើញគេមាន ឃើញគេសៀកពាក់ស្អាតបាត រាងកោងបន្តិច ខ្លាចគេជាងខ្លា ។

អ្នកទាំងបី នាំគ្នាចូលក្នុងបន្ទប់នៅក្នុងសណ្ឋាគារ សន្ទនាគ្នាពីរឿងដែលកន្លងផុតមក ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ធ្វើឆ្កួត

# ទើបរស់នៅស្រុកបាន

៙៙៙

ជ្រូកកើតនៅស្រុកចាម ជាជ្រូកដែលមានជីវិតរីករាយ។

ជ្រូកកើតនៅស្រុកចិន ជាជ្រូកដែលមានជីវិតខ្លោចផ្សា វេទនា...។

យើងរស់នៅយុគ ឆ្កួតលីលា ។ អ្នកចេះត្រូវធ្វើជាឆ្កួតទើបរួចរស់ជីវិត ។ អ្នកចេះរស់នៅស្រុកខ្មែរ ដូចជ្រូករស់នៅស្រុកចិន ដែលត្រូវគេយកទៅខ្វៃ ។

ខេមរាចាប់ផ្តើម និទានរឿងដែលកន្លងផុតទៅ ៖



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលដែលអ្នកទាំងពីរ ធ្វើដំណើរទៅស្រុកបារាំង (ប្រូច់សំះនិងឆេទី) កម្ពុជា រក់រី ក្នុងភ្លើងសង្គ្រាម ។

ខ្ញុំប្រញាប់ប្រញាប់ រៀបចំទុកដាក់ ឯកសារសំខាន់ៗ និងលាក់ទុកនូវរូបចម្លាក់ល្អ ដែលសាងពុំទាន់ចប់ ។

គ្រាន់តែ ប្រាសាទ បាពួនមួយ មានថ្មាំងសិលា ចំនួន ៣០០០០០ដុំ ដែលត្រូវផ្គុំផ្គុំឡើងវិញ ។

ថ្ងៃមួយពេលរសៀល ក្រោយពីចប់ ការងារ ហើយ ខ្ញុំ បំរុង នឹងវិលត្រឡប់មកគេហដ្ឋានវិញ ស្រាប់តែមាន យុទ្ធជន ខ្មែរក្រហម ជាច្រើន ដេញចាប់គ្នា យើង ដែលជា អ្នកថែរក្សាអង្គរ ។ ខ្លះរត់រួច ខ្លះត្រូវពួកវាចាប់បានចង ស្លាបសេក បណ្តើរយកទៅវាយចោល ។ និយាយឃាត់ អង្វរយ៉ាងណា ក៏ពុំព្រមស្តាប់ដែរ ។ ទាំងអស់៣០នាក់ត្រូវ វាចងយកទៅទីលានប្រជល់ដំរី ។ វាឲ្យយើងលុតជង្គង់ ។ វា ចាប់វាយម្តងមួយ ដូចគេវាយស្គរលេង ។ ខេមរា និយាយដោយញ័រ ស្រក់ទឹកភ្នែក រួចបន្ត! គួរឲ្យសង្វេគ ណាស់ ពេលដែលឃើញ គេវាយសម្លាប់សហការី ដែល



www.facebook.com/7khmer
Fb page : Entertainment And Knowledge

យើងស្រឡាញ់រាប់អាន និងមានចិត្តមុតតទល់ភ្លៀងខ្យល់ ការពារអង្គរ ។

អង្គរស្ងាត់ជ្រៀប សូម្បីតែរៃ ក៏ខ្លាច បារមីនៃមនុស្សព្រៃផ្សៃដែរ ។

ឈាមហូរ សម្រេងថ្ងូរ មុនពេលផុតជីវិត ។ កុលបុត្រខ្មែរអើយ! ព្រឹកមិញ អ្នកនៅរស់នៅឡើយ ។ ថ្វីត្បិតតែអ្នកបានឃើញ ពន្លឺនៃសេចក្ដីស្លាប់ពិតប្រាកដមែន ព្រលឹងអ្នក នឹងបែកផ្លូវ ពីខ្លួនអ្នក ។ មនុស្សម្នា ហៅថា សេចក្ដីស្លាប់ ។ អ្នកបានធ្វើអំពើល្អដល់អ្នកស្រុក អ្នកនឹងបានជួបទេព្ដា ជួយថែរក្សា អ្នក ។ ឯមនុស្សអាក្រក់នឹងចុះនរកអវចិមិនខាន ។

ភ្លៀងចាប់ធ្លាក់ខ្លាំងៗ ផ្គរលាន់ ឮយ៉ាងរន្ធត់ ផ្លេកបន្ទោរ ពាសពេញមេឃ ។ វា បន្តវាយសម្លាប់ ប្រញាប់ត្រឡប់ទៅកន្លែងវិញ ។

ខ្ញុំត្រូវវាវាយ ចុងក្រោយបំផុត តែវាមើលមិនឃើញ ព្រោះយប់ងងឹត ហើយភ្លៀងច្រើនទៀត ។ វាវាយត្រូវ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្មាខ្ញុំ ។ ខ្ញុំស្រែកដូចមនុស្សគេសម្លាប់ រួចវានាំគ្នារត់អស់ទៅ ។ បើវាវាយចំកញ្ចឹងក ខ្ញុំមិនរស់ទេ ។

ឈាម អ្នកជួសជុលអង្គរ ហូរ ជាបពោះ ដី នៃ សិលាចារឹក ។ ឈាមថ្មី ចារ ពីលើ ចារឹក ចាស់ ផ្តាំខ្មែរ ជំនាន់ក្រោយថា យើងរស់ឆ្កួតលិលា " ខ្មែរសម្លាប់គ្នា " ។ ខ្ញុំក៏សំរេចចិត្ត ធ្វើជាមនុស្សឆ្កួត ដើម្បីរស់បានមានជីវិត ។

ឆេទី ! យកដៃជូតទឹកភ្នែក រួចនិយាយថា ៖ មនុស្សបេះធ្វើ ល្ងង់ ធ្វើឆ្កួត មនុស្សល្ងង់ធ្វើបេះ ហើយបំពេញអំនួត "មហាលោតផ្លោះ" ។

ខេមរាបន្ត ! ក្រោយពីវាវាយសម្លាប់ ពួកយើងមក អង្គរស្ងាត់ត្រូវគេបោះបង់ចោល ។ រួចមកស្រុកខ្មែរត្រូវធ្លាក់ក្នុងកណ្ដាប់ដៃខ្មែរក្រហម ។

ខ្សែក ដែលមានកថា ចារការពារខ្លួន ដែលអូនប្រគល់ដល់បង ត្រូវពួកវាលួចយកទៅបាត់ ។

ឆេទីសួរ ! បងធ្វើដូចម្ដេច ដើម្បីរស់បានមានជីវិត?



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

-បងធ្វើជាមនុស្សឆ្កួត ម្តងយំម្តងសើច ច្រៀងរាំម្នាក់ឯង ដូចគេលេងល្ខោន ។

យំមានពីរយ៉ាង មួយយំចេញពីបេះដូង និងមួយយំពីក្បាល ។

ពួកដែលវាយសម្លាប់គ្នាយើង ត្រូវគេបញ្ជូនទៅសមរភូមិផ្សេងទៀត ។

ពួកថ្មីមកក្រោយ ឥតស្គាល់ឥតដឹងរឿងដើមឡើយ ។ ពេលគេស៊ីបាយ ខ្ញុំទៅឈរជិតគេ ជួនកាលគេឱ្យបន្តិចបន្តួច ជួនកាលគេដេញចេញឲ្យឆ្ងាយពីគេ ។

ពេលខ្លះខ្ញុំដេកឱបព្រះពុទ្ធរូប ឱបព្រះអង្គខ្មៅ ។ ខ្ញុំយំអាណិតខ្លួនឯង អាណិតស្រុក ទឹកដល់ឆេទី និងប្រទ្វង់សំរ ។

ក្មេងខ្មែរក្រហមខ្លះ វានោមដាក់លើព្រះពុទ្ធរូប នោមលើបងដែលដេកជិតនោះ ។

បងប្រាប់វាថា ៖ ឯងនោមដាក់លើរុក្ខជាតិ មានប្រយោជន៍ជាង ព្រោះដើមឈើត្រូវការទឹកនោមឯង ហើយរុក្ខជាតិនឹងអរគុណឯងផង ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្អាវានាំគ្នាសើច! អាម្នាក់និយាយថា៖

យី! អាឆ្កួតនេះ និយាយត្រូវ! រួចវានាំគ្នា សើចសប្បាយ!

ពេលទំនេរ បងដើររើសប្រមូលបារថ្មចំណាំ សម្រាប់ផ្ដុំសង់ឡើងវិញ ។ បងធ្វើជាឆ្កួតម្ដងៗ កុំឲ្យវាសង្ស័យ ។ ជួនកាលវាយកកាំភ្លើងបាញ់លើរូបចម្លាក់លេង ។ បងធ្វើជាឆ្កួតរួចនិយាយប្រាប់វាថា៖

នេះជារឿងរាមកេរ្តិ៍ ហនុមានច្បាំងជាមួយរាពណ៍ ។ វាស្លាប់បង្ហូរឈាម ។ បើអ្នកឯងបាញ់ឲ្យខូចអញ្ចឹង វាដាច់រឿងអស់ហើយ ។

វាយល់ រួចវាស្ដាប់!

ក្អាវាម្នាក់លាន់មាត់ថា យី អាឆ្កួតនេះនិយាយត្រូវម្ដងៗ ។ កុំតែឯងឆ្កួត អញយកទៅវាយចោលបាត់ទៅហើយ ។

ថ្ងៃមួយវាយកលោកសង្ឃទៅវាយចោល ។ លោកនិមន្តជាជួរ ដូចនិមន្តបិណ្ឌបាត្រ ស្បូត្រជម្ពូ ឥតឈប់ ។ វា



www.facebook.com/7khmer
Fb page : Entertainment And Knowledge

វាយព្រះសង្ឃ ម្តងមួយៗ រួចរុញទម្លាក់រណ្តៅ ។ លោកសង្ឃ ឈរសូត្រធម្មចាំវេនរៀងៗ អាត្មា ។

ទេវីអូនអើយ បងព្រឺខ្លួនណាស់ ។

បង អើយ! ស្រុក ចាប់ស្រួល បន្តិចម្តងៗ ហើយ មិនចាំបាច់ ធ្វើឆ្កួត ដើម្បីរស់ទៀតទេ ។ ចំពោះអូន បងជាមនុស្ស មានចំណេះ ជ្រៅជ្រះ ជាកូនទៀន មួយជួយបំភ្លឺកម្ពុជា ដែលរស់នៅក្នុងសភាព យប់ងងឹត ។

អំណើះតទៅ ប្រហែលជាខ្មែរ លែងសម្លាប់គ្នាទៀតហើយ?

ម្តាយចិញ្ចឹមបង ប្រពន្ធរបស់ ម្រួច់សំរ មីងចាណា បានអនិច្ចកម្ម ចោលយើងជិតពីរខែហើយ ។

គាត់ថាអូន មុខនឹងជួបបងនៅថ្ងៃណាមួយ មិនខាន ព្រោះព្រះជាម្ចាស់ មានភ្នែក ត្រចៀកទិព្វ ។ ព្រះអង្គមិនបណ្តោយឲ្យបងស្លាប់ទេ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

គាត់ជូនពរ យើងឲ្យមានកូនប្រកបដោយធម៌ និងទឹកចិត្ត ស្នេហាជាតិដ៏មោះមុតដូចបង ។ ប្រសិនណា កម្ពុជាមានមនុស្សដូចបងច្រើន កម្ពុជាមិនស្លាប់ឡើយ ។

បងខេមរា! អូននៅស្រឡាញ់បងដូចពេលមុន ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ជីវភាព

# នៅក្រុងប៉ារីស

ប្រឹងសំរេចចិត្តខំគ្រប់ប្រកល្អក បារាំងផងខ្មែរផង ធ្វើយ៉ាងណា យកខេមរា ចេញពីស្រុកខ្មែរ ទាល់តែបាន ។

យើង រីករាយ ណាស់ មករស់ នៅ ជាមួយ គ្នានៅប៉ារីស ។

ខេមរា រមែងទៅជួយធ្វើការ ឆទីនៅ ភោជនីយដ្ឋាន ឯ សង្កាត់ទី១៣ ដែលក្រោយមក គេឲ្យឈ្មោះថា ទីក្រុងចិន China town ។

www.facebook.com/7khmer

Fb page : Entertainment And Knowledge

ពេលទំនេរ ឆេរីរមែងនិយាយ រឿងជនភៀសខ្លួនខ្មែរ ដែលរស់នៅស្រុកបារាំងប្រាប់ដល់ខេមរា ។ ជនភៀសខ្លួនចែកជាបីផ្នែក ៖

១-អ្នកបេះដឹង អ្នកដែលរៀនសូត្រ បានសញ្ញាប័ត្រ ដូចជាគ្រូពេទ្យ ឱសថការី វិស្វករ ។ល។ អ្នកទាំងនេះ ប្រកបចិញ្ចឹមជីវិត ជួនធ្វើការឲ្យគេ ជួនបើកគាប៊ីណេពេទ្យ ឬបើកហាងលក់ថ្នាំ ។ ជីវភាពគេ លើសពីមធ្យម ល្អប្រសើរ ។

២-អ្នកបេះល្មមៗ រដ្ឋការខ្មែរពីដើមទាហានគ្រូបង្រៀន ។ល។ ក្នុងផ្នែកនេះ មានមនុស្សច្រើនជាងគេ ។ គេរកស៊ីបើកតាក់ស៊ី បើកភោជនីយដ្ឋាន ដេរខោអាវ ។ល។

៣-អ្នកមិនបេះអ្វីសោះ បេះតែនិយាយរកាក់រកុប ។ របររកស៊ីរបស់គេ គឺស៊ីឈ្នួលប្រើកម្លាំង ដូចជាកម្មករ បោសជូតផ្ទះឲ្យគេ មើលកូនឲ្យគេ ។ល។

ខ្លះទៀតរកស៊ីលក់មាសពេជ្រ លក់តាមផ្ទះ ។ របរនេះមានការបោកប្រាសគ្នាមិនតិចដែរ ។ បន្លំគ្រាប់ពេជ្រ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឲ្យចិន ម៉ូដ អាវថ្មី និង សាច់ក្រណាត់ ថា ខ្លួន ចង់ បាន អាវ ១០០០អាវ ក្នុងបីថ្ងៃ ។

ចិនយកម៉ូដអាវនិងក្រណាត់ បោះឲ្យខ្មែរ ដេរតាមផ្ទះ ៗ ក្នុងរយៈបីថ្ងៃ ខ្លះដេរ អត់បាយ អត់ទឹក ឲ្យបាន ចំនួន គ្រប់គ្រាន់ឲ្យគេ ។ ចិនប្រមូលអាវ នេះដេររួច ហើយ យក ទៅឲ្យសាសន៍ហ្សីវ នោះវិញ ។

សាសន៍ហ្សីវ យកអាវ នោះ ទៅបោះ ដាក់លក់ តាម ទីផ្សារ នានា ។ ជួនកាល អាវនោះលក់មិនដាច់ ដោយ ម៉ូដពុំត្រូវការនិយមរបស់គេ ។ ហ្សីវ នោះរលំជួញ ឥតមានលុយឲ្យចិន ។ ចិន ឥតមានលុយ ឲ្យខ្មែរ ។ អត់លុយ តៗគ្នា ។

របរ រកស៊ី ផ្សេងទៀត ក៏មាន លំនាំ ប្រហាក់ប្រហែលគ្នា ដែរ ។ ខ្លះ រកស៊ី ដោត អង្កាំ តាមផ្ទះ ៗ របរ ទាំងនេះជារបរ លួចលាក់ ព្រោះយើង ធ្វើការ ឥត បង់ពន្ធ ឲ្យរដ្ឋ ។ ជួនកាល រដ្ឋ មក ឆែកឆេរ ដល់ផ្ទះ រក ម៉ាស៊ីនដេរ ។ បើឃើញ គេ ចាប់ផាក ពិន័យ ជាប្រាក់ ព្រោះយើង រកស៊ី ឥតប្រកាសប្រាប់រដ្ឋ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ក្រោយមក អ្នករកស៊ី ទាំងប៉ុន្មាន បោះបង់ចោលរបរទាំងនេះ មកចាប់របរ ភោជនីយដ្ឋានវិញ ។

តើឆេទីបានលុយពីណាមក មកបើកហាងលក់ម្ហូប ដូចនេះ?

អូនលេងតុងទីន! អូនអង្វរឲ្យគេជួយលេង ។ អូនធ្វើមេតុងទីន ៤ ឬ ៥ ក្បាល យកដើមទុន ព្រោះយើងឥតចេះអី ដូចខ្ញុំបារាំង គេមិនឲ្យខ្ចីលុយទេ ។ ឆ្លៀតឱកាសនេះ អូននិទានរឿងជំរាបបង ពីដើមពេលដែលអូន មកដល់ស្រុកបារាំង ។

ប្រូង់ស៊ី ឈឺនៅគេងមន្ទីរពេទ្យ ៤ ខែ ។ ខ្ញុំជាមួយ មីងមាលា សំណាក់នៅផ្ទះគេសិន ទំរាំ រកជួលផ្ទះបាន ។ រាល់ថ្ងៃយើងនាំគ្នា ទៅមើល ប្រូង់ស៊ី ។ តែប្រាក់ខែប្រូង់ស៊ី ពុំអាចធានាចិញ្ចឹម និងផ្គត់ផ្គង់សេចក្ដីត្រូវការ របស់យើងបានឡើយ ។

ពិបាកចិត្តណាស់បងអើយ! បងក៏បាត់ដំណឹងឈឹង ។ ចេញពីផ្ទះ ឃើញសុទ្ធតែបារាំង គេឥតស្គាល់យើង យើង



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឥតស្គាល់គេៗ នៅស្រុកខ្មែរ មានមា មានមីង ពូ ជិតខាង សុំទៅហៅមក រកជីរ រកស៊ីក ត្រៃបាន ៗ ស្រុកនេះទៅ រកឯណា សុំអ្នកណា? ម្នាក់ៗ ប្រឹងរៀងខ្លួន នៅតែរក អង្ករ ដោយពិបាក ៗ ពេលដែលឃ្វង់សំះ ជូរស្រោល បន្តិច អូនដើរមើលគេ មើលឯង អូនទៅស៊ីឈ្នួល មូរ បាយ៉ ឲ្យ គេ រួបជួយ ធ្វើម្ហូប ទៀតៗ ម្ចាស់ហាង ដែលជាអ្នកមាន នៅស្រុកខ្មែរ ពីដើមគេសល់លុយ គេសល់គាត់ច្រើន ព្រោះគេដឹងស្ថានការណ៍មិនស្រួល គេប្រមូលលុយប្រមូល គាត់ ជញ្ជូនកូន ជញ្ជូនចៅ មកនៅស្រុកបារាំង ទាំងអស់ គ្នា ៗ គេបើកភោជនីយដ្ឋាន មួយ តែដំបូងឡើយ គាត់ ពុំសូវប្រសប់ធ្វើម្ហូប ៗ លុះដល់បានអូនមកជួយ គាត់ ត្រេកអរណាស់ ៗ មនុស្សម្នាមកច្រើន គាត់បើកហាង មួយទៀត សម្រាប់កូនស្រីរបស់គាត់ ចូលគ្នាជាមួយអូនៗ

ខេមរា និយាយ! ខ្ញុះថា កុំឲ្យរកស៊ីចូលគ្នា ៗ និយាយ ដូចនេះក៏ត្រូវ ម្យ៉ាង តែបើយើងទាំងពីរនាក់ ស្មើរ ដោយ ខ្លួន ទាល់តែផ្គុំគ្នា ទើបកិច្ចការកើតបាន ៗ ហើយយើង



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ត្រូវមានចិត្តស្មោះនឹងគ្នា ទៀត កុំចង់បានរបស់គេពេក ៗ ស្គាល់ខ្លួនឯង ស្គាល់សមត្ថភាពឯង ៗ

អូនឥតមានលុយឥតដើមទុន តែអូនមានជំរេះធ្វើម្ហូប ៗ

និយាយមកដល់នេះឆើ ! នាងទុចស្ងៀម មួយសន្ទុះ ៗ នាងនឹកថា ! កាលពីដើម គ្រូបង្រៀនម្នាក់មកដណ្ដឹងនាង លុះដល់ឪពុកបាត់ខ្លួនទៅ ហើយគ្រួសារបុះក្រ គេជូនពាក្យវិញ ៗ

ឥឡូវមានគេដៃទៃច្រើនចង់បាននាង កូនអ្នកមានទៀត ដូចកូនថៅកែនាងជាដើម ៗ តែនាងនិយាយដោះសារថា ចាំជំណឹង និងចាំបងប្អូនស្រុកខ្មែរ សិន ៗ ព្រោះនាងនៅ មានបងប្អូនច្រើននាក់ទៀត ដែលត្រូវនាងយកចេញពីស្រុកខ្មែរ ៗ

ឯឡុង ជាបណ្ឌិតខាងច្បាប់ ក៏សុំរៀបការជាមួយនាងដែរ ៗ

បងឡុង អើយ ! អូនអរគុណបងច្រើន ដែលស្រឡាញ់ រាប់អានអូន ចង់រួមរស់នៅជាមួយគ្នា ៗ តែអូនមានគូ

www.facebook.com/7khmer

Fb page : Entertainment  And Knowledge

ទៅហើយៗ សមត្ថភាពបង ជំរេះបង សម្ផស្សបង ខ្ពង់ខ្ពស់ល្អ គួរឲ្យស្នេហា តែបេះដូងអូន បានប្រគល់ដល់បងខេមរាទៅហើយ ! អូនមិនអាចក្បត់បងខេមរាបានទេ ប្រសិនណាជាអូនមិនដឹងការពិតៗ

អូន នឹកឃើញអនុស្សាវរីយ៍នានា បារាយណ៍ទឹកថ្លា តាព្រហ្ម បន្ទាយស្រី បក្សីចាំក្រុង ភ្នំក្រោម ។ល។ ពេលល្ងាចយើងអង្គុយពីរនាក់ មើលថ្ងៃលិចៗ ប្រាសាទប្រែរូប ទៅតាមពន្លឺថ្ងៃៗ មិនមែនតែយើងទេ ពីរនាក់ដែលមើល សម្ផស្សធម្មជាតិ នៅលើមែកឈើធំៗ ក៏មានស្វា អង្គុយជាជួរ មើលថ្ងៃលិចដែរ ដោយស្រណោះអាឡោះអាល័យ !..

គេនិយាយថា កាលជំនាន់ដើម មនុស្សម្នា ភិតភ័យណាស់ នៅពេលថ្ងៃលិចម្តងៗ ។ គេភ័យខ្លាចថ្ងៃមិនរះឡើងវិញ ។ តែឥតថ្ងៃហើយ មនុស្សម្នា សត្វនានា ព្រៃព្រឹក្សា ច្បាស់ជាស្លាប់មិនខានឡើយៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានមនុស្សព្រៃ នៃតំបន់ខ្លះ នាំគ្នាលេងភ្លេង រាំច្រៀង ឲ្យព្រះអាទិត្យសប្បាយចិត្ត ឲ្យព្រះអង្គចាប់វិលវិញ ។

អូនសូមអភ័យទោស! បងគ្មានលក្ខណៈអ្វីធ្គាំធ្គង ។ បងមានជំរេះវិជ្ជា ខ្ពង់ខ្ពស់ បងអាចរើសរក នារីណាផ្សេងទៀត ដោយមិនលំបាក ។ អូនសូមជូនពរបង សូមជួបនឹងនារីណារម្យទម ស័ក្តិសមនឹងតំរេះបង។

ឆេទីនាងនឹកក្នុងចិត្តថា ពេលដែលយើងតូចកែ ពេលដែលយើងភ្លី សត្វផ្សេង រមែង ហោមរោម ពន្ទី ជាពុំខាន ។ មិនចាំបាច់ពន្ទី ឪពុកម្តាយទេ ។

ឆេទីបន្ត! លុះដល់យើងចេះធ្វើការ មុខងារចេះស្ទាត់ហើយ យើងក៏បំបែកគ្នា ទៅបើកហាងនេះ សម្រាប់ខ្លួនឯងទៅ ។ ឯគាត់ទៅបើកកន្លែងផ្សេងទៀត។

មុនដំបូងលំបាកខ្លាំង ជាពិសេសរកមនុស្សមកធ្វើការ ។ មនុស្សចេះហើយទៀងត្រង់។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

នាងចន្ថា កូនលោកសក្តិប្រាំ ប៉ូលិស ពីដើម មកជួយធ្វើការឲ្យអូនៗ ផ្ទះជាប់របងគ្នា ទៅរៀនសាលាជាមួយគ្នាៗ លុះដល់អូនបាត់ឪពុកទៅ គេលែងទាក់ទងនិងយើងខ្ញុំៗ ខ្ញុំក៏មិហ៊ានទាក់ទងនិងគេដែរៗ គេជិះឡាន គេមកស្រុកបារាំង បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារមកៗ ឪពុកមានលុយហូរហៀរ ផ្ញើឲ្យកូនបាយ នៅស្រុកបារាំងៗ

តែដល់ស្រុកធ្លាក់ ក្រោមរបបខ្មែរក្រហម ទៅ ស្បៀងពីភ្នំពេញ ក៏រីងហួត នាងត្រូវ ត្រដរប្រវេប្រវា រកការងារធ្វើៗ ថ្ងៃមួយ យើងជួបគ្នា ក្នុងរូង មេត្រូ (រថភ្លើងក្រោមដី)ៗ អូនហៅគេមុន ព្រោះអូនមិនប្រកាន់ឡើយៗ ចរិតធម្មតា នៃកូនអ្នកមាន នៅស្រុកខ្មែរ ត្រូវតែបញ្ចេញឫកឲ្យខុសពីគេ ៗ អូននិយាយ លេងរំលឹក កាលពីនៅវ័យកុមារភាព តែអូនមិននិយាយពីពេលដែលគេមានហើយយើងក្រទេ ៗ ការដែល គេ មើលងាយ នេះ ហើយ ដែលធ្វើឲ្យយើងខំកសាងខ្លួនយើងៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែចន្ថា ខ្វះការពិសោធន៍ច្រើន មិនមែនខ្វះសមត្ថភាពទេ ។ តែនាងពុំព្រមរៀន ពុំព្រមយកចិត្តទុកដាក់ តាំងពីតូចមក ដល់ធំ ឡើងរឹតតែខ្វះខាត ។

និយាយបារាំង ក៏មិនពិរោះទៀត គំរោះគំរើយ ខ្វះការគួរសម ។ នៅស្រុកខ្មែរ យើងយល់ថា ឲ្យតែឪពុកម្ដាយ មានបុណ្យ មានលុយ កូនស្រីមិនចេះអ្វី ក៏មិនសល់ដែរ ។

ស្ដាយណាស់ ស្អាតតែសំបកក្រៅ មិនល្អឯខាងក្នុង ។

ក្រោយមក មានគេស្គាល់ចន្ថា គេលួចនិយាយប្រាប់ខ្ញុំថា ចន្ថាមានវិបត្តិផ្លូវចិត្តនឹងប្រុសម្នាក់ ។

ឪពុកម្ដាយចន្ថា បានចិញ្ចឹមក្មេងប្រុសម្នាក់ រៀនខាងបណ្ឌិតវេជ្ជសាស្ត្រ សំរាប់ទុករៀបការ ជាមួយចន្ថា នៅថ្ងៃក្រោយ ។

ពេលដែល រៀនជិតចប់ បុរសនោះទៅ ការជាមួយកូនឧត្តមសេនីយ មានលុយ មានឋានន្តរៈសក្តិ ខ្ពស់ជាង



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឪពុកម្ដាយចន្លាះទៀត ។ ឪពុកម្ដាយចន្លា ប្រាក់ក៏បង់ ថង់ក៏ដាច ពុំហ៊ានត្រហែមតទល់នឹងគេឡើយ ។

បងអើយ ! មនុស្សនិងប្រាក់ យក្សនិងសាច់ៗ រឿងរបៀបនេះ មានច្រើនណាស់ នៅក្នុងសង្គមខ្មែរ មិនមែនជារឿងគូព្រេង ឬវាសនាឡើយ ។ រឿងប្រាក់ជាធំ កូនក្រមុំជាក្រោយ ប្រាក់ដល់ហើយ ទ្វារបើកឯងៗ តែហួសពេលអស់ហើយ ។

ក្នុងជីវិតម្នាក់ៗ មានវ័យរបស់គេ ។ វ័យកុមារ វ័យសិក្សា វ័យស្នេហា វ័យរកលុយ វ័យរកធម៌អាថ៌ វ័យធ្វើអាចារ្យ ។ល។

បើយើងមិនគោរពពេលវេលា តាមលំដាប់លំដោយទេ បាយបិណ្ឌ ជាបាយបាត្រហើយ រួចជីវិតពិតជាមានបញ្ហាទៅថ្ងៃក្រោយ ។

ខ្មែរយើងប្រឡំស្នេហា និងស្នេហ៍លុយ ។

ខេមរា ដកដង្ហើមធំ ហាក់ដូចជាជួយព្រួយ ដល់ចន្លា រួចបន្ទឺវាចាថា៖



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ធ្វើម្តេចបើសង្គមយើងយ៉ាងដូចនេះទៅហើយ ។ យើងឃើញក្នុងរឿងទុំទាវ ជារឿងស្នេហាពិត មែន ពុំមែនស្នេហ៍លុយ ស្នេហ៍បុណ្យសក្តិនោះឡើយ ។

ឱទីបន្ត! រឿងដែលពិបាក ក្នុងរបររកស៊ីទទួលទាន គឺរកមនុស្សទុកចិត្ត ។

មានអ្នកធ្វើការខ្លះ ពេលយើងមិននៅលួចទឹកត្រី លួចប្រេង ។ល។ មានម្នាក់លួចកាត់សាច់គោ ដាក់ក្នុងថង់ រួចបោះបោលក្នុងធុងសម្រាម ដល់ពេលផុតម៉ោងធ្វើការ ទៅយកសាច់គោទៅផ្ទះ ។ តែមនុស្សទាំងនោះ មុជមិនជ្រៅ ទៅមិនឆ្ងាយឡើយ ព្រោះតែខ្វះការទុកចិត្តហើយ មនុស្សនេះឥតមានតម្លៃឡើយ ។

អ្នកដែលមកកាន់ភោជនីយដ្ឋាន គឺមកដោយសប្បាយ ចង់ប្តូរបរិយាកាស ដូចនេះ យើងត្រូវតម្រូវចិត្តអ្នកទាំងនោះ តាំងពីម្ហូបអាហារ ការទទួលភ្ញៀវ សម្តីសំដៅ ។ល។ គេយកលុយមកឱ្យយើង យើងត្រូវតែទទួលរាក់ទាក់ស្និទ្ធភាពគ្នា ទោះជាអ្នកមានក្តី អ្នកក្រក្តី ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ត្រូវឲ្យស្អាត ព្រោះគេយល់ថា បើបង្គន់មិនស្អាត ហើយ ចង្ក្រានរឹតតែក្រខ្វក់ ជាងនេះទៅទៀត ។ នៅស្រុកគេ ពុំមានរុយ ដូចស្រុកយើងទេ តែអាចមានកណ្តុរ កន្លាត នាំការមិនស្អាត ស្មោគគ្រោក បម្លងរោគផ្សេងៗ ។ល។

ម្ហូបត្រូវតែគ្របទុក រៀបចំទៅតាមរបៀបអនាម័យ ព្រោះមានក្រសួងសំអាតមកត្រួតពិនិត្យ ក្រែងយើងធ្វើមិនត្រូវតាមច្បាប់ក្បួន ។

មានភោជនីយដ្ឋានខ្លះ បើកហើយ ត្រូវបិទទ្វារទៅវិញ ព្រោះគ្មានមនុស្សចូលទទួលទាន ។ ព្រោះអ្នកដែលបើក ពុំពូកែធ្វើម្ហូប បេះបន្តិចបន្តួច ឆាឆួរ ឲ្យរួចតែពីដៃ ។ ម្យ៉ាងទៀតត្រូវបេះសំបៃ កែឆ្នៃរបស់សេសសល់ខ្លះឲ្យរឹតតែមានគុណភាពឡើងៗ បើបងចូលហាង ឆេទីបន្ត! ប្រយ័ត្ននឹងពាក្យថា "plats du jour" ម្ហូបសម្រាប់ថ្ងៃនេះ ព្រោះគេច្រើនយករបស់ដែលសល់ មកកែឆ្នៃ លក់ឲ្យអស់ ។ ម្ហូបដែលអាចឆ្ងាញ់គឺ ម្ហូបពិសេសរបស់ហាង "spécialité de la maison" ដែលមានរសជាតិ ព្រោះត្រូវធានាឈ្មោះ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហាងរបស់គេ ។ ចៀសវាងកុំសួរ អ្នករត់តុ តើអ្នកជួយប្រាប់ខ្ញុំបានទេ ម្ហូបណាឆ្ងាញ់ជាងគេ ? ព្រោះអ្នករត់តុទទួលបញ្ជាពីថៅកែ ប្រាប់ម្ហូបណាដែលខ្លួនត្រូវលក់ចេញដាច់ ។ បើពុំដូច្នោះទេ វាប្រាប់ម្ហូបណាដែលវាចូលចិត្ត តែពុំត្រូវចំណង់យើងឡើយ ។

ខេមរា សួរ ! ហេតុដូចម្តេចបានជាយើង សរសេរដាក់ថាភោជនីយដ្ឋានម្ហូបចិន និងថៃ មិនដាក់ម្ហូបខ្មែរ ។

ធេវី ឆ្លើយ ! ម្ហូបដែលឆ្ងាញ់ពិសា នៅលើលោកិយយើងនេះ គឺម្ហូបចិន ម្ហូបបារាំង និងម្ហូបអ៊ីតាលី ។ ហេតុដូចនេះហើយបានជា ខ្ញុំដាក់ភោជនីយដ្ឋាន ម្ហូបចិន ។ ការដែលយើងស្រឡាញ់ជាតិ ជារឿងមួយ៉ាង រឿងរកស៊ីជារឿងមួយ៉ាង មិនត្រូវលាយឡំជាមួយគ្នា ។ ដល់យើងបានលុយច្រើន យើងជួយជាតិយើង ។

ធេវី នាងនិយាយសើច! ថ្ងៃមួយខ្ញុំឃើញហាងបោកខោអាវខ្មែរ នៅអាមេរិក សរសេរយីហោធំៗ ដាក់ថា " ហាងបោកខ្មែរ" ព្រោះបើដាក់បោកខោអាវវាវែងពេក ។ គ្រាន់



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែឃើញយីហោថា "ហាងបោកខ្មែរ" ខ្មែរភ័យខ្លាចបាត់ខោគាត់ ឥតហ៊ានយកទៅបោកនៅហាងនោះឡើយ ។

ឆេទីនិងខេមរា រកស៊ីបានចំរើនខ្លាំង ។ នាងបានធានាយកបងប្អូន នាងចេញពីជំរំ ទៅអ៊ុីដាង ជាបន្តបន្ទាប់គ្នា ។ នាងជួយផ្គត់ផ្គង់បង្ហាត់បង្រៀន ឲ្យចេះធ្វើម្ហូប ឲ្យចេះរៀបចាន វៀបកែវ ចេះទទួលភ្ញៀវ ចេះរបៀបចាត់ចែងកិច្ចការផ្សេងៗ ។ ពេលដែលចេះហើយ នាងបំបែកឲ្យទៅកាន់កាប់ភោជនីយដ្ឋាន រៀងខ្លួនៗ

ភោជនីយដ្ឋានជាការនឿយហត់និងរវល់ច្រើន ព្រោះត្រូវនៅដល់ពេលយប់ជ្រៅ ម៉ោង១យប់ស្ទើររាល់ថ្ងៃ ។ តែធ្វើដូចម្តេច ព្រោះយើងជាជនភៀសខ្លួន ។ ទោះជាមានសញ្ញាប័ត្រធំ ដូចបងឡុង ជាដើម ក៏ពិបាករកការធ្វើដែរ ព្រោះបារាំងគេឥតត្រូវការយើងទេ ។ អ្នកចេះគេមានច្រើនសន្ធឹកសន្ធាប់ ។ បើមានការធ្វើ ប្រាក់ខែ ក៏ពុំច្រើន ។

អ្នកដែល មកស្រុកបារាំង មិនមែន សុទ្ធតែមានសិទ្ធិអាចធ្វើការបាន នោះទេ ។ អាចធ្វើការបាន លុះត្រាតែ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មាន អត្តសញ្ញាណ ប័ណ្ណ ធ្វើការងារ " carte de travail " ។ និស្សិត ពុំមានសិទ្ធិ ធ្វើការទេ ។

ខេមរា នឹកក្នុងចិត្តថា ៖ នៅស្រុកខ្មែរ ស្ត្រីជាជំនួយបុរស តែប៉ុណ្ណោះ ។ តែមកដល់ស្រុកបារាំង ស្ត្រីអាចបង្ហាញនូវ សមត្ថភាព ដែលខ្លួនមាន ខ្លះពូកែជាងបុរសទៅទៀត ។ ឆេទី នាងជួយសំរួលច្រើនដល់ជីវិតគេ តែនាងពុំដែលមានពាក្យ ជំលើសលោះទៅលើខ្លួនម្តងណាឡើយ ។

ខេមរា ឃើញឆេទី រឹតតែស្អាតឡើង ។ សម្ផស្ស ស្ត្រី គឺ កិរិយាទន់ភ្លន់ សំដីផ្អែមល្ហែម ត្រជាក់ដួងចិត្ត ដូចទឹកអម្រឹត ។

ខេមរា នឹកឃើញពេលដែលគេជួបឆេទីជាដំបូង ។ នាង មានរូបសម្បត្តិ និងចរិយាល្អ សមរម្យជាទីគាប់ចិត្ត ។ ចំពោះខ្ញុំ គុណសម្បត្តិទាំងនេះគ្រប់គ្រាន់ហើយ ។ អ្នកខ្លះ ដែលប្រាថ្នាឡាន ឬមាសពេជ្រ របស់មិនឋិតថេរ ត្រូវភ្លើង សង្គ្រាម បំផ្លាញអស់ ។ សម្បត្តិឆេទី នៅជាប់នឹងខ្លួននាង នាងអាច យកមកប្រើប្រាស់ នៅគ្រប់ពេលវេលា និងគ្រប់ កាលៈទេសៈ ។ ឥឡូវ ឆេទី មានលុយ មានសម្បត្តិច្រើន


Fb page : Entertainment And Knowledge

តែនាងនៅតែគោរពខ្ញុំជាប្ដី មិនស្រដីធំធាត់ ក្អាត់សម្ដេង ដូចស្រីគេឯង ឯទៀត <<ឫកឡើងតាមទឹកលុយ>> ។ ខ្ញុំខ្ជាប់ចិត្តនាងទៅវិញទេ ព្រោះរស់ដោយសារគេទាំងស្រុង ។ នេះហើយឬ ដែលគេហៅថា វាលវត្តសង្ក្រារ? ក្រឡាប់ផ្កាប់ផ្ងារ ក្បាលចុះក្រោម ជើងឡើងលើ?



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# វិលទៅរស់នៅ
# ស្រុកកំណើតយើងវិញ

ពេលបុណ្យទានម្តងៗ បងប្អូនឆេទី នាំគ្នា មកជួបជុំគ្នា ផុតសាច់ ទទួលទាន នៅផ្ទះឆេទី ។ នាងមានផ្ទះធំ មានដីទូលាយ សម្បូណ៌ ដោយបុប្ផា កុលាប និងផ្កា ផ្សេងៗទៀត ។

បងប្អូនទាំងឡាយ អរគុណ ដល់ឆេទី ដែលជួយ ជ្រោមជ្រែង ឲ្យមានរបររៀងខ្លួន ។ អ្នកទាំងនោះ ដឹងថា នៅស្រុកគេ ត្រូវរស់ដោយកម្លាំងថាមពល ខ្លួនឯង ម្លប់ឪពុកម្តាយ គ្មានឥទ្ធិពលអ្វីឡើយ ។ បងស្រីជីដូនមួយ ជាប្រពន្ធ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

គយ ពីដើម នៅស្រុកខ្មែរ ឥតធ្វើអ្វីទេ ឈ្នួលធ្វើទាំងអស់ ។ មកដល់ស្រុកបារាំងត្រូវដកផ្លាកលោកស្រីចេញ មូរដៃអាវ លាងចាន ធាឈ្នួរ ឡើងផ្សារ បោសជី ជូតកញ្ចក់ ។ ឯប្ដីវិញ ក៏ដូចនេះដែរ ដកផ្លាក តេជគុណចេញ ជូតតុ រៀបតុ រៀបចាន ដាក់ចង្កឹះ ស្លាបព្រា រត់តុ ចាក់ស្រាឲ្យភ្ញៀវ ។ល។

អ្វីដែលយើងធ្លាប់មើលងាយ គេពីដើម ឥឡូវធ្លាក់មកលើខ្លួនយើង ម្ដងវិញ ។ ពេលដែលគេជាន់ជើងយើង ទើបយើងដឹងថា ឈឺយ៉ាងណា ព្រោះកាលដែលយើងរស់នៅស្រុកខ្មែរ យើងជាន់ជើងគេ ។

ថ្ងៃមួយឆេទីមានជម្ងឺជាទម្ងន់ នាងឈឺបេះដូង ។ នាងត្រូវទៅគេងនៅមន្ទីរពេទ្យ ឲ្យគេដូរដាក់បេះដូងថ្មី ។ ពេលដែលដូរបេះដូង ឈាមត្រូវគេបញ្ជូនទៅក្រៅ ចូលក្នុងម៉ាស៊ីន រួចបានរត់ចូលមកក្នុងខ្លួនវិញ ។

នាងដូចជាស្លាប់ហើយ ហើយត្រូវគេប្រស់ឲ្យមានជីវិតឡើងវិញ ។ ជីវិតថ្មី គំនិតថ្មី ធ្វើឲ្យនាងរិះគិតវែងឆ្ងាយដល់បញ្ហាជីវិត ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នាងនឹកដល់ម្ដាយ ពេលដែលមានជម្ងឺ លក់ផ្ទះ លក់ដី លក់អ្វីៗ ដែលខ្លួនមាន ដើម្បីមើលខ្លួន ។ គ្រួសារធ្លាក់ក្រ ដោយសារជម្ងឺ ។

ឥឡូវ នាងមានអាយុស្មើនឹងម្ដាយ នាងបាក់ឈឺ ឈឺធ្ងន់ ជាងម្ដាយទៅទៀត តែនាងឥតមានបង់ប្រាក់សោះ ឡើយ ព្រោះនាងមាន Sécurité sociale - គ្រួសារនាង ឥតមានទទួលរងបាបកម្មដោយសារជម្ងឺនាងឡើយ ។

ឱកាលណាទៅ ទើបស្រុកយើង មានច្បាប់ដូចស្រុក គេ? ច្បាប់នេះមានដំឡៃជាងធ្វើបុណ្យ ១០វត្តទៅទៀត ។ នាងស្រក់ទឹកភ្នែកនឹកដល់ម្ដាយ នឹកដល់បងប្អូនខ្មែរ ខ្លះ ឈឺ ពុំហ៊ានទៅពេទ្យទៀត ព្រោះពេទ្យថ្លៃហួសហេតុ ។ នាងនិយាយទៅកាន់ខេមរា ។

បងខេមរា ! ក្នុងរយៈពេលដ៏ខ្លីនេះ យើងរកស៊ីមាន បានច្រើន ។ តែពេលនេះ ពេលដែលឈឺធ្ងន់ ហើយជា ឡើងវិញ អូនក្រឡេកមើលជីវិត ដោយរបៀបម្យ៉ាង ។ ពេលដែលជិតស្លាប់ អូនដឹងថាលុយពុំមានប្រសិទ្ធភាពដូច



www.facebook.com/7khmer
Fb page : Entertainment And Knowledge

យើងស្មានទោះទេ ។ ពេលដែលឈឺធ្ងន់ របស់សំខាន់ គឺគ្រូពេទ្យចំណាន ។ ដូចនេះស្រុកយើងត្រូវខិតខំ ធ្វើយ៉ាងណាឲ្យពេទ្យ ខ្លាំងពូកែ ឲ្យខ្មែរម្នាក់ៗមានសង្គមនិរភ័យ Sécurité sociale ។

បើបងមិនយល់ទាស់ទេ ពេលដែលអូនជាទៅ អូននឹងសុំបងទៅរស់នៅស្រុកខ្មែរវិញ ទៅជួយកសាងស្រុកយើងតាមដែលអូនអាចធ្វើបាន ។

យើងវិលមកស្រុកបារាំង ម្តងៗ មកឲ្យពេទ្យពិនិត្យ ព្រោះពេទ្យបារាំងពូកែជាងពេទ្យខ្មែរយើង ហើយនិងមកមើលកូនផង ។ យើងទុកកូនទាំងពីរ ឲ្យនៅរៀនស្រុកបារាំង ។ យើងខិតខំជួយ ធ្វើយ៉ាងណាឲ្យស្រុកយើងមានសាលាល្អ និងពូកែ ។ ប្រទេសណា ដែលមានសាលាល្អ ប្រទេសនោះហើយ នឹងចំរើន ទៅថ្ងៃមុខ ។ ត្រូវបណ្តុះពូជល្អ ពីឥឡូវនេះទៅ ។ បើយើងព្រួតគ្នា សន្មតរួមប្រឹងធ្វើល្អ ជួយជាតិយើង ដល់ចៅយើងស្រុកបានល្អត្រឹមត្រូវ ហើយ ។ ខ្មែរអើយ! ខាំមាត់បន្តិចទៅ ដើម្បីបានល្អ រស់នៅជាមួយ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

គ្នា ។ យើងធ្លាប់ពិបាក ធ្លាប់វេទនា យើងត្រូវបៀសបៀប នេះទៀត។ តែពុំនោះ វានឹងវិលមកវិញទៀតហើយ ។

គំរោងរបស់អូនដូចតទៅ៖

យើងទៅនៅម្តុំខេត្តសៀមរាប។ បងនឹងបន្តកិច្ចការរបស់បង ជួយរក្សាប្រាង្គ ប្រាសាទអង្គរ ឲ្យល្អឡើង ។ ជួយមើលថែទាំរក្សា របស់ទាំងនោះ ព្រោះជាសម្បត្តិនៃខ្មែរគ្រប់រូប។

ឯអូន នឹងរើសរក យកភូមិណា តូចល្មម ធ្វើជាភូមិគំរូ ។ រកភូមិណា ដែលក្រជាងគេ បំផុត ហើយដែលគ្មានសាលារៀន។ អូននឹងបង្រៀនកុមារី ក្មេងស្រីៗ ឲ្យចេះធ្វើម្ហូប អាចបើកភោជនីយដ្ឋានបាន។ ព្រោះទៅថ្ងៃមុខដោយសារអង្គរ ច្បាស់ជាមានទេសចរណ៍ មកលេងជាច្រើនលើសលុប ។ ទេសចរណ៍ទាំងនោះ គេត្រូវការម្ហូបឆ្ងាញ់ពិសា និងទស្សនាប្រាង្គប្រាសាទ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឯក្មេងប្រុសៗ ត្រូវបង្ហាត់ឲ្យដាំស្ពៃ សាឡាដ និងចិញ្ចឹមមាន់ទា ។ បានរបស់ទាំងនោះ យើងលក់ខ្លះ យើងយកមកដាំស្ល បង្រៀនក្មេងស្រីៗ ។

បងអាចជួយបង្រៀន ខាងសំណង់ ជាងឈើ ជាងធ្វើផ្ទះទៀតផង ។

ជាច្រើនរយឆ្នាំមកហើយ អ្នកប្រាជ្ញចិនម្នាក់ បានសរសេរថា បើអ្នកចង់ជួយមនុស្សអត់ឃ្លាន មិនត្រូវឲ្យត្រីស៊ីឡើយ ត្រូវបង្រៀនឲ្យអ្នកនោះចេះស្ទូចត្រី ទើបប្រសើរជាង ។ បើយើងឲ្យត្រីស៊ី ជននោះស៊ីត្រីតែមួយថ្ងៃ អស់អ៊ីស៊ីទៀត ហើយ ។ តែបើយើងបង្រៀនឲ្យចាប់ត្រីវិញ បំណេះនឹងជួយដល់ជននោះឲ្យរស់រានមួយជីវិត ។

ខេមរា ជូនយោបល់ តាមការសិក្សានៃអ្នកឯកទេសបរទេស ឲ្យដឹងថា ពីកុមារដ្ឋាន ដល់ថ្នាក់បញ្ចប់ សិស្សពូកែ ឬមិនពូកែ ដោយសារតែគ្រូបង្រៀនប៉ុណ្ណោះ ។ សាលាមិនចាំបាច់ធ្វើពីថ្ម ឬពីឈើឡើយ ទោះជាស្បូវ អាចឲ្យយើងបង្រៀនកូនខ្មែរបានពូកែដែរ ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឆេទី - បងនិយាយត្រូវមែន ។ បងមើលព្រះជិនវង្ស មើលមានចាំបាច់សាលាថ្មីឯណា ម្ដេចក៏ពូកែម្ល៉េះ? អ្នកទាំងពីរសើចលេងដោយសប្បាយ ។

ខេមរា- របៀបបង្រៀនតាមតាឥសី ពុំអាចធ្វើឲ្យមនុស្សពូកែបានឡើយ ក្នុងបច្ចុប្បន្ននេះ ព្រោះជារបៀបផ្សព្វផ្សាយ បំណេះដោយមន្ត អាគម គាថា ។ ឥឡូវរបៀបបង្រៀន គឺធ្វើយ៉ាងណា ឲ្យមនុស្សឆ្លាប្រើនបេះ ។ គេមិនបង្រៀនតែបច្ចេកទេសទេ គេបង្រៀនពង្សាវតារ ភូមិសាស្ត្រ ចរិយាសាស្ត្រនិងបង្ហាត់បង្រៀនឲ្យសិស្សស្រឡាញ់ជាតិឯងផង ។

ឆេទី- ព្រះពុទ្ធទ្រង់ប្រដៅមនុស្សឲ្យល្អ ដោយសំដីវាចាល្អ ពាក្យពិរោះ យកទៅគិត មិនមែនដោយព្រនង់ឬរំពាត់ឡើយ ។ អ្នកដែលបង្រៀនក្មេង តោងចាត់ទុកខ្លួន ដូចជាឪពុកម្ដាយ ជួយណែនាំក្មេងឲ្យឈានឆ្លងបឹងល្វង់ខ្មៅ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំពោះខ្ញុំ គ្រូ អ្នកណាដែលមាន សន្តានចិត្តជាល្អ ខិតខំបង្រៀន ខ្ញុំឲ្យទៅមុខ ចង់ឲ្យខ្ញុំខ្ពង់ខ្ពស់ ថ្កើងថ្កាន រុងរឿង។

ការអប់រំតាមរបៀបសព្វថ្ងៃ របៀបស្រុកខ្មែរ យើងពុំអាចធ្វើឲ្យមនុស្សបានល្អ ក្នុង១០ឆ្នាំទៅមុខទៀតបានឡើយ។

គ្រូ ពុំបានធ្វើជាគំរូល្អ ដល់សិស្ស ព្រោះគេសំអាងថា ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឱ្យយក ។ យើងពុំមានវីរបុរសគំរូ ឬមនុស្សជាគំរូ សម្រាប់ក្មេងជំនាន់ក្រោយ។

នៅស្រុកគេធំៗដូចស្រុកបារាំង មានកន្លែងទុកសព នៃវីរបុរសរបស់ប្រទេសគេ ដែលគេហៅថា ប៉ង់តេអុង (Panthéon)។

អ្នកដែលមិនបានទៅដល់វីរបុរស តែបានធ្វើអំពើល្អ ក៏គេឲ្យឈ្មោះទៅដល់អ្នកនោះដែរ ដូចជាច្បាប់ជាដើម "ច្បាប់លោកនេះ ច្បាប់លោកនោះ ។ល។"

អ្នកខ្លះទៀត ដែលបានបូជាជីវិត ដល់ប្រទេសជាតិ ក្នុងសង្គ្រាម លោកលើកទី១ ឬលោកលើកទី២ ត្រូវគេ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

សរសេរបារឈ្មោះ នៅតាមជងផ្លូវ របងផ្ទះ ឬសួនច្បារ ។ អ្នកស្លាប់របៀបនេះមានច្រើនណាស់នៅស្រុកបារាំង។

មិនតែប៉ុណ្ណោះ បុត្រាបុត្រី នៃជនដែលបានបូជាជីវិតសម្រាប់ប្រទេសបារាំង គេហៅថា កែវភ្នែក ឬ ប្រស្រីភ្នែកនៃមាតុប្រទេស។ ប្រទេសត្រូវតបស្នង សងគុណដល់មាតាបិតា នៃជនទាំងនោះ តាមរយៈកូននេះឯង ។

មានរបរ និង ការងារខ្លះ គេទុក សំរាប់ តែកែវភ្នែក នៃប្រទេស ដែលមាន សិទ្ធិ រើសយក មុនគេ ។ បន្ទាប់មកបានធ្លាក់ទៅជនានុជន ទូទៅ ។

សង្គ្រាម គ្មានបាន បង្ហាត់បង្រៀន ខ្មែរ ឲ្យ ធ្វើល្អ ចំពោះគ្នាទាល់តែសោះ ផ្ទុយទៅវិញ សង្គ្រាមបង្រៀនមនុស្សឲ្យចេះខូច ចេះវៀចវេរ ដើម្បីរស់។

យើងធ្វើយ៉ាងណា ឲ្យក្មេងដែលទៅរៀនសប្បាយនិងទៅរៀន សប្បាយនិងការចេះដឹង សប្បាយនិងរស់នៅជួបជុំមិត្តភក្តិ លេងសប្បាយ ជាមួយគ្នា ។ ព្រោះសាលារៀនជាសង្គមតូចមួយ ដែលយើងហាត់រស់នៅជាមួយគ្នា



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ហាត់ប្រណាំងប្រជែងយកឈ្នះ យកបាញ់គ្នា ក្នុងផ្លូវកិត្តិយស ក្នុងផ្លូវប្រាជ្ញា ។ ត្រូវធ្វើយ៉ាងណា ឲ្យសាលា ជាកន្លែងសំរាប់ពលរដ្ឋខ្មែរ ទៅថ្ងៃក្រោយ ឲ្យក្មេងហ៊ាននិយាយស្តី បញ្ចេញយោបល់ បញ្ចេញមតិ ក្នុងទិសដៅធំ គឺ ធ្វើយ៉ាងណា ជំរុញកិច្ចការ ឲ្យដើរទៅមុខ ។

បង! ពេលនោះឆេទី នឹកដល់បងប្រុស ឈ្មោះឆណ្ណា ។ ឆណ្ណាជាកូនក្មោះជាមួយនាង ។ យើងស្រឡាញ់គ្នា ប្រឡែងលេងសើចក្អាកក្អួយ កាលនៅវ័យពិកុមារភាព ។ ខ្មែរច្រើននិយាយថាៈ កាលពីជាតិមុន យើងជាប្តីប្រពន្ធនិងគ្នា ។

ពេលដែលគ្រួសារបុះក្រ ខ្ញុំបែកបងប្អូនអស់ ។ អ្វីដែលខ្ញុំស្រឡាញ់ ឃ្លាតឆ្ងាយពីខ្លួនខ្ញុំ ។

បងអើយ! អូននៅតូចនៅឡើយ ។ សេចក្តីភ័យរន្ធត់ អង្រួនខ្លួនអូន រហូតដល់សព្វថ្ងៃនេះ ។ ខ្ញុំនិងឆណ្ណា ឱបគ្នាយំ ពេលដែលយើងត្រូវបែកគ្នា ។ អូនមករស់នៅខេត្តសៀមរាប ឆណ្ណាទៅនៅជាមួយឪពុកមា ឯខេត្តស្ទឹងត្រែង ។ យើង



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅបែកគ្នា ៗ ឆ្ងាយ អើយ សែនឆ្ងាយ! យើងព្រាត់ប្រាស គ្នា ដូចមនុស្សស្លាប់ ៗ

ក្រោយមក អូនបានទទួលដំណឹងថាឥឡូវ មានបរិតប្តូរ ច្រើន គេទៅជាមនុស្សខឹងច្រើនប្រឡោកគោតតូង មួរម៉ៅ មិនសប្បាយចិត្ត នឹងជីវិត នឹងវាសនា នឹងប៉ូលីស ដែលគ្រិះ គ្រុសរកលុយ នឹងប៉ូលីសដែលចាប់គេ ព្រោះជិះកង់ឥត ភ្លើង ៗ ឥឡូវ ហ៊ាននិយាយ តៗ និងទិទៀន រដ្ឋការ ដោយ ឥតខ្លាច ៗ

អាកប្បកិរិយារបៀបនេះហើយ នៅជំនាន់នោះ រមែង នាំមកនូវសោហ្មង ពីសំណាក់អ្នកកាន់អំណាច ៗ

យើងនៅឆ្ងាយពីគ្នា ពុំមានឱកាសរិះរកផ្លូវល្អ សំរាប់ ដំណើរជីវិតទៅអនាគត ៗ ជីវិតរមែងមានការជូរចត់ ដូច នេះ យើងត្រូវតែ ខំកសាងខ្លួន ឲ្យរឹតតែប្រសើរឡើង ៗ កាលពី ៤០ ឆ្នាំមុន កង់ឥតភ្លើង ឥតហ្រាំងមានស្ទើរតែគ្រប់ គ្នា ៗ ថ្នល់ចាក់កៅស៊ូ មានតែថ្នល់ធំៗ ខ្មែរ មានឡានរាប់ ស៊ើ នឹង ម្រាមដៃ ៗ តែប៉ូលីស ចូលចិត្ត ធ្វើបាប យុវជន



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចាប់ឥតប្រណី ។ កង់ជិះឱបគ្នា ក៏ពុំបានដែរ ។ ច្បាប់ធ្វើសំរាប់មនុស្ស ទូទៅ ចាប់តែគ្នាល្អិតល្អោច ។ ប៉ូលិសឥតហ៊ាន ចាប់ បនបៀរ បនល្បែងស៊ីសង កាន់កាប់ដោយ អ្នកអម្ចាស់នេះ ឬ អម្ចាស់នោះឡើយ ។ បនបៀរ មានច្រើននៅក្នុងរាជធានីភ្នំពេញ ជំនាន់នោះ ។

ឥណ្ឌា! ជាតិមុន ប្រហែលជា យើងសប្បាយ នឹងរស់នៅជាមួយគ្នា ។ យើងបានផ្សងឲ្យជួបគ្នាជាតិនេះទៀត។ តែភាពក្រីក្រ បានបំបែកយើងៗ សំណាងយើងក៏មិនដូចគ្នា ។ ជាតិនេះក៏មិនប្រសើរជាងជាតិមុនដែរ។

ខ្ញុំដួល បាត់ស្មារតី ពេលដែលឃើញរូបឥណ្ឌានៅទួលស្លែង ។ ទួលស្លែងក្លាយជាកន្លែងមួយ ដែលប្រវត្តិសាស្ត្រខ្មែរត្រូវកត់ត្រាបញ្ចូល ។ អ្វីដែលជាប្រវត្តិសាស្ត្រ យើងមិនត្រូវបំផ្លាញបំបាត់ឡើយ ព្រោះជាមេរៀន ដល់ខ្មែរជំនាន់ក្រោយ ។

ឥណ្ឌា! បងអើយ! ម៉ាក់មាសម្ដាយ ខ្ញុំចង់ជួប អ្នកទាំងពីរ នៅជាតិក្រោយទៀត។ តែខ្ញុំនឹកថា បើជួបគ្នាទៀត ក៏



www.facebook.com/7khmer
Fb page : Entertainment And Knowledge

មិនសប្បាយដែរ ។ ជណ្ណាទិងខ្ញុំ យើងកើតថ្ងៃខែជាមួយគ្នា សំណាងយើង មិនដូចគ្នា ។ អ្នកដែលខ្ញុំចង់ជួបគឺ ព្រះបាទជ័យវរ្ម័នទី៧ នោះខ្ញុំយល់ឃើញថាសង្គម នឹងប្រែប្រួល មិនខាន ។ ពេលដែលខ្មែរ សង់អង្គរ លើកថ្មទាំងផ្ទាំងៗ ជ្រោងឡើងខ្ពស់ដល់ពពក បារាំងចាប់សង់ Notre Dame de Paris ។



ព្រះវិហារ " Notre Dame "កសាងនៅឆ្នាំ១១៦៣-១៣៣០



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលនោះ បច្ចេកទេស យើងមានប្រៀបជាង ។ ម្ដេច ឡើយ ក៏ក្រោយមក ខ្មែរចុះថយរហូត ដល់ក្លាយ ជាខ្ញុំ បារាំង?

ទឹកភ្នែកឆេទី ហូរ ធ្លាក់ ឥតដាច់ ៗ នាងខ្សឹកខ្សួល អួល ដើមក ជាខ្លាំង ពុំអាចនិយាយ តទៅទៀតបាន។ នៅស្រុក គេ គេបណ្ដុះពូជល្អ តាំងពីតូចមកម៉្លេះ!

នៅស្រុកបារាំង គេបង្រៀនក្មេងឲ្យធ្វើតំណាងរាស្ត្រ ។ គេជ្រើសរើស តំណាងសិស្ស គ្រប់ភូមិ ស្រុកមកប្រជុំគ្នា នៅសភាជាតិ ម្ដងៗ ។ ក្មេងទាំងនោះ ហាត់ធ្វើច្បាប់ ស្នើ តំរោងច្បាប់ ។ល។

នៅប្រទេសអង់គ្លេស គេបង្ហាត់កូនសិស្ស ឲ្យគិតគូរ កិច្ចការ ភូមិស្រុក ដូចជាមេឃុំ ឬ ចៅហ្វាយស្រុក ធ្វើយ៉ាង ណា ឲ្យភូមិស្រុកខ្លួនបានចំរើន ។ កុមារ ទាំងនោះជាពល រដ្ឋល្អ ទៅថ្ងៃក្រោយៗ ទំពាំងស្នងឫស្សី ។ ដូចនេះ ក្មេង ទាំងនោះត្រូវហាត់ឲ្យចេះគិត កសាងស្រុក សំរាប់ខ្លួន ទៅ អនាគត ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឯក្មេងនៅស្រុកយើង ច្រើនស្អប់ខ្ពើមប៉ូលិស តិញ អ្នករដ្ឋការ ពុករលួយ ចង់គំនុំ និងអ្នកទាំងនោះ ។ ក្នុងចិត្តចង់តែសងសឹក សម្លាប់បំផ្លាញ អ្នកដែលជិះជាន់ខ្លួន ។ ដល់បានឱកាស ដូចខ្មែរក្រហម អញ្ចឹង ក៏បញ្ចេញកំហឹងសម្លាប់ឥតត្រាប្រណី ។

នៅស្រុកខ្មែរ "ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" ។

នៅស្រុកគេ "ទឹកឡើង កុំចាល់ឡើងតាមទឹក " ។

ឆេទី នាងលូកដៃទៅកាន់ដៃប្រុសស្នេហ៍ ។

បងអើយ ! ជីវិត អូន ចប់ត្រឹមណេះហើយ ។ អំណោះតទៅ អ្វីដែលអូនធ្វើ គឺដើម្បីជួយអ្នកដទៃ តែប៉ុណ្ណោះ ។ អូន លែងចង់មាន ចង់បាន ធ្វើជាប្រយោជន៍ ផ្ទាល់ខ្លួនទៀតហើយ ។ មិនមែនរហូតដល់ព្រះវេស្សន្តរនោះទេ ព្រោះប្រាក់កាស យើងមានគ្រប់គ្រាន់ រហូតដល់ថ្ងៃស្លាប់ ។

"របស់ទ្រព្យ ដែលយើង អាចយកទៅឋានសួគ៌ បាន
លុះត្រាតែយើងធ្វើអំណោយ ដល់គេឯង ពេលដែលយើងរស់នៅ " ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

អូនស្រឡាញ់កូន! តែមរតក ថ្លៃថ្លា សំរាប់ជីវិតកូន មិនមែនលុយទេ គឺចំណេះវិជ្ជា និងចរិយា ៗ របស់ទាំងពីរ បូកគ្នា ដែលយើងសព្វថ្ងៃហៅថាវាសនា របស់មនុស្ស វាសនាបច្ចុប្បន្ន។

វាសនានេះ ថ្កុំថ្កើងបាន កើតឡើង ដោយនាងមាន ចំណេះ ខាងម្ហូបអាហារ និងចរិយា ត្រឹមត្រូវ មានមិត្តភក្តិ បងប្អូនស្រឡាញ់ រាប់អានទុកចិត្ត។

ពេលនេះ នាងអាចរស់ដោយខ្លួនឯងបាន ដោយមិនបាច់ពឹងលើកម្លាំងប្តី ៗ មិនដូចស្ត្រីខ្មែរភាគច្រើន ដែលរស់នៅក្រោមម្លប់ ប្តី ៗ ជីវិតទាំងមូល ពឹងផ្អែកទៅលើបុរសតែមួយ ៗ ពេលដែលប្តីដួល គ្រួសារទាំងមូលរលំ គ្មានអ្វីអាចទប់ទល់នឹងព្យុះព្យោមា ដែលបោកបក់មកលើក្បូនគ្រួសារបាន។

សង្គមខ្មែរ ពុំបានបង្រៀន ឲ្យយើងខំធ្វើការទេ បែរជាបង្អុលផ្លូវ ត្រូវតែបែរបន់ ឱនសំពះ សុំតេជៈបារមី សុំសុខភាពល្អ សុំស្រណុកសុខសប្បាយ ដេកស៊ី ស៊ីដេក



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពឹកផ្អែកទៅលើអបិយជំនឿ ។ នេះជាទស្សនៈនៃការរស់នៅរបៀបស្រុកយើង។

នៅអឺរ៉ុប គេជឿថា មនុស្សត្រូវតែធ្វើការ ។ ធ្វើការចិញ្ចឹមជីវិត អាចឲ្យមនុស្សមានសេរីភាព មិនពឹងផ្អែកទាំងស្រុងទៅលើវាសនា និងព្រហ្មលិខិត។

យប់ល្ងឹត ព្រឹលៗ បក្សីថ្ងៃហើរចូលទ្រនំ បក្សីយប់ចាកទ្រនំ បោះពួយសំដៅទៅកន្លែងរកស៊ី ព្រិលជ្រុះរុះរោយ ធ្លាក់រពុយ ពុំដាច់ ឆេចម្នាក់ឯង ក្នុងបន្ទប់ នាមន្ទីរពេទ្យ ក្រឡេកមើលតាមបង្អួច ។

សូម្បីតែសត្វ ក៏ត្រូវខំរកស៊ីដែរ ។ មួយថ្ងៃ ស៊ីបានតែមួយចម្អែត។ មនុស្សត្រូវរកស៊ី រកស៊ីទុក តកូន តចៅ ចៅទួត ចៅលួត ចៅលា ។ តែខ្មែរ បំផ្លាញគ្នា រលាយខ្ទេចខ្ទី គ្មានសល់ដល់កូនចៅឡើយ ។

ម្នាក់ឯង តទល់ និងជម្ងឺ តទល់ និងវាសនា? ពេលឈឺគ្មានអ្នកណា ជួយយើងបាន ក្រៅពីគ្រូពេទ្យ តែនាងពុំបំភ្លេចបន់ស៊ុំជីវិត ឲ្យរស់រាន តទៅទៀត ។ នាងបន់ស៊ុំ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីសុខ ដូចបងប្អូនខ្មែរផ្សេងទៀត ។ ទម្លាប់នេះមាន ជាយូរយារមកហើយ ។ ទឹកភ្នែកឈឺ ហៀរហូរមក ដោយឯកឯង ៗ នាងជណ្ដឹងសួរខ្លួនឯងថា ៖

តើយើងអាចគេចផុតពីវាសនា បានឬទេ? ធ្វើបុណ្យធ្វើទាន បញ្ចៀសកម្មផល និងកម្មពៀរ? តើបានដូចប្រាថ្នាឬទេ?

ដាក់ឈ្មោះឲ្យកូនថា សុខ ដើម្បីឲ្យបានសុខ

ឈ្មោះសំណាង ដើម្បីឲ្យមានសំណាង... ៗល ៗ...

នេះគ្រាន់ជា ក្ដីសង្ឃឹម តែប៉ុណ្ណោះ !!!

លន់ នល់ ពេលឡើងកាន់អំណាច សន្យាថា ឲ្យគ្រួសារខ្មែរម្នាក់ៗ មានទូទស្សន៍ និងទូរទឹកកក !

ប៉ុល ពត សន្យាថាកសាងសង្គម ឲ្យមានភាពស្មើគ្នា និងមាន ប្រជាធិបតេយ្យ ពិតប្រាកដ !

ទាំងនេះជាស្រមោល ជាពាក្យភូតភរ កុំឲ្យរាស្ត្របះបោរ ដើម្បីខ្លួនក្រាញនៅលើអំណាច ៗ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឯពុទ្ធទំនាយ ទាយថាមានសង្គ្រាម គឺបណ្ដាលមកពីរបបគ្រប់គ្រងរដ្ឋ មិនល្អ តែប៉ុណ្ណោះ! បើមានប្រជាធិតេយ្យ មានយុត្តិធម៌ក្នុងសង្គម នោះគ្មានទេ ពុទ្ធទំនាយ ។

## វាសនាមកពីនយោបាយ

**ណាប៉ូឡេអុង**

វាសនាអ្នកល្អ យ៉ាងណាក៏ដោយ នយោបាយ ប៉ុលពត បានធ្វើឲ្យ មនុស្សទូទាំងប្រទេសស្លាប់ ព្រាត់ប្រាសនិរាសគ្និគ្នា ហិនហោច ខ្លោចផ្សា ក្រីក្រ អន្តរធាន គ្មានទីពឹងទីជម្រក និងវេទនារកទីបំផុតគ្មាន ។

ចប់ ភាគ១

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ប្រវត្តិរូបអ្នកនិពន្ធ

## ជៀប គឹមហៀង

CHIEP Kim Heang

- កើតនៅថ្ងៃ១៨ ធ្នូ ឆ្នាំ១៩៤៥ នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

- ឪពុកឈ្មោះ **ជៀប ជិនឡេង** ម្ដាយ **តាំង អេង**។
- សិក្សាជាដំបូង នៅសាលាសួង - អនុវិទ្យាល័យ សួង-រួច មកវិទ្យាល័យ ព្រះសីហនុ កំពង់ចាម រហូតដល់ មធ្យមសិក្សាប័ត្រភាគទីពីរ។
- សិក្សានៅ មហាវិទ្យាល័យ ក្សេត្រសាស្ត្រ ចំការដូង ជំនាន់ទី១ ផ្នែកបសុពេទ្យ។
- បានបន្តវិជ្ជានៅទីក្រុងប៉ារីស ឆ្នាំ១៩៧០ ដោយអាហារូបករណ៍បារាំង។
- បានសិក្សានៅវិជ្ជាស្ថានផ្នែកខាងជំនួញអន្តរជាតិ នាក្រុងប៉ារីស។ ជាប់សញ្ញាប័ត្រពីវិជ្ជាស្ថានផ្សេងៗ ដូចតទៅ៖
- Institut National Agronomique Paris Grignon (INAPG)
- Institut Supérieur d'Industries et d'économie laitières ( ISIEL)
- Ecole Technique de Conserve à Paris
- Institut du Commerce International (ICI)



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផ្សាយចេញពី

សមាគមអ្នកនិពន្ធខ្មែរនៅបរទេស

សមាគមខ្មែរសាកល

១.- ក្រឡេកមើលភ្លើងឆេះស្រុកខ្មែរ... ពីក្រោយម្លាង

សមាគមអ្នកនិពន្ធខ្មែរនៅបរទេស ប៉ារីស ១៩៩៧

២.- ខ្មែរលើកម្ពីរ ស្វែងរកព្រះបាទជ័យវរ្ម័នទី៧

សមាគមខ្មែរសាកល ប៉ារីស ២០០៣

រក្សាសិទ្ធិគ្រប់បែបយ៉ាង

www.facebook.com/7khmer 
Fb page : Entertainment And Knowledge

លោក ជៀបគីមឈាង ក្នុងនាមជាកម្រងពេជ្រ បានរំលេចរឿង ៖ “ក្រឡេកមើលភ្លើងឆេះស្រុកខ្មែរ... ពីត្រើយម្ខាង ” ដែលបានទទួលរង្វាន់ចំណាត់ថ្នាក់លេខ១ ពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស ដោយមានកំណត់ចំណារ ចារភ្ជាប់សំរាប់បញ្ជាក់ ពីប្រធានសមាគម ដូចតទៅ៖

“... ផ្ទុះព្រឹត្តិការណ៍ពិតជាក់ស្តែងរបស់និស្សិតខ្មែរ ក្នុងផ្ទះខ្មែរ នាទីក្រុងប៉ារីស ។

- ប្រវត្តិស្នេហា ប្រកបដោយការភ្ញាក់រឭក ចំពោះហេតុនិងអំពើកន្លងមក ។

- សាច់រឿងមានខ្លឹមសារ មានឧត្តមគតិ ជារឿងល្អអាចចាត់ទុកជាចំណីអារម្មណ៍ សំរាប់យុវជន ជំនាន់ក្រោយ ។

- អហិង្សា ការមានគំនិតសាមគ្គី បោះបង់ការប្រណែននិន្ទា ឈ្នានីស គំនិតស្វែងរកសេចក្តីសុខ សន្តិភាព ដែលតួអង្គឯកក្នុងរឿងនេះ បានប្រព្រឹត្ត នៅក្នុងដំណើរជីវិត គឺជាវីរភាពមួយកម្រជួប... ។ ”

**សមាគមអ្នកនិពន្ធខ្មែរនៅបរទេស**

អ្នកស្រី **ប៊ិច សង្វារ៉ាន**



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ឧបសម្ពន្ធ
# Annexe

## ប្រាសាទតាព្រហ្ម

បទនាគបរិព័ន្ធ

ពាក្យ៨

> តាព្រហ្មយំ យែកស្រែក ផ្តែផ្តាំទៅ
ផ្តែផ្តាំថា ឈប់ទៅ រ៉ើឆានខ្មែរ!
រ៉ើឆានខ្លាំង ប្រឆាំង ទឹងជាតិគេ
ទឹងជាតិតាក់ ស្បថស្បែ ថែសង្គ្រាម !

> ថែសង្គ្រុប សង្គ្រោះ យកថ្ពុស
យកថ្មជា ចំរុះ ថ្មបាយក្រៀម
ថ្មបាយក្រួស ក្រំក្រ ថ្មក្អួតឈាម
ថ្មក្អួតឈូ! ឈប់ភ្ញាម!! ខ្លាចចាមចាប់!!!

> ខ្លាចចាមចូក! ចាមឈូស!! ចាមកកាយ!!!
ចាមកកូរ ថ្មភាយ ក្លាយខ្ទនស្លាប់!
ក្លាយខ្ទនស្ងឹង មិនដឹងទឹងរ៉ាយរ៉ាប់
ទឹងរ៉ាយរឿង រៀបរាប់ ក្រែងពុំគួរ ៗ

> ក្រែងពុំតាប់ ទឹងច្បាប់អ្នកកស៊ូ
អ្នកកសិល ថ្ពួចថ្ពូរ ក្តិពុំគួរ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ក្តីពុំគាប់ ពុំជាប់អួប្រណូ
អួប្រណម្យ លន់គូ គូរប្រណិ !

> គូរប្រណិត លំអិតចិត្តលំអ
ចិត្តលំអោន សីលធម៌ក្រោមព្រឹក្សព្រៃ
ក្រោមព្រឹក្សព្រាត ព្រោងព្រាយភាយបារមី
ភាយបរមត្ថ សេចក្តីន័យថ្លៃថ្លា ។

> ន័យថ្លៃថ្លែង សម្តែងក្រោមបុសស្តន់
ក្រោមបុសស្តិន វិនស្តិនត្បែនថ្មជា
ត្បែនថ្មផុស បំផុសក្តីស្នេហា
ក្តីស្នេហ៍ហ៊ក សច្ចា ស្មិត្រគម្គល់ ។

> ស្មិត្រគម្គីង ថ្កើងសុខស្រណុកប្រាណ
ស្រណុកប្រាថ្ន ប្រមាណ លែងមានខ្វល់
លែងមានខ្វិក វិពើកទៅតាមខ្យល់
ទៅតាមខ្យាយ យោបល់ខ្វល់ទីងភ័យ ។

> ខ្វល់ទីងភ័ត្ សំណាងសានថ្មផុស
សានថ្មជា បំផុសបំផុលព្រៃ
បំផុលព្រឹក្ស សទ្ទិកទាំងយប់ថ្ងៃ
ទាំងយប់ថ្ងូរ ក្រែងព្រៃឃ្លាតបោលថ្ម ។

ឃ្លាតបោលថ្មើរ ណាក្រាស្គន់ទីងបេញ!
ស្គន់ទីងចាកបោលវិញ លុះក្តីមរណ៍!
លុះក្តីមាន ធានាការពារថ្ម!
ការពារថ្មិ! សាធុ ពិសាគ្នលោក ។ល។

ឆួច គិមស៊ិគ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# បណ្ណាល័យខ្មែរ

លើប្រព័ន្ធ អ៊ីនធឺណែត តាមបណ្ដាញ ៖ W.W.W( World Wide Web ) ហៅថា "ព.ព.ព" អក្សរកាត់របស់ពាក្យ (ពីងពាងព័ទ្ធពិភពលោក) បានលេចត្រដែតនៅលើគេហទំព័រ ៖ http://bible.aku.free.fr

ប្រយោជន៍លាតត្រដាងនិងលើកតម្កើងវប្បធម៌និងសង្គមធម៌ខ្មែរ ដែលជា ជម្រក និង ជាកញ្ចក់ឆ្លុះនូវអារ្យធម៌ខ្មែរ ផងដែរ ។

សំណាដៃរបស់លោក - លោកស្រី៖

- នីតិសាស្ត្រ - ឌុក រ៉ាស៊ី (បណ្ឌិត)
- អក្សរសិល្ប៍ -ឃឹង ហុកឌី (បណ្ឌិត)
- ប្រលោមលោក -ជុត ខៃ (បរិញ្ញា) - ជៀប គឹមហៀង (វិស្វករ)
- ទស្សនៈ - ខណ្ឌ សុភា (បរិញ្ញា)
- សាសនា - សោម សុខណ្ឌ (ឧបជ្ឈាយ៍)
- កំណាព្យ-ម៉ឹន ខាន់ (អតីតជាងទង)- ឆួច គិម ស្ងួត (វិស្វករ)

-គួច សុខ ឃាត់ (វិស្វករ) - អ៊ុំ ឃួត (បរិញ្ញា) - ខណ្ឌ សុភា (បរិញ្ញា)...

- កំព្យូទ័រ -ជួន ការ៉ុល (វិស្វករ)
- ល្បែងកំសាន្ត - អ្នកស្រី ពេជសល់ នាមដើម សារិះយ៉ាន - អ៊ុំ ឃួត (បរិញ្ញា)

បានផ្សាយរួចហើយនៅក្នុងប្រព័ន្ធ "ព.ព.ព" នេះ។

នឹងមានផ្សាយតាមរយៈ **បណ្ណាល័យខ្មែរ** នូវសំណេរនិងដំណឹងផ្សេងៗ ជាលំដាប់លំដោយ ដោយបន្តបន្ទាប់ សំរាប់សេចក្តីត្រូវការនៃអស់លោក-អ្នក- នាង។



www.facebook.com/7khmer
Fb page : Entertainment And Knowledge



លោក **ជៀប តឹមហ៊ាង** បានបញ្ចប់ឧត្តមសិក្សា នៅស្រុកខ្មែរ ជាវិស្វករបសុពេទ្យ ។ លោកនៅតែខំស្វះស្វែងរកចំណេះវិជ្ជា រហូតដល់បានទទួលសញ្ញាបត្របួនទៀត ដោយសង្ឃឹមថានឹងបានវិលវិញ មកបំរើជាតិ ។

លោក ជៀប តឹម ហ៊ាង ស្រដៀងនាមនឹង ជៀប កប្បាស ។ លោកខ្វល់ណាស់នឹងក្រេបរសជាតិបច្ចេកវិជ្ជា ដូចគ្នានឹងជៀបកប្បាសដែលខ្វល់ណាស់នឹងក្រេបលំអងផ្កា ។ លោកពុំនឹកស្មានថានឹងមានឧបសគ្គមករាំងរាដំណើរវិលវិញ យ៉ាងណាមិញ ជៀប កប្បាស ក៏ពុំនឹកស្មានថា ដល់ពេលថ្ងៃលិច ផ្កាឈូកនឹងបិទស្រទាប់ហើយខ្ទប់ទាំងរូបបក្សា យ៉ាងនោះដែរ ។

ភ្លើងឆាបឆេះព្រៃ រាលដាលប្រល័យកូនក្នុងសំបុក ពេលនោះ ជៀប កប្បាសកំពុងតែរីបម្រះក្នុងផ្កាឈូក ដូចគ្នាក្នុងពេលដែលភ្លើងសង្គ្រាមឆេះស្រុកខ្មែរ ពេលនោះលោក ជៀប តឹមហ៊ាង កំពុងតែតស៊ូ យ៉ាងស្វិតស្វាញ បំពេញវិជ្ជានៅឯស្រុកបារាំង ។

ថ្ងៃរះ ផ្កាឈូកបើកស្រទាប់ ជៀប កប្បាស រូតរះវិលត្រឡប់មករកសំបុកវិញ ។ ពុំទាន់ទាំងបានយកលំអងផ្កាបញ្ចុកកូនផង ក៏ត្រូវប្រពន្ធស្តីបន្ទោសទាំងយំសោកបោកខ្លួនថា ពិតជារវល់ទៅមានស្រី ព្រោះអីខ្លួនជិតដោយក្លិនក្រអូប បានជាបណ្តោយកូនឱ្យក្ស័យសង្ខារ រួចហើយបក្សីក៏បោះពួយចូលភ្លើងទៅ ទុកឱ្យបក្សារនៅខកចិត្តអាណិតខ្លួន ផ្ទួនទុក្ខ ផ្សងថា ជាតិមុខនឹងប្រាថ្នាឱ្យជួបតែប្រពន្ធកូន រួចក៏បង្ហោនកាយថ្វាយព្រះអគ្គី !!!

ក្រោយសង្គ្រាម ឈាមលែងដាបពោះដី ពុំទាន់បានយកចំណេះបច្ចេកវិជ្ជាអ្វី ទៅបំរើជាតិផង លោក ជៀប តឹមហ៊ាង ក៏ក្លាយខ្លួនទៅជាអ្នកនិពន្ធ ហៅក្រមងពេជ្ររំលេចសេចក្តី ៖
" **ក្រឡេកមើលភ្លើងឆេះស្រុកខ្មែរ...ពីក្រោយម្ខាង** " ។

ជា **ជៀប កប្បាស** លោកត្រាំថ្នាស់រហស្សនាមថ្មី ក្នុងស្នាដៃលើកតម្លៃអក្សរសិល្ប៍ និងភាសាខ្មែរ ផ្សៀផ្សំក្រមងផ្សង រកខ្មែរអ្នកមានបុណ្យ ដើម្បីទ្រទ្រង់ ស្នេហាការពារ និង កសាងជាតិ ៖
" **ខ្មែរឈឺគម្ពីរ ស្វែងរកព្រះបាទជ័យវរ្ម័នទី៧** " ។

អស់លោកអ្នកអាននឹងបានជ្រាបថា អ្នកដែលស្វែងរកវិជ្ជាបច្ចេកទេស ហើយលង់ទ្រនេសក្នុងការប្រលោមលោក ពុំមែនជាអ្នកទទួលនូវចំណេះធម្មតាទេ ព្រោះថាវិជ្ជាមួយជាវិជ្ជាប្រាកដនិយម ហើយវិជ្ជាមួយទៀត ជាវិជ្ជាអណ្តែតអណ្តូងនិយម ។

**សមាគមខ្មែរសារគណ**

**ខូច គិមសួគ៌**

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ**ករុណាខ្មែរ**

Scan ជា eBook ដោយ **ប៉ៅ ភារម្យ**

ក្រោមការឧបត្ថម្ភពី

**ខ្ទៅ សំរ៉ង** និង **កែ ក្រានីត**

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ
ឧបាសក ខ្ទៅ ពញ និង ឧបាសិកា ឈរ យឿន

(ឃុំ កំពង់ឃ្លាំង ស្រុក ជីក្រែង ខេត្រ សៀមរាប)

ខែ កុម្ភៈ ឆ្នាំ២០១៤

www.facebook.com/7khmer
Fb page : Entertainment  And Knowledge